**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ដំណើរការស្វែងរកយុត្តិធម៌ដោយការបង្កើត អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី០៣ ខែមេសា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២៣


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ភោគ សិរីរតនា**

លោក **ហ្គួយ សុខហៀង**

ណែនាំដោយ

បណ្ឌិត **អ៊ឹង រដ្ឋា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៣

ឆ្នាំចូលសិក្សា ២០១៩

ឆ្នាំសរសេរសារណា ២០២៣

# **សេចក្តីថ្លែងអំណរគុណ**

ខ្ញុំបាទឈ្មោះ **ហ្គួយ សុខហៀង** និង នាងខ្ញុំឈ្មោះ **គោគ សិរីរតនា** ជានិស្សិតឆ្នាំទី៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី២៣ ឆ្នាំសិក្សា ២០២២-២០២៣។

**យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

**លោកឪពុក** និង**អ្នកម្តាយ** ជាទីគោរព ដែលបានបង្កើត ចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មាន ប្រៀនប្រដៅ និងទំនុកបម្រុងដល់យើងខ្ញុំគ្រប់បែបយ៉ាង ទាំងស្មារតី និងសម្ភារៈដើម្បីឱ្យយើងខ្ញុំបានសិក្សារៀនសូត្ររហូតដល់ថ្នាក់បរិញ្ញាបត្រ។ គុណូបការៈដែលលោកទាំងពីរបានធ្វើចំពោះកូនៗ មានតម្លៃដែលមិនអាចកាត់ថ្លៃ និងមិនអាចបំភ្លេចបានឡើយ។

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតប្រមុខរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** រួមទាំងសមាជិករាជរដ្ឋាភិបាល ដែលបានរួមចំណែកក្នុងការកសាងជាតិមាតុភូមិកម្ពុជាឱ្យស្គាល់នូវ ស្ថិរភាពនយោបាយ ការបង្រួបបង្រួមជាតិ ឯកភាពជាតិ បូរណភាពទឹកដី និងការអភិវឌ្ឍន៍ ក៏ដូចជាការស្វែងរកនូវយុត្តិធម៌ដល់ប្រជាជនកម្ពុជា។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកការិយាល័យសិក្សា ការិយាល័យស្រាវជ្រាវ ព្រមទាំងបណ្ណារក្សទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការចែករំលែកនូវចំណេះដឹងសម្រាប់ជាស្ពានក្នុងការពង្រឹងសមត្ថភាពដើម្បីអភិវឌ្ឍខ្លួន គ្រួសារ និងសង្គម។

ជាពិសេសយើងខ្ញុំ សូមថ្លែងអំណរគុណចំពោះ **បណ្ឌិត អ៊ឹង រដ្ឋា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ព្រមទាំងកម្លាំងកាយចិត្ត ទាំងបទពិសោធន៍ ចែករំលែកចំណេះដឹង និងណែនាំ ដើម្បីឱ្យសារណាមួយនេះបញ្ចប់ទៅដោយជោគជ័យ។ យើងខ្ញុំ ក៏សូមថ្លែងអំណរគុណ ចំពោះលោកគ្រូ អ្នកគ្រូ ដែលផ្តល់ជាមតិយោបល់ និងឯកសារផ្សេងៗដែលពាក់ព័ន្ធសម្រាប់ការស្រាវជ្រាវលើប្រធានបទនេះ។

**ឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ និងមន្ត្រីនៃមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (ម.ជ.ឯ.ច) និង**រាជរដ្ឋាភិបាលជប៉ុន ក៏ដូចជាប្រជាជនជប៉ុន** ដែលបានផ្តល់នូវអាហារូបករណ៍ដល់យើងខ្ញុំសម្រាប់ការសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ក៏ដូចជារៀបចំវគ្គបណ្តុះបណ្តាលផ្សេងៗ ដែលជាជំនួយទាំងផ្នែកស្មារតី និងសម្ភារៈក្នុងការសិក្សាស្រាវជ្រាវ។ ការផ្តល់ការពិភាក្សា ការពិគ្រោះ ការណែនាំ និងការផ្តល់នូវមតិដើម្បីកែលម្អ បានធ្វើឱ្យសារណាមួយនេះកាន់តែមានភាពល្អប្រសើរឡើង។

ជាកិច្ចបញ្ចប់ យើងខ្ញុំសូមសម្តែងនូវការគោរពជូនពរដល់ **អ្នកមានគុណ សម្តេច ឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យ មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ** សូមជួបប្រទះនូវសេចក្តីសុខ សេចក្តីចម្រើន សុខភាពបរិបូរណ៍ ជន្មាយុយឺនយូរ មានកម្លាំងពលំ ខ្លាំងក្លា ប្រាជ្ញាស្មារតីល្អ ជាពិសេសសម្រេចបានជោគជ័យគ្រប់ភារកិច្ច និងជួបតែពុទ្ធពរទាំង៤ ប្រការកុំបីឃ្លៀងឃ្លាតឡើយ។

# **អារម្ភកថា**

បន្ទាប់ពីបានសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេល ០៤ ឆ្នាំ យើងខ្ញុំសម្រេចជ្រើសរើសយកប្រធានបទ ""**ដំណើរការស្វែងរកយុត្តិធម៌ដោយការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**" មកសិក្សាស្រាវជ្រាវដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ។

ក្នុងនាមជាប្រជាជនខ្មែរ យើងខ្ញុំពិតជាមានការសោកស្តាយចំពោះហេតុការណ៍ដែលប្រជាជនកម្ពុជាបានឆ្លងកាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ឬ ស្គាល់ថា របបខ្មែរក្រហម។ ជាលទ្ធផល តុលាការពិសេសមួយដែលមិនធ្លាប់មាននៅលើពិភពលោកបានលេចជារូបរាងឡើង ដែលគេហៅជាសាមញ្ញថា សាលាក្តីខ្មែរក្រហម កើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាជាមួយនឹងសហគមន៍អន្តរជាតិ ។ តុលាការនេះ គឺជាក្តីសង្ឃឹមសម្រាប់ប្រជាជាតិខ្មែរ ក៏ព្រោះតែគោលបំណងនៃការបង្កើតតុលាការនេះ គឺដើម្បីស្វែងរកនូវយុត្តិធម៌ជូនប្រជាជនកម្ពុជា និងផ្តន្ទាទោសចំពោះបុគ្គលណាដែលបានបង្កឱ្យសោកនាដកម្មកើតមានឡើង។ នេះគឺជាមូលហេតុដែលទាក់ទាញចំណាប់អារម្មណ៍ដល់យើងខ្ញុំក្នុងការសម្រេចជ្រើសរើសយកប្រធានបទនេះមកធ្វើការស្រាវជ្រាវ។

ប្រធាននេះនឹងផ្តល់សារៈសំខាន់ដល់អ្នកសិក្សាស្រាវជ្រាវ ឬ បុគ្គលដែលមានបំណងចង់ស្វែងយល់អំពីសាលាក្តីខ្មែរក្រហម ដោយគោលដៅចម្បងរបស់យើងខ្ញុំគឺចែករំលែកនូវចំណេះដឹងជាមូលដ្ឋាន ដែលជាចំណុចសំខាន់ៗ ដើម្បីជាដើមទុនមុននឹងឈានទៅដល់ការស្វែងយល់ឱ្យកាន់តែមានលក្ខណៈស៊ីជម្រៅអំពីតុលាការនេះ។ មិនតែប៉ុណ្ណោះ យើងខ្ញុំសង្ឃឹមថាប្រធានបទនេះនឹងជំរុញដល់និស្សិតច្បាប់ជំនាន់ក្រោយ ឱ្យសិក្សាស្រាវជ្រាវបន្ថែមអំពីតុលាការខ្មែរក្រហម ពីព្រោះថាមានចំណុចដ៏គួរកត់សម្គាល់ជាច្រើនក្រៅតែពីចំណេះដឹងផ្នែកប្រវត្តិសាស្ត្រ គឺនិស្សិតនឹងស្វែងយល់អំពីបច្ចេកទេសនៃការប្រើប្រាស់ និងការបកស្រាយលិខិតបទដ្ឋានគតិយុត្តស្របតាមស្តង់ដារអន្តរជាតិ ដើម្បីជាពុទ្ធិក្នុងការពង្រឹង និងពង្រីកចំណេះដឹងផ្នែកច្បាប់ឱ្យកាន់តែល្អប្រសើរ។

បើទោះបីជា ប្រធានបទនេះកើតចេញពីសមត្ថភាពនៃការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់យ៉ាងណាក្តី យើងខ្ញុំជឿជាក់ថាកិច្ចការស្រាវជ្រាវនេះ នៅពុំទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយ និងល្អឥតខ្ចោះនៅឡើយទេ ដោយហេតុថាភាពច្រើនសន្ធឹកសន្ធាប់នៃឯកសារដែលពាក់ព័ន្ធ រួមទាំងពេលវេលាដែលត្រូវស្រាវជ្រាវមានកម្រិត។ អាស្រ័យហេតុនេះ សូម ឯកឧត្តម លោកជំទាវ សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តនិស្សិត និងប្រិយមិត្តអ្នកអាន មេត្តាខន្តី អភ័យទោស ចំពោះកំហុសឆ្គងទាំងឡាយណាដែលកើតមានដោយអចេតនាទៅលើការប្រើប្រាស់អក្ខរាវិរុទ្ធ រួមទាំង ខ្លឹមសារ ពាក្យពេចន៍ និងវេយ្យាករណ៍ត្រង់កន្លែងណាដែលលើសលស់ ខ្វះខាត ឬ មិនសមរម្យជាដើម។ យើងខ្ញុំរីករាយ និងស្វាគមន៍ជានិច្ចចំពោះការចូលរួមវាយតម្លៃ និងមតិរិះគន់ក្នុងន័យស្ថាបនាមកលើប្រធានមួយនេះ។

# ឧទ្ទិសស្នាដៃជូនដល់បុព្វការីជន

ក្នុងនាមយើងខ្ញុំជានិស្សិតថ្នាក់ បរិញ្ញាបត្រនីតិសាស្ត្រជំនាន់ទី២៣ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច  ក៏ដូចជាកូនចៅជំនាន់ក្រោយដែលបានសិក្សារៀនសូត្រនៅក្នុងសម័យកាលមួយដែលមានសន្តិភាព និងការអភិវឌ្ឍន៍។ យើងខ្ញុំសូមសម្តែងនូវការគោរពអរគុណ និងរំលែកទុក្ខជូនដល់ក្រុមគ្រួសារយុទ្ធជន កងពលទាហានគ្រប់រូបដែលបានបូជានូវកម្លាំងកាយ កម្លាំងចិត្ត និងជីវិតនៅក្នុងសមរភូមិដើម្បីរំដោះជាតិមាតុភូមិ រួមទាំងប្រជាជនកម្ពុជាឱ្យរួចផុតពីរបបខ្មែរក្រហម។ យើងខ្ញុំក៏សូមចូលរួមរំលែកទុក្ខដល់ក្រុមគ្រួសារជនរងគ្រោះគ្រប់រូប ជាមិត្ត ជាបង ជាប្អូន ដែលបានបាត់បង់ជីវិតនៅក្នុងភ្លើងសង្គ្រាម និងនៅក្នុងអំឡុងពេលនៃប្រទេសស្ថិតក្រោមការកាន់កាប់របស់ពួកខ្មែរក្រហមនៃរបបកម្ពុជាប្រជាធិបតេយ្យ។

សោកនាដកម្មដែលបានកើតឡើងនៅអំឡុងឆ្នាំ ១៩៧៥ ដល់ ឆ្នាំ១៩៧៩ គឺជាការបាត់បង់យ៉ាងធំធេងនូវប្រជាជនខ្មែរ ដែលជា គ្រូ បញ្ញវ័ន្ត ជនស្លូតត្រង់ ដែលបានអស់ជីវិតដោយការកាប់សម្លាប់គ្មានត្រាប្រណី និងគ្មានតុលាការវិនិច្ឆ័យពីពិរុទ្ធភាពឱ្យបានត្រឹមត្រូវ។ សោកនាដកម្មនេះ គឺជាការចងចាំដ៏អាក្រក់បំផុតសម្រាប់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលរស់រានមានជីវិតក្រោយពីសម័យសង្គ្រាម។ ពួកគាត់បានបាត់បង់សាច់ញាតិ មិត្តភក្តិ និងខ្លះទៀតត្រូវបានខ្មែរក្រហមជម្លៀសចេញពីគ្នាដោយមិនបានដឹងថាតើសមាជិកក្រុមគ្រួសារនៅមានជីវិតដែរឬយ៉ាងណានោះទេ។

ជាថ្មីម្តងទៀត យើងខ្ញុំសូមសម្តែងនូវការរំលែកទុក្ខដ៏ក្រៀមក្រំ និងសោកស្តាយជាទីបំផុតចំពោះការបាត់បង់ជីវិតរបស់ប្រជាពលរដ្ឋខ្មែរ។ យើងខ្ញុំសូមលំឱនកាយឧទ្ទិសបួងសួងដល់វិញ្ញាណក្ខន្ធ ដល់យុទ្ធជន យុទ្ធនារី និងប្រជាជនខ្មែរទាំងអស់ដែលបានទទួលមរណៈភាពនៅក្នុងអំឡុងពេលមានសង្គ្រាម និងក្នុងរយៈពេលនៃការកាន់កាប់ដោយរបបខ្មែរក្រហមសូមឱ្យបានចាប់បដិសន្ធិក្នុងសុគតិភព កុំបីឃ្លៀងឃ្លាតឡើយ។

# មាតិកា

## សេចក្តីផ្តើម


**១. លំនាំបញ្ហា** ........ ១

**២. ចំណោទបញ្ហា** ........ ២

**៣. គោលបំណង** ........ ២

**៤. ដែនកំណត់ និងវិសាលភាព** ........ ២

**៥. វិធីសាស្ត្រនៃការស្រាវជ្រាវ** ........ ៣

៥.១ ការប្រមូលទិន្នន័យ ........ ៣

៥.២ ការវាយតម្លៃទិន្នន័យ ........ ៣

៥.៣ ការវិភាគទិន្នន័យ ........ ៣

**៦. សារៈសំខាន់នៃការស្រាវជ្រាវ** ........ ៤

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ** ........ ៤


## ជំពូកទី១

## ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា


**១.១ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ** ........ ៥

១.១.១ ការឡើងកាន់អំណាចរបស់ខ្មែរក្រហម ........ ៥

១.១.២ សោកនាដកម្មដែលប្រព្រឹត្តដោយខ្មែរក្រហម ........ ៦

១.១.៣ ការផ្តួលរលំរបបខ្មែរក្រហម ........ ៨

**១.២ ដំណើរការនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ........ ៩

១.២.១ សំណើរបស់រាជរដ្ឋាភិបាលកម្ពុជាជូនទៅអង្គការសហប្រជាជាតិ ........ ៩

១.២.២ ការចរចាដើម្បីឈានទៅរកកិច្ចព្រមព្រៀងរួម ........ ១១

១.២.៣ ការសម្រេចបាននូវលទ្ធផលជាវិជ្ជមាន ........ ១២

**១.៣ គោលដៅនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ........ ១៤

១.៣.១ ផ្តល់យុត្តិធម៌ជូនជនរងគ្រោះ ........ ១៤

១.៣.២ ការធានាឱ្យបាននូវសិទ្ធិរបស់ជនជាប់ចោទ ........ ១៥

១.៣.២.១ សិទ្ធិសេរីភាពក្នុងការជ្រើសរើសមេធាវី និងពេលវេលារៀបចំខ្លួន ................................... ១៦
១.៣.២.២ សិទ្ធិសន្មតគ្មានទោសរហូតដល់តុលាការផ្តន្ទាទោសជាស្ថាពរ ................................... ១៧
១.៣.២.៣ សិទ្ធិទទួលបានសវនាការ និងជាសាធារណៈ ................................... ១៧
១.៣.៣ ផលប្រយោជន៍សម្រាប់ប្រទេសកម្ពុជា ................................... ១៨

## ជំពូកទី២

## យុត្តាធិការអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**២.១ សមត្ថកិច្ចតុលាការតាមពេលវេលា** ................................... ២០
**២.២ សមត្ថកិច្ចតុលាការផ្អែកលើឋានៈបុគ្គល** ................................... ២១
២.២.១ មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ................................... ២១
២.២.១.១ តំណែងនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ................................... ២១
២.២.២.២ សិទ្ធិអំណាច និងសកម្មភាពនៅក្នុងមុខងារ ................................... ២២
២.២.២ ជនដែលទទួលខុសត្រូវខ្ពស់បំផុត ................................... ២៣
២.២.២.១ តំណែងនៅក្នុងស្ថាប័នសំខាន់ក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ................................... ២៤
២.២.២.២ សិទ្ធិអំណាច និងសកម្មភាពនៅក្នុងមុខងារ ................................... ២៤
**២.៣ សមត្ថកិច្ចតុលាការផ្អែកលើបទល្មើស** ................................... ២៥
២.៣.១ ឧក្រិដ្ឋកម្មសង្គ្រាម ................................... ២៦
២.៣.១.១ ជម្លោះប្រដាប់អាវុធ ................................... ២៧
២.៣.១.២ ទំនាក់ទំនងរវាងអំពើអមនុស្សធម៌របស់ចារី និងជម្លោះប្រដាប់អាវុធ ................................... ២៧
២.៣.១.៣ ការបំពានលើកម្មវត្ថុនៃការការពារក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ ................................... ២៨
២.៣.១.៤ ការយល់ដឹងរបស់ជនជាប់ចោទទាក់ទងនឹងជម្លោះប្រដាប់អាវុធ ................................... ៣០
២.៣.២ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ................................... ៣០
២.៣.២.១ ការវាយប្រហារ ................................... ៣០
២.៣.២.២ ទម្រង់នៃការវាយប្រហារ ................................... ៣១
២.៣.២.៣ ការវាយប្រហារសំដៅលើប្រជាជនស៊ីវិល ................................... ៣១
២.៣.២.៤ មូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ឬ សាសនា ................................... ៣២

២.៣.២.៥ ទំនាន់ទំនងរវាងអំពើរបស់ចារីនិងការវាយប្រហារ.................................................... ៣២

២.៣.២.៦ ការយល់ដឹងជាចាំបាច់របស់ជនជាប់ចោទអំពីការវាយប្រហារ.................................... ៣២

២.៣.៣ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ...................................................................................... ៣៣

២.២.៣.១ គោលដៅនៃការបំផ្លាញ ............................................................................................. ៣៣

២.៣.៣.២ ធាតុផ្សំសត្យានុម័តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ......................................................៣៤

២.៣.៣.៣ ធាតុអត្តនោម័តនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ......................................................៣៤

## ជំពូកទី៣

## ចំណាត់ការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើរឿងក្តីខ្មែរក្រហម

**៣.១ សំណុំរឿងលេខ ០០១ កាំង ហ្កេចអ៊ាវ ហៅ ឌុច**.......................................................៣៥

៣.១.១ ពិរុទ្ធភាពរបស់ជនជាប់ចោទដែល អ.វ.ត.ក បានរកឃើញ...................................................៣៥

៣.១.១.១ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តដោយ កាំង ហ្កេចអ៊ាវ .....................................៣៥

៣.១.១.២ ការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលប្រព្រឹត្តដោយ កាំង ហ្កេចអ៊ាវ ...................................................................................................................... ៣៧

៣.១.២ ការទទួលខុសត្រូវរបស់ជនជាប់ចោទ............................................................................ ៣៨

៣.១.៣ ការបដិសេធរបស់ជនជាប់ចោទចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌ ..................................៣៩

៣.១.៤ ជោគវាសនារបស់ កាំង ហ្កេចអ៊ាវ ................................................................................ ៤០

៣.១.៤.១ ការសម្រេចអំពីទណ្ឌកម្មក្នុងដំណាក់កាលអង្គជំនុំជម្រះសាលាដំបូង.............................. ៤០

៣.១.៤.២ ការសម្រេចចុងក្រោយអំពីទណ្ឌកម្មដោយអង្គជំនុំជម្រះតុលាការកំពូល.......................... ៤០

**៣.២.សំណុំរឿង ០០២/០១**.........................................................................................................៤១

៣.២.១ ពិរុទ្ធភាពរបស់ជនជាប់ចោទទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ.................................. ៤៤

៣.២.១.១ អំពើមនុស្សឃាត...................................................................................................... ៤៤

៣.២.១.២ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ............................................................ ៤៥

៣.២.១.៣ អំពើអមនុស្សធម៌ដទៃទៀត........................................................................................ ៤៥

៣.២.២ ការទទួលខុសត្រូវព្រហ្មទណ្ឌជាឯកត្តបុគ្គល ................................................................. ៤៦

៣.២.២.១ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា...................................................................៤៧

៣.២.២.២ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន ........ ៤៨
៣.២.៣ ការបដិសេធការទទួលខុសត្រូវព្រហ្មទណ្ឌរបស់សហជនជាប់ចោទ ........ ៤៩
៣.២.៤ ជោគវាសនារបស់សហជនជាប់ចោទ ........ ៥០
៣.២.៤.១ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ........ ៥០
៣.២.៤.២ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ........ ៥១
**៣.៣ សំណុំរឿង ០០២/០២** ........ ៥៣
៣.៣.១ ពិរុទ្ធភាពរបស់ជនជាប់ចោទទាក់ទងនឹងឧក្រិដ្ឋកម្ម ........ ៥៣
៣.៣.១.១ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ........ ៥៣
៣.៣.១.២ ការបំពានយ៉ាងធ្ងន់ធ្ងរទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ ........ ៥៨
៣.៣.១.៣ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ........ ៥៩
៣.៣.២ ការទទួលខុសត្រូវព្រហ្មទណ្ឌជាឯកត្តបុគ្គល ........ ៦០
៣.៣.២.១ ការទទួលខុសត្រូវរបស់ នួន ជា ........ ៦០
៣.៣.២.២ ការទទួលខុសត្រូវរបស់ ខៀវ សំផន ........ ៦១
៣.៣.៣ ជោគវាសនារបស់សហជនជាប់ចោទ ........ ៦១
៣.៣.៣.១ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ........ ៦១
៣.៣.៣.២ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ........ ៦៣
**៣.៤ ការសម្រេចអំពីផ្នែកសំណងរដ្ឋប្បវេណី** ........ ៦៥
៣.៤.១ សំណុំរឿងលេខ ០០១ ........ ៦៦
៣.៤.២ សំណុំរឿងលេខ ០០២/០១ ........ ៦៦
៣.៤.៣ សំណុំរឿងលេខ ០០២/០២ ........ ៦៨
**សេចក្តីសន្និដ្ឋាន** ........ ៧០
**អនុសាសន៍** ........ ៧១
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ឧក្រិដ្ឋកម្មដែលមានលក្ខណៈឃោរឃៅ ព្រៃផ្សៃ និងអមនុស្សធម៌ បានកើតឡើងមកលើមនុស្សជាតិជាច្រើនលើកច្រើនសារ។ ប្រវត្តិសាស្ត្រពិភពលោកបានបង្ហាញឱ្យឃើញអំពីសោកនាដកម្មដែលបង្កឡើងដោយអាល្លឺម៉ង់ និងអាណាចក្រជប៉ុន កាលពីសង្គ្រាមលោកលើកទី២ ឧក្រិដ្ឋកម្មដែលបានកើតឡើងនៅអតីតយូហ្គោស្លាវីកាលពីអំឡុងឆ្នាំ ១៩៩១ ក៏ដូចជាហេតុការណ៍នៅប្រទេសរវ៉ាន់ដានៅក្នុងឆ្នាំ ១៩៩៤ និងសង្គ្រាមស៊ីវិលនៅប្រទេសសៀរ៉ាឡេអូន ក្នុងចន្លោះឆ្នាំ ១៩៩១ ដល់ ២០០១។ ហេតុការណ៍ដែលបានរៀបរាប់ទាំងនេះ បានបង្កឱ្យកើតមាននូវបទល្មើសដែលពាក់ព័ន្ធទៅនឹង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលត្រូវបានចាត់ទុកជាអំពើប្រឆាំងទៅនឹងមនុស្សជាតិនៅទូទាំងសកលលោក។

ដើម្បីបញ្ចប់នូវវប្បធម៌និទណ្ឌភាព និងបង្កើនភាពសុខដុមរមនាសម្រាប់មនុស្សជាតិ សហគមន៍អន្តរជាតិបានធ្វើសកម្មភាពជាវិជ្ជមានក្នុងការឆ្លើយតបចំពោះអំពើអមនុស្សធម៌ តាមរយៈការបង្កើតនូវតុលាការអន្តរជាតិអចិន្ត្រៃយ៍ក្នុងគោលដៅស្វែងរកនូវយុត្តិធម៌ជូនជនរងគ្រោះ ដោយរកែមុខឧក្រិដ្ឋជន និងផ្តន្ទាទោសចំពោះអំពើដែលពួកគេបានប្រព្រឹត្ត។ ជាក់ស្តែង តុលាការយោធាអន្តរជាតិ (IMT) សាលាក្តីយោធាសម្រាប់ចុងបូព៌ា (IMTEF) តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (ICTR) តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន (SCSL) គឺជាយុត្តាធិការដែលលេចរូបរាងឡើងក្រោមការជំរុញពីមជ្ឈដ្ឋានអន្តរជាតិ ដើម្បីប្រឆាំងទៅនឹងឧក្រិដ្ឋជនដែលបង្កឱ្យមាននូវព្យសនកម្មយ៉ាងធ្ងន់ធ្ងរមកលើមនុស្សជាតិ។

កម្ពុជាក៏ត្រូវបានចាត់ទុកជាប្រទេសមួយក្នុងចំណោមប្រទេសដែលបានជួបប្រទះ នឹងឧក្រិដ្ឋកម្មយ៉ាងឃោរឃៅ និងមានលក្ខណៈព្រៃផ្សៃ ដោយហេតុថាវត្តមានរបស់ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[1] (ECCC) នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាពុំមែនជារឿងចៃដន្យនោះទេ ពោលគឺប្រទេសកម្ពុជាធ្លាប់បានធ្លាក់ចូលទៅក្នុងទំព័រប្រវត្តិសាស្ត្រដ៏អាក្រក់មួយ កាលពីអំឡុងពេលដែលប្រទេសស្ថិតក្រោមរបបកម្ពុជាប្រជាធិបតេយ្យ ដែលបង្កឱ្យប្រជាជនខ្មែរបានស្លាប់បាត់បង់ជីវិតប្រមាណជិត ២លាននាក់[2]។ បន្ទាប់ពីកម្ពុជាទទួលបាននូវស្ថិរភាពជាបណ្តើរៗ រាជរដ្ឋាភិបាលនៃអាណត្តិទី១ នៃព្រះរាជាណាចក្រកម្ពុជា បានស្វះស្វែងស្នើសុំទៅអង្គការ

[1] តទៅនេះ សូមហៅកាត់ថា អ.វ.ត.ក

[2] *Introduction Cambodia 1975-1979*, United States Holocaust Memorial Museum, https://www.ushmm.org/genocide-prevention/countries/cambodia/case-study/introduction/cambodia-1975. (ទស្សនាចុងក្រោយ ០៨/មេសា/២០២៣)

សហប្រជាជាតិឱ្យផ្តល់នូវមធ្យោបាយ ដើម្បីក្នុងការជម្រះបញ្ជីចំពោះហេតុការណ៍ដែលបានកើតឡើងកាលពីរបប កម្ពុជាប្រជាធិបតេយ្យ ដែលស្គាល់ថាជារបបខ្មែរក្រហម ក្នុងគោលបំណងស្វែងរកនូវយុត្តិធម៌ជូនប្រជាជាតិខ្មែរ។

ដូច្នេះ ប្រធានបទនេះនឹងសិក្សាស្រាវជ្រាវ ទៅលើដំណើរការស្វែងរកយុត្តិធម៌ដោយការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

## ២. ចំណោទបញ្ហា

ដោយហេតុថា អ.វ.ត.ក បានបិទបញ្ចប់កិច្ចនីតិវិធីជំនុំជម្រះជាស្ថាពរលើរឿងក្តីខ្មែរក្រហម ហេតុនេះហើយទើបមានទស្សនៈលើកឡើងថា៖

១- តើ អ.វ.ត.ក នឹងសម្រេចអំពីជោគវាសនារបស់ជនជាប់ចោទយ៉ាងដូចម្តេច?

២- តើ អ.វ.ត.ក ពិតបានផ្តល់នូវយុត្តិធម៌ចំពោះប្រជាជនខ្មែរដែរ ឬទេ?

## ៣. គោលបំណង

គោលបំណងនៃការសិក្សាលើប្រធានបទខាងលើនេះ គឺដើម្បីចែករំលែកនូវពុទ្ធិដល់និស្សិត និងអ្នកសិក្សាស្រាវជ្រាវឱ្យបានជ្រាបអំពី៖

- ហេតុការណ៍ជាប្រវត្តិសាស្ត្រនៃរបបកម្ពុជាប្រជាធិបតេយ្យដែលកម្ពុជាបានឆ្លងកាត់ ដែលក៏ជាមូលហេតុចម្បងដែលនាំឱ្យលេចវត្តមាន អ.វ.ត.ក
- កិច្ចចរចាដែលរាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងជាមួយនឹងអង្គការសហប្រជាជាតិ ដើម្បីទទួលបានជំនួយក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនកម្ពុជា
- យុត្តាធិការរបស់ អ.វ.ត.ក ដែលបានកំណត់ក្នុងកិច្ចព្រមព្រៀងអន្តរជាតិ ក៏ដូចជាច្បាប់ស្តីពីការបង្កើត អ.វ.ត.ក
- ជោគវាសនារបស់ជនជាប់ចោទ ក្រោយពីបិទបញ្ចប់ការវិនិច្ឆ័យសេចក្តីជាស្ថាពរ។

## ៤. ដែនកំណត់ និងវិសាលភាព

អ.វ.ត.ក បានបំពេញនូវកិច្ចនីតិវិធី និងសកម្មភាពជាច្រើន ជាហេតុធ្វើឱ្យមានវត្តមាននៃឯកសារជាច្រើនលានសន្លឹក បានបន្សល់ទុកសម្រាប់សិក្សាស្រាវជ្រាវ។ អាស្រ័យហេតុនេះ យើងខ្ញុំពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីសិក្សា និងពន្យល់ឱ្យបានលម្អិត និងក្បោះក្បាយលើគ្រប់ទិដ្ឋភាពបាននោះទេ។ ប៉ុន្តែ ប្រធានបទមួយនេះនឹងជួយដល់អ្នកអានឱ្យបានជ្រាបជាចំណេះដឹងមូលដ្ឋានដែលជាចំណុចសំខាន់ៗ ពាក់ព័ន្ធនឹង អ.វ.ត.ក។ សូមបញ្ជាក់ថាការសិក្សាស្រាវជ្រាវនេះ គឺផ្តោតទៅលើឯកសារដែលមានស្រាប់ ពោលគឺយើងខ្ញុំពុំបានធ្វើការសម្ភាស ឬ ពិភាក្សាជាមួយនឹងមន្ត្រីតុលាការ មេធាវី និងបុគ្គលដែលពាក់ព័ន្ធនៅក្នុងសំណុំរឿងនោះទេ។

រីឯនៅក្នុងជំពូកនៃចំណាត់ការរបស់តុលាការទៅលើសំណុំរឿងក្តីខ្មែរក្រហម យើងខ្ញុំនឹងសិក្សាដោយផ្តោតទៅលើសំណុំរឿងលេខ ០០១ ដែលពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ កាំង ហ្កេចអ៊ាវ ហៅ ឌុច និងសំណុំរឿងលេខ ០០២ ដែលមានជនជាប់ចោទឈ្មោះ ខៀវ សំផន និង នួន ជា។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

### ៥.១ ការប្រមូលទិន្នន័យ

ក្នុងការស្រាវជ្រាវលើប្រធានបទនេះ យើងខ្ញុំពឹងផ្អែកជាចម្បងទៅលើលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ សៀវភៅប្រវត្តិសាស្ត្រកម្ពុជា និងព័ត៌មានតាមគេហទំព័រផ្លូវការផ្សេងៗ ក៏ដូចជាស្វែងរកឯកសារទៅ តាមបណ្ណាល័យ និងចុះទៅទីតាំងដែលមានផ្ទុកនូវឯកសារ ឬ ទិន្នន័យដែលពាក់ព័ន្ធនឹង អ.វ.ត.ក មានដូចជា មជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[3] ហៅកាត់ថា «ម.ត.ឯ.ច» និងគេហទំព័ររបស់ អ.វ.ត.ក[4] ជាដើម។

បន្ថែមពីនេះ គឺស្នើសុំការណែនាំបន្ថែមពី សំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ដើម្បីផ្តល់ជាធាតុចូលពាក់ព័ន្ធនឹងបច្ចេកទេសផ្លូវច្បាប់ និងបកស្រាយពីព្រឹត្តការណ៍នានាដែលពាក់ព័ន្ធនឹង អ.វ.ត.ក ជាដើម។

### ៥.២ ការវាយតម្លៃទិន្នន័យ

ដោយសារតែប្រធានបទយើងខ្ញុំ មានចំណុចមួយចំនួនពាក់ព័ន្ធនឹងព្រឹត្តការណ៍ជាប្រវត្តិសាស្ត្រនាសម័យកម្ពុជាប្រជាធិបតេយ្យ ដូច្នេះតម្រូវឱ្យយើងខ្ញុំស្វែងរកសៀវភៅរបស់អ្នកនិពន្ធផ្សេងៗគ្នាមកសិក្សា និងវាយតម្លៃអំពីហេតុការណ៍ដែលកើតឡើង ដើម្បីធានាឱ្យបាននូវអព្យាក្រឹត្យភាព ភាពត្រឹមត្រូវ និងគណនេយ្យភាពនៃព្រឹត្តការណ៍ដែលបានកើតឡើងជាសក្ខានុម័តនាសម័យកាលនោះ។

ចំណែកឯ ចំណុចផ្សេងៗក្រៅពីប្រវត្តិសាស្ត្រ យើងខ្ញុំពឹងផ្អែកទៅលើលិខិតបទដ្ឋានគតិយុត្ត មានជាអាទិ៍ច្បាប់អន្តរជាតិ ច្បាប់ជាតិ ដែល អ.វ.ត.ក បានយកប្រើប្រាស់ក្នុងចំណាត់ការលើរឿងក្តីដែលស្ថិតក្រោមយុត្តាធិការរបស់ អ.វ.ត.ក។ល។ អ្វីដែលសំខាន់នោះ គឺសេចក្តីសម្រេចរបស់ អ.វ.ត.ក ដែលមានដូចជា សាលក្រម និងសាលដីកានៃសំណុំរឿងលេខ ០០១ និង០០២។

### ៥.៣ ការវិភាគទិន្នន័យ

ចំពោះការវិភាគទិន្នន័យ យើងខ្ញុំនឹងប្រើប្រាស់វិធីសាស្ត្រសិក្សាតាមបែបគុណវិស័យ (Qualitative) ដែលផ្តោតសំខាន់ទៅលើការពន្យល់អំពីភាពស្មុគស្មាញ និងវិភាគឱ្យបានស៊ីជម្រៅទៅលើខ្លឹមសារនៃបទបញ្ញត្តិ ក៏ដូចជា

[3] គេហទំព័រផ្លូវការរបស់ ម.ត.ឯ.ច https://www.ldc-eccc.gov.kh/index.php?pt&p=1

[4] គេហទំព័រផ្លូវការរបស់ អ.វ.ត.ក https://www.eccc.gov.kh/

ពន្យល់អំពីការបកស្រាយរបស់ អ.វ.ត.ក ឱ្យមកជាលក្ខណៈងាយស្រួលក្នុងការស្វែងយល់ ដោយរក្សាឱ្យបាននូវភាពត្រឹមត្រូវនៃខ្លឹមសារដើម។

## ៦. សារៈសំខាន់នៃការស្រាវជ្រាវ

ប្រធានបទនេះ នឹងចែករំលែកពុទ្ធិដល់បុគ្គលដែលមានបំណងចង់ស្វែងយល់អំពី អ.វ.ត.ក ពាក់ព័ន្ធនឹងការបង្កើត អ.វ.ត.ក យុត្តាធិការ អ.វ.ត.ក និងការកំណត់អំពីជោគវាសនារបស់ជនជាប់ចោទដោយការសម្រេចសេចក្តី។ បន្ថែមពីនេះ គឺការយល់ដឹងអំពីខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តដែលគ្រប់គ្រងដំណើរការប្រព្រឹត្តិទៅនៃតុលាការ។ លើសពីនេះ អ្នកអានអាចស្វែងយល់ត្រួតៗ អំពីព្រឹត្តិការណ៍ជាប្រវត្តិសាស្រ្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាសកម្មភាពរបស់រាជរដ្ឋាភិបាលក្នុងការបង្កើតសាលាក្តីនេះឡើងផងដែរ។

អ្វីដែលសំខាន់គឺយើងខ្ញុំ មានបំណងជំរុញឱ្យអ្នកសិក្សាស្រាវជ្រាវ ជាពិសេសនិស្សិតផ្នែកនីតិសាស្រ្តឱ្យផ្តោតការចាប់អារម្មណ៍មកលើ អ.វ.ត.ក ពាក់ព័ន្ធនឹងវិធីសាស្រ្តក្នុងការប្រើប្រាស់លិខិតបទដ្ឋានគតិយុត្ត ការបកស្រាយច្បាប់ ការធ្វើសំអាងហេតុមួយប្រកបដោយភាពច្បាស់លាស់ និងសកម្មភាពជាច្រើនទៀតដែលតុលាការនេះបានអនុវត្តនាពេលកន្លងមក ដើម្បីជាចំណេះដឹងក្នុងការពង្រឹងការអនុវត្តច្បាប់ក្នុងប្រព័ន្ធតុលាការកម្ពុជាឱ្យកាន់តែមានភាពប្រសើរឡើងថែមមួយកម្រិតទៀត។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

សារណានៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ នឹងបែងចែកជា ៣ ជំពូក ដូចខាងក្រោម៖

**ជំពូកទី ១៖ ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ដែលនៅក្នុងជំពូកនេះនឹងសិក្សាទៅលើមូលហេតុនៃការបង្កើតដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍ពីអតីតកាល ដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ, បេសសកម្មរបស់រាជរដ្ឋាភិបាលដើម្បីរៀបចំអង្គតុលាការនេះឡើង និងស្វែងយល់អំពីគោលដៅនៃការបង្កើតតុលាការនេះ។

**ជំពូកទី ២៖ យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** ដែលនៅក្នុងជំពូកនេះនឹងសិក្សាពាក់ព័ន្ធនឹងយុត្តាធិការរបស់តុលាការនេះ ថាតើ អ.វ.ត.ក ត្រូវបានកំណត់យុត្តាធិការក្នុងបេសសកម្មពាក់ព័ន្ធនឹងចំណុចអ្វីខ្លះ។

**ជំពូកទី ៣៖ ចំណាត់ការរបស់អង្គជំនុំជម្រះវិសាមញ្ញលើសំណុំរឿងខ្មែរក្រហម** ដែលនៅក្នុងជំពូកនេះនឹងបង្ហាញអំពីចំណាត់ការរបស់ អ.វ.ត.ក ក្នុងសំណុំរឿង ០០១ ពាក់ព័ន្ធនឹងជនជាប់ចោទ កាំង ហ្គេចអ៊ាវ និងសំណុំរឿង ០០២ ពាក់ព័ន្ធនឹងជនជាប់ចោទ នួន ជា និង ខៀវ សំផន។

# ជំពូកទី ១

# ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុង
# តុលាការកម្ពុជា

# ជំពូកទី ១ ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញតុលាការកម្ពុជា

អ.វ.ត.ក ឬ សាលាក្តីខ្មែរក្រហម បានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៧ ដែលជាតុលាការដ៏សំខាន់មួយ ដើម្បីស្វែងរកការពិត និងផ្តន្ទាទោសបុគ្គលដែលបង្កឱ្យកើតមាននូវឧក្រិដ្ឋកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ តាមរយៈព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រនៅចន្លោះឆ្នាំ ១៩៧៥ ដល់ ១៩៧៩ គឺជាបុព្វហេតុដែលធ្វើឱ្យសង្គមខ្មែរធ្លាក់ចូលទៅក្នុងអំពើអមនុស្សធម៌ និងធ្វើឱ្យប្រជាជនរស់រងទុក្ខវេទនាអស់រយៈពេល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ។ នេះគឺជាចំណុចចាប់ផ្តើមធំបំផុតដែលនាំឱ្យ អ.វ.ត.ក មានវត្តមាននៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា។

## ១.១ ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ

វត្តមាន អ.វ.ត.ក នៅកម្ពុជាមិនមែនជាសំណាងសម្រាប់ប្រជាជនកម្ពុជានោះទេ ប៉ុន្តែវាជាក្តីសង្ឃឹមសម្រាប់ប្រជាពលរដ្ឋកម្ពុជាក្នុងការទទួលបាននូវយុត្តិធម៌ មិនថាចំពោះជនរងគ្រោះដែលនៅរស់រានមានជីវិត ឬគ្រួសាររបស់ជនរងគ្រោះដែលបានស្លាប់នៅក្នុងរបបនោះទេ។ ក៏ព្រោះតែពួកគាត់បានឆ្លងកាត់នូវព្រឹត្តការណ៍ដ៏ខ្មៅងងឹតដែលបង្កឡើងដោយខ្មែរក្រហម ហេតុដូច្នេះជាមូលដ្ឋានគប្បីស្វែងយល់អំពី ការឡើងកាន់អំណាចរបស់ខ្មែរក្រហម អំពើឃោរឃៅដែលរបបនេះបង្កឡើង និងទីអវសាននៃរបបនេះ។

### ១.១.១ ការឡើងកាន់អំណាចរបស់ខ្មែរក្រហម

នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ លោកសេនាប្រមុខ លន់ នល់ និងរដ្ឋសភា បានសម្រេចធ្វើរដ្ឋប្រហារទម្លាក់សម្តេចព្រះ នរោត្តម សីហនុ ចេញពីតំណែងជាព្រះប្រមុខរដ្ឋ ដែលព្រឹត្តិការណ៍នេះគឺជាចំណុចនៃការចាប់ផ្តើមបើកឱ្យមាននូវសង្គ្រាមផ្ទុះឡើងនៅលើទឹកដីកម្ពុជាអស់រយៈពេលជាង ៣ទសវត្ស។ នៅចន្លោះខែមករា ដល់ខែមេសា ឆ្នាំ១៩៧៥ ចលនាខ្មែរក្រហម បានធ្វើសកម្មភាពឡោមព័ទ្ធទីក្រុងភ្នំពេញ និងបំផ្លិចបំផ្លាញផ្លូវដឹកជញ្ជូនស្បៀងមានដូចជា ផ្លូវទឹក ផ្លូវគោក និងផ្លូវដែក ជាមួយគ្នានេះ ក៏មានការបាញ់គ្រាប់មីស៊ីលចូលមកទីក្រុងភ្នំពេញផងដែរ។[5] ខ្មែរក្រហម គឺត្រូវបានឮជាលើកដំបូងតាមរយៈព្រះរាជបន្ទូលរបស់ សម្តេច ព្រះនរោត្តម សីហនុ ដែលទ្រង់ចង់សំដៅទៅលើក្រុមកុម្មុយនីស្តដែលប្រឆាំងនឹងព្រះអង្គនៅទសវត្សទី ៦០។[6]

កងទ័ពខ្មែរក្រហម បានវាយផ្តួលរលំរបបសាធារណរដ្ឋខ្មែរដឹកនាំដោយលោក លន់ នល់ បានដោយជោគជ័យនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលពួកខ្មែរក្រហមបានប្រកាសថាជាថ្ងៃដ៏មហាអស្ចារ្យ ក្រោយពីបានធ្វើសង្គ្រាមប្រមាណជា ៥ឆ្នាំ តទល់នឹងកងទ័ពរបស់សាធារណរដ្ឋខ្មែរ។ គួរបញ្ជាក់ផងដែរថា របបសាធារណរដ្ឋខ្មែរពិតជាមានការជួយជ្រោមជ្រែង និងពឹងផ្អែកមកលើសហរដ្ឋអាមេរិក ដែលជាហេតុបណ្តាលឱ្យរដ្ឋាភិបាលនៃ

[5] វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាភាគទី២*, បោះពុម្ពផ្សាយលើកទី ២, ទំព័រទី ៥៧។

[6] ឌី ខាំបូលី, *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*, បោះពុម្ពផ្សាយលើកទី ២, ទំព័រទី ១។

របបមួយនេះបានសម្តែងនូវការខកចិត្ត ក្រោយពីសហរដ្ឋអាមេរិកសម្រេចដើរចេញពីសង្គ្រាមនៅឥណ្ឌូចិន។[7] ការខកចិត្តនេះ បានរំលេចឡើងជាសត្យានុម័ត តាមរយៈអតីតឯកអគ្គរាជទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា លោក ចន ហ្គាន់ធី ឌីន (John Gunther Dean) ដែលលោកបានអាននូវខ្លឹមសារនៃលិខិតមួយចុះនៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ សរសេរដោយ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ ជូនចំពោះសហរដ្ឋអាមេរិក។[8]

ក្រោយពីការវាយផ្តួលរលំរបបសាធារណរដ្ឋខ្មែរបានសម្រេចដោយពួកខ្មែរក្រហមហើយ ប្រជាជនកម្ពុជាបានជួបប្រទះនូវទង្វើរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ដែលជាសោកនាដកម្មប្រព្រឹត្តដោយខ្មែរក្រហម។

### ១.១.២ សោកនាដកម្មដែលប្រព្រឹត្តដោយខ្មែរក្រហម

បន្ទាប់ពីខ្មែរក្រហមបានវាយចូលកាន់កាប់ទីក្រុងភ្នំពេញ ថ្នាក់ដឹកនាំ និងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរមួយចំនួន ត្រូវបានពួកខ្មែរក្រហមអូសយកទៅសម្លាប់ចោលភ្លាមៗ។ ទន្ទឹមនឹងនេះ ពួកខ្មែរក្រហមបានធ្វើសកម្មភាពជម្លៀសប្រជាជន ដោយការបង្ខិតបង្ខំឱ្យប្រជាជនទាំងអស់ ធ្វើដំណើរចាកចេញពីទីក្រុងភ្នំពេញជាបន្ទាន់ដោយពុំមានការលើកលែងជនណាម្នាក់ឡើយ សូម្បីតែអ្នកកំពុងសម្រាកព្យាបាលជំងឺក៏ត្រូវបានបណ្តេញចេញពីមន្ទីរពេទ្យផងដែរ ក្រោមហេតុផលថា ដើម្បីគេចចេញពីការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក។[9] មនុស្សរាប់ពាន់នាក់ ជាពិសេស កូនក្មេង ជនចាស់ជរា ស្ត្រីមានផ្ទៃពោះ និងអ្នកជំងឺ ត្រូវបានជម្លៀសចេញគ្មានសល់ ហើយអ្វីដែលសំខាន់គឺពួកខ្មែរក្រហមមិនអនុញ្ញាតឱ្យយកសូម្បីតែចំណីអាហារ បាយទឹក ទៅជាមួយ ហើយក៏ពុំមានការចែកអាហារហូបចុកជូនប្រជាជននោះទេ ដែលជាហេតុបង្កឱ្យមានមនុស្សជាច្រើនស្លាប់នៅតាមដងផ្លូវក្នុងអំឡុងពេលធ្វើដំណើរចាកចេញពីទីក្រុង។[10]

កម្ពុជាក្រោមការត្រួតត្រានៃរបបកម្ពុជាប្រជាធិបតេយ្យ បានបង្កឱ្យប្រជាជនខ្មែរបាត់បង់ជីវិតប្រមាណជិត ២លាននាក់ ដោយការកាប់សម្លាប់ ការធ្វើទារុណកម្ម បង្អត់អាហារ បង្ខំឱ្យធ្វើការហួសកម្លាំង កង្វះអនាម័យ និងជំងឺដង្កាត់គ្មានថ្នាំព្យាបាលជាដើម។ ប្រជាជនដែលត្រូវបានយកទៅសម្លាប់ និងចាប់ឃុំឃាំងធ្វើទារុណកម្ម ភាគច្រើនគឺក្រោមការចោទប្រកាន់ថាជាខ្មាំង ក្បត់បក្ស ជនបដិវត្តន៍ ឬ បុគ្គលដែលជាប់ការសង្ស័យថាមានគោលបំណងវាយរលំ ប៉ុល ពត។ របបនេះបានបង្កើតមន្ទីរសន្តិសុខ២១ ឬហៅកាត់ ស២១ ដែលជាកន្លែងសម្រាប់ការ

[7] ឥណ្ឌូចិន (Indochina) សំដៅលើ ០៣ប្រទេស មានដូចជា កម្ពុជា ឡាវ ថៃ។

[8] សូមភ្ជាប់ខ្លឹមសារនូវលិខិតរបស់ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ផ្ញើជូនលោក John Gunther Dean ឯកអគ្គរាជទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ចន្លោះឆ្នាំ ១៩៧៤ និង១៩៧៥។ មានជាមួយនៅក្នុងឧបសម្ព័ន្ធ

[9] អ.វ.ត.ក, *សហព្រះរាជអាជ្ញា តទល់នឹង ជនជាប់ចោទ នួន ជា និង ខៀវ សំផន*, សាលក្រមសំណុំរឿងលេខ ០០២/១៩ កញ្ញា ២០០៧/អវតក /អជសជ, E313, កថាខណ្ឌទី ១៥៣។ "ចាប់ពីនេះសូមហៅកាត់ថា សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313"

[10] លោក វ៉ាន់ឌី កាអុន, *ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាភាគទី២*, បោះពុម្ពផ្សាយលើកទី ២, ទំព័រ ៦៣។

ឃុំឃាំង ការសួរចម្លើយ ធ្វើទារុណកម្មយ៉ាងសាហាវព្រៃផ្សៃ និងចុងបញ្ចប់គឺសម្លាប់ចោលក្រោយពីបានបំពេញសំណុំឯកសារសារភាពចប់សព្វគ្រប់នៅឯវាលពិឃាតជើងឯក ឬ នៅក្នុងបរិវេណមន្ទីរស២១។[11]

យោងតាមមាត្រា ៩ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បានបញ្ញត្តិថា៖

> តុលាការជាតុលាការរបស់ប្រជាជន តំណាងយុត្តិធម៌របស់ប្រជាជន ការពារយុត្តិធម៌របស់ប្រជាជន ការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោសដល់គ្រប់សកម្មភាពដែលប្រឆាំងនឹងរដ្ឋរបស់ប្រជាជន ឬដែលល្មើសនឹងច្បាប់រដ្ឋរបស់ប្រជាជន។

ថ្វីត្បិតតែរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ មានចែងអំពីតុលាការដែលជាស្ថាប័នក្នុងការវិនិច្ឆ័យសេចក្តីលើសកម្មភាពល្មើស ការធានានូវយុត្តិធម៌ និងការពារសិទ្ធិសេរីភាពរបស់ប្រជាជនយ៉ាងណាក្តី ប៉ុន្តែជាក់ស្តែងរបបនេះពុំមានបង្កើតនូវតុលាការ ឬ ស្ថាប័នដែលមានយុត្តាធិការក្នុងការផ្តល់យុត្តិធម៌ និងធានាសិទ្ធិរបស់ប្រជាជនដូចមានចែងក្នុងរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់រដ្ឋនោះទេ។ ទង្វើនេះ គឺបង្ហាញពីភាពចន្លោះប្រហោងក្នុងការអនុវត្តច្បាប់តាមគោលការណ៍នីតិរដ្ឋ ដែលបណ្តាលឱ្យប្រជាជនជាច្រើនត្រូវបានខ្មែរក្រហមចោទថាជាខ្មាំង ហើយបានយកទៅសម្លាប់ចោលដោយពុំបានឆ្លងកាត់ដំណើរការវិនិច្ឆ័យសេចក្តីឱ្យឃើញអំពីកំហុស ឬ សកម្មភាពដែលពួកគេបានបំពានមុននឹងឈានដល់ការផ្តន្ទាទោសឡើយ។ ការចាប់ខ្លួន និងយកទៅសម្លាប់ចោលត្រូវបានពង្រីកវិសាលភាពតាមរយៈការអនុវត្តនូវគោលការណ៍របស់អង្គការគឺ "ដកស្មៅត្រូវដកទាំងឫស"[12] ដែលជាកត្តាជំរុញឱ្យមានព្យសនកម្មយ៉ាងធ្ងន់ធ្ងរដល់អាយុជីវិតរបស់ប្រជាជន។

មិនតែប៉ុណ្ណោះ បុគ្គលដែលប៉ះពាល់ទ្រព្យសម្បត្តិរួម មានជាអាទិ៍ ដំណាំ បន្លែ ផ្លែឈើ ត្រី សត្វ និងសម្បត្តិធម្មជាតិផ្សេងៗ ត្រូវបានខ្មែរក្រហមយកទៅអប់រំ ឬ ណែនាំឱ្យឈប់ប្រព្រឹត្តិអំពើខុសឆ្គង ឬ សម្លាប់ ដែលខ្មែរក្រហមប្រើប្រាស់ជំនួសដោយពាក្យថា "កសាង"[13]។ ដោយហេតុថា មធ្យោបាយផលិតកម្មសំខាន់ៗ ជាទូទៅគឺជាកម្មសិទ្ធិរួមរបស់រដ្ឋប្រជាជន និងកម្មសិទ្ធិរួមរបស់សមូហភាព រីឯរបស់របរប្រើប្រាស់ប្រចាំថ្ងៃស្ថិតនៅជាកម្មសិទ្ធិផ្ទាល់របស់ឯកជន[14] មានន័យថារបបកម្មសិទ្ធិឯកជនសឹងតែពុំមាននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ប្រជាជនជាច្រើនត្រូវបានរងគ្រោះដោយការល្មើសទៅនឹងច្បាប់នេះ ក៏ព្រោះតែពួកគាត់គ្មានជម្រើសអ្វីក្រៅពីបំពានដើម្បីរស់រានមានជីវិត ជាជាងការស្លាប់ដោយសារដាច់ពោះព្រោះគ្មានអាហារហូបចុកគ្រប់គ្រាន់។ កង្វះខាតនូវអនាម័យ គ្មាន

[11] អ.វ.ត.ក, *សហព្រះរាជអាជ្ញា តទល់នឹង ជនជាប់ចោទ កាំង ហ្គេចអ៊ាវ ហៅ ឌុច*, សាលក្រម, សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧/អវតក/អជសដ, E188, កថាខណ្ឌទី ១៨៤ និង ១៨៥។ "ចាប់ពីនេះសូមហៅកាត់ថា សាលក្រម ០០១ ឌុច, E188"

[12] ខ៊ី ខាំបូលី , *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*, បោះពុម្ពផ្សាយលើកទី ២, ទំព័រទី ៥៧។

[13] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ, មាត្រា ១០ កថាខណ្ឌទី២ ចែងថា "ចំពោះប្រភេទល្មើសក្រៅពីប្រភេទខាងលើត្រូវអប់រំកសាងក្នុងអង្គការរដ្ឋ ឬក្នុងក្របខណ្ឌអង្គការប្រជាជន"។

[14] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ, មាត្រា ២។

ថ្នាំសង្កូវក្នុងការព្យាបាល ការបង្ខំឱ្យធ្វើការហួសពីកម្លាំង ការហូបចុកមិនគ្រប់គ្រាន់ សុទ្ធតែជាកត្តាបង្កឱ្យមានការបាត់បង់អាយុជីវិតរបស់ប្រជាជនផងដែរ។

ក្រៅពីការបង្កសោកនាដកម្មនៅលើទឹកដីកម្ពុជា ក្រុមនេះក៏មានជម្លោះប្រដាប់អាវុធជាមួយនឹងខាងកងទ័ពវៀតណាម តាមរយៈការវាយចូលកាន់កាប់កោះត្រល់[15] ឬ ភូគុក (Phu Quoc) ការប៉ះទង្គិចនៅតាមព្រំដែនរវាងកម្ពុជា និងវៀតណាម ក៏ដូចជាការវាយប្រហារចូលក្នុងទឹកដីនៃប្រទេសវៀតណាម[16] ដែលក្នុងហេតុការណ៍នេះ ខ្មែរក្រហមបានបង្កឱ្យមានការខូចខាតផ្នែកសម្ភារៈ និងជាពិសេសគឺបានសម្លាប់ជនស៊ីវិលជាច្រើននាក់។ លើសពីនេះក៏មានដែលការបង្កទំនាស់ជាមួយនឹងប្រទេសថៃ ដែលក្រុមនេះបានចូលទៅកាប់សម្លាប់ប្រជាជន និងដុតបំផ្លាញផ្ទះសម្បែង ក្នុងភូមិមួយចំនួននៃប្រទេសថៃផងដែរ។[17]

## **១.១.៣ ការដួលរលំរបបខ្មែរក្រហម**

របបកម្ពុជាប្រជាធិបតេយ្យគ្រប់គ្រងប្រទេសបានត្រឹមតែរយៈពេល ៣ឆ្នាំ ៨ខែ និង២០ថ្ងៃ ដែលចាត់ទុកជារបបដែលដឹកនាំប្រទេសបានរយៈពេលខ្លីបំផុតក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា។ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ ១៩៧៩ របបខ្មែរក្រហមត្រូវបានអ្នកតស៊ូខ្មែរ ដោយមានការជួយជ្រោមជ្រែងពីកងទ័ពវៀតណាមវាយរំលំដើម្បីរំដោះប្រជាជនខ្មែរចេញពីសោកនាដកម្មដែលបង្កឡើងដោយរបប ប៉ុល ពត។

ការបែកបាក់ផ្ទៃក្នុង និងការប៉ះទង្គិចជាមួយនឹងប្រទេសវៀតណាម គឺជាមូលហេតុដ៏ចម្បងដែលបណ្តាលឱ្យរបបកម្ពុជាប្រជាធិបតេយ្យពុំអាចបន្តការគ្រប់គ្រងប្រទេសកម្ពុជា។ ការបែកបាក់ផ្ទៃក្នុង ស្តែងក្រោមរូបភាពនៃការបោសសម្អាតជនក្បត់ដែល ប៉ុល ពត ជឿជាក់ថាកំពុងតែបង្កប់នៅក្នុងជួរបក្ស ពោលគឺចាប់ពីឆ្នាំ ១៩៧៦ មកមានការចាប់ខ្លួន កម្មាភិបាលជាន់ខ្ពស់ គណៈភូមិភាគ គណៈតំបន់ មេបញ្ជាការកងទ័ព ជាច្រើនយកមកសួរចម្លើយ និងសម្លាប់ចោល។[18] តួយ៉ាងមានដូចជា កុយ ធួន ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ ចាន់ ចក្រី លេខាតំបន់២៤នៃភូមិភាគបូព៌ា ម៉ែន សាន លេខាភូមិភាគពៀសាន សួស នៅ ហៅ ឈូក អនុប្រធានសេនាធិការ វន វ៉េត ហៅ ពេញ ធួក សមាជិកគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ឆាយ គីមហ៊ែរ ហៅ ហុក ប្រធានគណៈកម្មធិការថាមពល គង់ សុផល លេខាភូមិភាគពាយ័ព្យ សួ សុផាន ហៅ ប៉ង់

[15] សាលក្រម ០០១ ឧច, E188, កថាខណ្ឌទី ៦៦។

[16] ពុយ គា, *រដ្ឋាភិបាលកម្ពុជាពីឆ្នាំ ១៩៤៥ ដល់ ឆ្នាំ ២០១០*, បោះពុម្ពលើកទី២, ទំព័រ ១១៩ និង ១២២។ "កងទ័ពខ្មែរក្រហមបានលុកលុយជាលើកដំបូងចូលទីក្រុងវៀតណាមដូចជា ចូវដុក និងហាទៀន នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧៧ និងលុកលុយក្នុងទឹកដីវៀតណាមជាលើកទី ២ នៅថ្ងៃទី២៤-៣០ ខែកញ្ញា ឆ្នាំ១៩៧៧ មានលក្ខណៈទ្រង់ទ្រាយធំ ដែលបណ្តាលឱ្យជនស៊ីវិលវៀតណាមចំនួន ១០០០ នាក់ត្រូវស្លាប់ និងរបួស"។

[17] ប្រភពដូចខាងលើ, ទំព័រ ១១៩។

[18] ឌី ខាំបូលី , *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*, បោះពុម្ពផ្សាយលើកទី ២, ទំព័រទី ៧៣។

សមាជិកគណៈកម្មាធិការថាមពល សួ សុផាន ហៅ ប៉ង់ សមាជិកគណៈកម្មាធិការមជ្ឈិម និង អ៊ិន លន ហៅ ណាត អតីតប្រធានមន្ទីរស២១។[19] ហេតុការណ៍នេះបានបណ្តាលឱ្យពួកខ្មែរក្រហមដែលមាននិន្នាការប្រឆាំងនឹងការដឹកនាំរបស់ ប៉ុល ពត និងប្រជាជនផ្សេងទៀត ប្រមូលផ្តុំគ្នាបង្កើតកងកម្លាំងមួយក្រុមហៅថា រណសិរ្សសង្គ្រោះជាតិកម្ពុជា នៅថ្ងៃទី០២ ខែធ្នូ ឆ្នាំ១៩៧៨ ក្រោមជំនួយពីកងទ័ពវៀតណាម ដើម្បីរំដោះប្រទេសចេញពីរបបដ៏ឃោរឃៅនេះ។

ថ្វីត្បិតតែពួកខ្មែរក្រហម ត្រូវបានវាយចេញពីតួនាទីក្នុងការដឹកនាំប្រទេសកម្ពុជា នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ក៏ពិតមែន ប៉ុន្តែវត្តមាននៃក្រុមនេះនៅតែបន្តឈរជើងនៅលើដែនដីមួយចំនួននៃប្រទេសកម្ពុជា ខាងផ្នែកពាយ័ព្យ ជាប់ព្រំដែនថៃ ជាពិសេសគឺនៅស្រុកអន្លង់វែង ស្ថិតក្នុងខេត្តឧត្តរមានជ័យ ដែលជាទីកន្លែងប្រមូលផ្តុំកម្មាភិបាលខ្មែរក្រហម បន្ទាប់ពីឆ្នាំ១៩៧៥ ហើយក៏ជាតំបន់តស៊ូចុងក្រោយរបស់កងកម្លាំងខ្មែរក្រហមផងដែរ។ វត្តមាននៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសអំពីបញ្ហាខ្មែរ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ១៩៩១ និងការបោះឆ្នោតដែលរៀបចំឡើងដោយអ៊ុនតាក់ក្នុងឆ្នាំ ១៩៩៣ ពុំបានបញ្ចប់នូវអធិករណ៍រវាងខ្មែរ និងខ្មែរ បាននោះទេ។ ផ្ទុយទៅវិញ នៅក្នុងឆ្នាំ ១៩៩៤ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានដាក់ចេញនូវគោលនយោបាយ ឈ្នះ-ឈ្នះ ដែលមានគោលដៅរំលាយអង្គការរបស់ខ្មែរក្រហម និងនាំមកនូវសន្តិភាពយូរអង្វែងសម្រាប់កម្ពុជា។[20] ជាលទ្ធផល នៅក្នុងឆ្នាំ១៩៩៨ គោលនយោបាយនេះបានធ្វើឱ្យចលនាខ្មែរក្រហមរលំរលាយជាស្ថាពរ ហើយដែលនាំឱ្យកម្ពុជាបានស្គាល់នូវឯកភាពជាតិ សន្តិភាព និងបិទបញ្ចប់នូវជម្លោះដ៏រ៉ាំរ៉ៃរវាងខ្មែរ និងខ្មែរ ដែលបានប្រឈមមុខដាក់គ្នាអស់ប្រមាណជា ៣ ទសវត្ស។

## ១.២ ដំណើរការនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ក្រោយពីស្ថានភាពនៅកម្ពុជាមានលក្ខណៈធូរស្រាលបន្តិច រាជរដ្ឋាភិបាលអាណត្តិទី១ នៃរបបព្រះរាជាណាចក្រកម្ពុជាទី២ បានទទូចឱ្យសហគមន៍អន្តរជាតិផ្តល់ជាជំនួយដើម្បីស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនខ្មែរ។ មុននឹងឈានដល់ការបង្កើតនូវតុលាការនេះ រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងជាមួយនឹងអង្គការសហប្រជាជាតិ អស់ប្រមាណជាងមួយទសវត្ស។

### ១.២.១ សំណើរបស់រាជរដ្ឋាភិបាលកម្ពុជាជូនទៅអង្គការសហប្រជាជាតិ

កម្ពុជាបានទទួលរងនូវផលវិបាកយ៉ាងធ្ងន់ធ្ងរដែលកើតចេញពីសង្គ្រាមដ៏រ៉ាំរ៉ៃ ជាហេតុបណ្តាលឱ្យមានកង្វះខាតលើ ផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស។ កត្តានេះ គឺជាចំណុចប្រឈមដែលនឹងនាំឱ្យមានផលប៉ះពាល់ដល់កិច្ចដំណើរការនីតិវិធីលើការកាត់សេចក្តីចំពោះឧក្រិដ្ឋកម្ម ដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

[19] សាលក្រម ០០១ ឌុច, E188, កថាខណ្ឌទី ២១១-២១៣។

[20] ឯកឧត្តម នាយឧត្តមសេនីយ៍ ប៉ុល សារឿន, *យុទ្ធសាស្ត្រឈ្នះឈ្នះតេជោសែននៃកម្ពុជា*, ទំព័រទី៩។

។[21] នៅក្នុងឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើសំណើទៅកាន់អគ្គលេខាធិការអង្គការសហប្រជាជាតិដើម្បីស្នើសុំជំនួយពីមជ្ឍដ្ឋានអន្តរជាតិ ដើម្បីកាត់ទោសលើជនដែលបានបង្កឱ្យមានអំពើរំលោភបំពានសិទ្ធិមនុស្សយ៉ាងធ្ងន់ធ្ងរ ក្នុងពេលដែលកម្ពុជាស្ថិតក្រោមការដឹកនាំរបស់ ប៉ុល ពត។ ស្របពេលជាមួយគ្នានេះ គណៈកម្មាធិការសិទ្ធិមនុស្សក៏បានលើកសំណើទៅកាន់អង្គសហប្រជាជាតិ ដើម្បីឱ្យអង្គការនេះផ្តល់ជាមធ្យោបាយសមរម្យដល់កម្ពុជា ក្នុងគោលដៅផ្សះផ្សារជាតិ ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការដោះស្រាយបញ្ហាគណនេយ្យភាពបុគ្គលនៅកម្ពុជា។[22]

មហាសន្និបាតអង្គការសហប្រជាជាតិ បានស្នើទៅអគ្គលេខាអង្គការសហប្រជាជាតិ ឱ្យធ្វើការត្រួតពិនិត្យលើសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា និងសុំឱ្យចាត់តាំងអ្នកជំនាញចុះមកសិក្សាអំពីស្ថានភាពនៅកម្ពុជា។ ជាលទ្ធផលក្រុមអ្នកជំនាញបីរូប ត្រូវបានចាត់តាំងដើម្បីបើកការស៊ើបអង្កេតនៅលើទឹកដីកម្ពុជា ក្នុងគោលដៅកំណត់នូវប្រភេទនៃឧក្រិដ្ឋកម្មដោយផ្អែកទៅលើភស្តុតាងដែលបានបន្សល់ទុក ពាក់ព័ន្ធនឹងការឃុំខ្លួនបុគ្គលដែលមានតម្រុយពិរុទ្ធភាព និងការធ្វើបត្យាប័នដើម្បីនាំយកបុគ្គលដែលមានតម្រុយពិរុទ្ធភាព មកកាត់ទោសដោយពិភាក្សាអំពីជម្រើសថាតើគួរប្រគល់សមត្ថកិច្ចជូនតុលាការអន្តរជាតិ ឬតុលាការជាតិ។[23]

របាយការណ៍របស់ក្រុមអ្នកជំនាញ បានរកឃើញនូវសកម្មភាពអមនុស្សធម៌ដែលកើតមានឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យមានដូចជា[24]៖

- ការបង្ខំឱ្យប្រជាជនចេញពីទីក្រុង
- ការបង្ខំឱ្យធ្វើការលើសកម្លាំងពលកម្ម និងការរស់នៅក្នុងលក្ខខណ្ឌមិនសមរម្យ
- ការវាយប្រហារលើសត្រូវបដិវត្តន៍ ឬ ជនដែលត្រូវបានចាត់ទុកថាជាខ្មាំង
- ការបោសសម្អាតផ្ទៃក្នុងបក្សកុម្មុយនីស្តកម្ពុជា។

---

[21] UNITED NATION(UN), A/51/930, S/1997/488, *Letter dated 21 June 1997 from the First and Second Prime Ministers of Cambodia addressed to the secretary-general (លិខិតរបស់សហនាយករដ្ឋមន្ត្រីទី១ និងទី២ នៃព្រះរាជាណាចក្រកម្ពុជា ផ្ញើជូនអគ្គលេខាធិការអង្គការសហប្រជាជាតិ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧)*។

[22] Commission on Human Rights (C.H.R), res.1997/49, Situation of human rights in Cambodia *(ស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា)*, ១១/មេសា/១៩៩៧, កថាខណ្ឌទី ១២។

[23] UN, A/RES/52/135, RESOLUTION ADOPTED BY THE GERNERAL ASSEMBLY, [*on the report of the Third Committee* (A/52/644/add.2.)], res.52/135, *Situation of human rights in Cambodia*, ២៧/កុម្ភៈ/១៩៩៨, កថាខណ្ឌទី១៥។

[24] UN, A/53/850, S/1999/231, The report of the group of experts for Cambodia established pursuant to General Assembly resolution 52/135 (របាយការណ៍របស់ក្រុមអ្នកជំនាញអង្គការសហប្រជាជាតិ ដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥២/១៣៥), ទំព័រទី ៩-១២, កថាខណ្ឌទី ១៩-៣១។

ជាកិច្ចបញ្ចប់ ក្រុមអ្នកជំនាញក៏ផ្តល់យោបល់ឱ្យបង្កើតតុលាការពិសេសអន្តរជាតិដើម្បីដោះស្រាយលើរឿងក្តីខ្មែរក្រហម (Ad Hoc International Tribunal)។[25]

### ១.២.២ ការចរចាដើម្បីឈានទៅរកកិច្ចព្រមព្រៀងរួម

ជំនួបរវាងអគ្គលេខាធិការអង្គការសហប្រជាជាតិ ជាមួយនឹងអ្នកតំណាងរបស់កម្ពុជាបានប្រព្រឹត្តទៅនៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៩ ដែលកម្ពុជាបានបង្ហាញអំពីគោលជំហរចំពោះការកាត់ទោសខ្មែរក្រហម ដោយគិតគូរអំពីសន្តិភាព និងការបង្រួបបង្រួមជាតិជាលក្ខខណ្ឌចម្បង។ បន្ថែមពីនេះកម្ពុជាបញ្ជាក់ថា វាជារឿងដ៏សមហេតុសមផល និងត្រឹមត្រូវបំផុតដែលតុលាការកម្ពុជាមានសមត្ថកិច្ចក្នុងដំណើរការវិនិច្ឆ័យសេចក្តី ដោយហេតុថាសោកនាដកម្មបានកើតឡើងនៅលើទឹកដីកម្ពុជា ជនរងគ្រោះក៏ជាប្រជាជនកម្ពុជា ហើយបុគ្គលដែលបង្កក៏ជាប្រជាជនកម្ពុជា។ ទន្ទឹមនឹងនេះ កម្ពុជាបានសុំការជួយជ្រំជ្រែងពីអង្គការសហប្រជាជាតិឱ្យផ្តល់អ្នកជំនាញ ដើម្បីជាកិច្ចជំនួយដល់ការធ្វើសេចក្តីព្រាងច្បាប់ក្នុងការបង្កើតតុលាការពិសេសមួយនៅកម្ពុជា។ ជាពិសេស ដើម្បីឱ្យកិច្ចដំណើរការនៃប្រព័ន្ធយុត្តិធម៌កាន់តែមានភាពត្រឹមត្រូវ កម្ពុជាក៏បានស្នើសុំឱ្យមាននូវវត្តមានចៅក្រម និងព្រះរាជអាជ្ញាអន្តរជាតិដើម្បីចូលរួមដំណើរការវិនិច្ឆ័យសេចក្តីផងដែរ។ ភាគីបានពិភាក្សាគ្នា ដើម្បីកំណត់នូវ មុខងាររចនាសម្ព័ន្ធ និងសមត្ថកិច្ចនៃសាលាជម្រះក្តី។[26]

នៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០០ អង្គការសហប្រជាជាតិ បានសម្រេចអំពីការបង្កើតឱ្យមាននៅតុលាការថ្មីមួយនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីកាត់ទោសលើជនដែលបានបង្កឱ្យមាននូវសកម្មភាពរំលោភបំពានសិទ្ធិមនុស្សនៅកម្ពុជា។ បន្ថែមពីនេះ អង្គការសហប្រជាជាតិបានទទួចឱ្យរាជរដ្ឋាភិបាលកម្ពុជាធានា និងសម្របសម្រួល ដើម្បីពន្លឿននីតិវិធីក្នុងដំណើរការកាត់ទោសដោយគោរពតាមស្តង់ដារអន្តរជាតិ ប្រកបដោយយុត្តិធម៌ និងភាពត្រឹមត្រូវតាមច្បាប់។ ច្បាប់ស្តីពី "ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ" ត្រូវបានរដ្ឋសភាកម្ពុជាអនុម័ត និងប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ នៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១។

កិច្ចចរចានេះនៅមិនទាន់បញ្ចប់ទាំងស្រុងនោះទេ ព្រោះថាអគ្គលេខាធិការអង្គការសហប្រជាជាតិលោកកូហ្វី អាណាន់ (Kofi Annan) បានអស់អាណត្តិបំពេញតួនាទីក្នុងនាមជាអ្នកចរចា ជាហេតុតម្រូវឱ្យមានការពន្យា

[25] UN, A/53/850, S/1999/231*, Identical letters dated 15 March 1999 from the Secretary-General to the president of the General Assembly and the President of the Security Council (លិខិតចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ របស់អគ្គលេខាធិការអង្គការសហប្រជាជាតិផ្ញើជូនមហាសន្និបាតអង្គការសហប្រជាជាតិនិងអគ្គលេខាធិការនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ)*។

[26] UN, A/57/769, *Report of the Secretary-General on Khmer Rouge Trials (របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីអំពីសាលាក្តីខ្មែរក្រហម),* ៣១/មីនា/២០០៣។

ពេលរង់ចាំសេចក្តីសម្រេចពីមហាសន្និបាត និងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដើម្បីផ្តល់អាណត្តិថ្មីក្នុងការបន្តកិច្ចចរចាជាមួយកម្ពុជា។ កិច្ចចរចាត្រូវបានបន្តដោយចែកចេញជាពីរដំណាក់កាល ក្រោយពីលោក កូហ្វី អាណាន់ (Kofi Annan) ទទួលបានអាណត្តិបន្ត។[27] ដំណាក់កាលទី១ គឺកិច្ចចរចាដែលធ្វើឡើងនៅទីក្រុងញ៉ូវយក នៅក្នុងខែមករា ឆ្នាំ២០០៣ ដោយមានការចូលរួមពី ឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងក្រុមការងារអង្គការសហប្រជាជាតិ ដឹកនាំដោយ លោក ហាន ខូរ៉ែល (Hans Corell) អគ្គលេខាធិការរងទទួលបន្ទុកកិច្ចការច្បាប់ និងប្រឹក្សាផ្នែកច្បាប់។ កិច្ចចរចានេះ មានគោលបំណងគឺដើម្បីស្វែងរកចំណុចរួមជាមូលដ្ឋាន ដើម្បីដោះស្រាយលើបញ្ហាដែលកើតឡើង។ ដំណាក់កាលទី២ គឺការចរចាធ្វើឡើងនៅទីក្រុងភ្នំពេញ នៅក្នុងខែមីនា ឆ្នាំ២០០៣ ដោយជំនួបពិភាក្សានេះ ជាលទ្ធផលនាំឱ្យឈានដល់កិច្ចព្រមព្រៀងរួមគ្នាមួយ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា។

### ១.២.៣ ការសម្រេចបាននូវលទ្ធផលជាវិជ្ជមាន

មហាសន្និបាតអង្គការសហប្រជាជាតិ បានអនុម័តលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់មក កិច្ចព្រមព្រៀងនេះត្រូវបានអនុម័តនៅទីក្រុងភ្នំពេញ នៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣។

ការកំណត់ អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបំពានលើច្បាប់ជាតិ និងលិខិតបទដ្ឋានអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៥ គឺជាកម្មវត្ថុចម្បងនៃកិច្ចព្រមព្រៀងនេះ។[28] តាមរយៈមាត្រា២ នៃកិច្ចព្រមព្រៀង បានទទួលស្គាល់យុត្តាធិការអង្គជំនុំជម្រះវិសាមញ្ញ ដូចបានមានចែងនៅក្នុង "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា"[29] និងអាចអនុវត្តបាននៅកម្ពុជាក្រោយពេលច្បាប់នេះត្រូវបានអនុម័ត និងបានធ្វើវិសោធនកម្មរួចរាល់។ ពាក់ព័ន្ធនឹងដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ គឺត្រូវសមស្របជាមួយនឹងច្បាប់កម្ពុជា លើកលែងតែក្នុងករណីដែលច្បាប់កម្ពុជាមិនអាចដោះស្រាយបាន ឬនិយាយម្យ៉ាងទៀងថាអវត្តមាននូវច្បាប់កម្ពុជា ដូច្នេះករណីនេះអង្គជំនុំជម្រះអាចប្រើប្រាស់បទដ្ឋាន

[27] UN, A/57/76, *Report of the Secretary-General on Khmer Rouge Trials (របាយការណ៍របស់អគ្គលេខាធិការអង្គការសហ ប្រជាជាតិស្តីអំពីសាលាក្តីខ្មែរក្រហម)*, ៣១/មីនា/២០០៣, កថាខណ្ឌទី ៨-៣០។

[28] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តិឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, ថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣, មាត្រា១។ (តទៅសូមហៅកាត់ថា កិច្ចព្រមព្រៀង អ.ស .ប និង កម្ពុជា)។

[29] តទៅសូមហៅកាត់ថា ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

នីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិបាន។[30] បន្ថែមពីនេះ ក៏ព្រោះតែរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ មិនទទួលស្គាល់នូវទោសប្រហារជីវិត ហេតុដូចនេះទោសអតិបរមាគឺកម្រិតត្រឹមតែដាក់ពន្ធនាគារអស់មួយជីវិតប៉ុណ្ណោះ។[31]

សមាសភាព ចៅក្រម ចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញា ក៏ជាចំណុចដែលគួរឱ្យកត់សម្គាល់ផងដែរ ក៏ព្រោះតែតុលាការនេះគឺជាប្រភេទតុលាការកូនកាត់ (Hybrid Court) ដែលពុំធ្លាប់មានពីមុនមកពោលគឺកិច្ចនីតិវិធីតាំងពីដំណាក់កាលចោទប្រកាន់ ស៊ើបអង្កេត និងជំនុំជម្រះ មានសមាសភាពថ្នាក់ជាតិ និងអន្តរជាតិ ក្នុងការសម្រេចសេចក្តី។ អាស្រ័យហេតុនេះ ដើម្បីធានាឱ្យបាននូវកិច្ចដំណើរការនីតិវិធីប្រកបដោយភាពរលូន ភាគីបានព្រមព្រៀងគ្នាលើវិធានការដោះស្រាយក្នុងករណីមានការខ្វែងយោបល់គ្នារវាង សហចៅក្រមស៊ើបអង្កេត ឬ សហព្រះរាជអាជ្ញា ដែលមានអង្គបុរេជំនុំជម្រះទទួលបន្ទុកក្នុងការដោះស្រាយលើបញ្ហាវិវាទ។[32]

មិនតែប៉ុណ្ណោះ រដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ បានផ្តល់ព្រះរាជសិទ្ធិថ្វាយព្រះមហាក្សត្រក្នុងការបន្ធូរបន្ថយទោស និងលើកលែងទោស។[33] ទោះបីជាយ៉ាងនេះក្តី ផ្អែកតាមមាត្រា ១១ កថាខណ្ឌទី១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាល ភាគីបានព្រមព្រៀងគ្នាថា៖

> រាជរដ្ឋាភិបាលកម្ពុជា នឹងមិនស្នើសុំឱ្យមានការលើកលែងទោស ឬ អនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចនឹងត្រូវស៊ើបអង្កេត ឬ នឹងត្រូវផ្តន្ទាទោសអំពីឧក្រិដ្ឋកម្ម ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះទេ។

នេះបង្ហាញអំពីភាពត្រឹមត្រូវក្នុងដំណើរការស្វែងរកយុត្តិធម៌ ក៏ព្រោះតែ អ.វ.ត.ក នឹងចំណាយធនធាន ពេលវេលា និងកម្លាំងឥតប្រយោជន៍ ប្រសិនបើជនទាំងនោះអាចទទួលបានការអនុគ្រោះទោស ឬ លើកលែងទោសនៅក្នុងដំណើរការ ឬ ក្រោយបញ្ចប់នីតិវិធី។ ប៉ុន្តែដោយហេតុថា ក្នុងឆ្នាំ១៩៩៦ អៀង សារី ត្រូវបានព្រះមហាក្សត្រ នរោត្តម សីហនុ ចេញព្រះរាជក្រឹត្យឱ្យរួចផុតពីការផ្តន្ទាទោសតាមអំណាចនៃសាលក្រមរបស់តុលាការប្រជាជនបដិវត្តន៍ក្រុងភ្នំពេញ ចុះថ្ងៃទី១៩ ខែ សីហា ឆ្នាំ១៩៧៩ និងចំពោះទោសដែលបានកំណត់ដោយច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់។[34] ចំពោះករណីនេះ ភាគីបានឯកភាពគ្នាផ្តល់សមត្ថកិច្ចជូន អ.វ.ត.ក ក្នុងការវិនិច្ឆ័យ និងសម្រេចអំពីការលើកលែងទោសចំពោះតែជននេះម្នាក់ប៉ុណ្ណោះ។

---

[30] កិច្ចព្រមព្រៀង អ.ស.ប និងកម្ពុជា, មាត្រា១២។

[31] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា៣២ កថាខណ្ឌទី២។

[32] កិច្ចព្រមព្រៀង អ.ស.ប និងកម្ពុជា, មាត្រា៣ មាត្រា៥ មាត្រា៧។

[33] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា២៧។

[34] ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់, មាត្រា១។

លើសពីនេះ ដើម្បីធានាបាននូវស្មារតីនៃការព្រមព្រៀងគ្នា ការធ្វើវិសោធនកម្មនានា ទាក់ទងនឹងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នេះ ភាគីត្រូវជាប់កាតព្វកិច្ចក្នុងការពិគ្រោះយោបល់ជាមួយភាគីម្ខាងទៀតនៃកិច្ចព្រមព្រៀង ក្នុងករណីដែលមានបំណងចង់កែប្រែ លុបចោល ឬបន្ថែមនូវខ្លឹមសារ។[35] ចំពោះការចំណាយរបស់អង្គជំនុំជម្រះ គឺត្រូវទ្រទ្រង់ដោយប្រទេសក្នុងសមាគមន៍អន្តរជាតិ តាមរយៈការចូលរួមចំណែកដោយស្ម័គ្រចិត្ត និងតាមការអំពាវនាវ។

ជាលទ្ធផល ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដែលប្រកាសឱ្យប្រើក្នុងឆ្នាំ២០០១ ត្រូវបានកម្ពុជាធ្វើវិសោធនកម្មដើម្បីឱ្យស្របទៅតាមខ្លឹមសារដែលរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានឯកភាពគ្នាតាមកិច្ចព្រមព្រៀង ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣។ បន្ទាប់មកច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រម នស/រកស/១០០៤/០០៦។ ជាចុងក្រោយ អ.វ.ត.ក ចាប់ផ្តើមបើកបេសកកម្មនៅលើទឹកដីកម្ពុជា បន្ទាប់ពីចៅក្រម ព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ រួមជាមួយនឹងមន្ត្រីតុលាការបានធ្វើពិធីស្បថចូលកាន់តំណែងក្នុងនៅថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៦។

## ១.៣ គោលដៅនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ការធានាឱ្យបាននូវស្តង់ដាយុត្តិធម៌ជាលក្ខណៈអន្តរជាតិដល់ភាគីពាក់ព័ន្ធ គឺជាគោលដៅចម្បងនៃការបង្កើតសាលាក្តីខ្មែរក្រហម។ ហេតុនេះហើយបានជា អ.វ.ត.ក បានប្រើប្រាស់វិធានច្បាប់ជាតិ និងអន្តរជាតិ មានដូចជា រដ្ឋធម្មនុញ្ញកម្ពុជាដែលជាច្បាប់កំពូល កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស (UDHR) និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដើម្បីជាមូលដ្ឋានផ្តល់ជូនគ្រប់ភាគីក្នុងការអនុវត្តសិទ្ធិស្របតាមលិខិតបទដ្ឋានគតិយុត្តទាំងនេះ។

### ១.៣.១ ផ្តល់យុត្តិធម៌ជូនជនរងគ្រោះ

អវត្តមាននៃការគោរពសិទ្ធិមនុស្ស ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានធ្វើឱ្យប្រជាជនខ្មែរប្រមាណ ១,៧ លាននាក់ត្រូវបាត់បង់ជីវិត និងក្រៅពីនេះគឺរស់នៅរងទុកវេទនា ដោយសារការបាត់ បង់សិទ្ធិជាមូលដ្ឋានដែលមនុស្សគ្រប់រូបត្រូវទទួលបាន។ ការមិនយកចិត្តទុកដាក់លើបញ្ហាសិទ្ធិមនុស្ស ជាពិសេសសិទ្ធិរស់រានមានជីវិត គឺជាកំហុសដ៏ធ្ងន់ធ្ងរជាប្រវត្តិសាស្ត្រដែលមេដឹកនាំនៃរបបនេះបានបង្កឡើង។ ភស្តុតាងដ៏ច្រើនសន្ធឹកសន្ធាប់ ដែលសបញ្ជាក់អំពីសកម្មភាពបំពារបំពានសិទ្ធិមនុស្សនាសម័យកាលនោះ ជាក់ស្តែង វត្តមាននៃរណ្តៅសាកសពរួមប្រមាណជា ២ម៉ឺនរណ្តៅ ដែលរបបខ្មែរក្រហមបានបន្សល់ទុកនៅលើទឹកដីកម្ពុជា។[36]

---

[35] កិច្ចព្រមព្រៀង អ.ស.ប និងកម្ពុជា, មាត្រា ២ កថាខណ្ឌទី៣។

[36] ឌី ខាំបូលី , *ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*, បោះពុម្ពផ្សាយលើកទី ២, ទំព័រទី ៥។ រូបភាពផែនទីមាននៅក្នុងឧបសម្ព័ន្ធទី ២

ជាគោលការណ៍អន្តរជាតិ គឺជនគ្រប់រូបត្រូវមានសិទ្ធិឱ្យសាលាក្តីមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង ដែលបង្កើតឡើងដោយច្បាប់ ជំនុំជម្រះរឿងក្តីរបស់ខ្លួន ដោយសមធម៌ និងជាសាធារណៈដើម្បីសម្រេចលើការចោទប្រកាន់ប្រឆាំងមកលើខ្លួនក្នុងវិស័យព្រហ្មទណ្ឌ ឬលើសិទ្ធិ និងករណីយកិច្ច ក្នុងវិស័យរដ្ឋប្បវេណី។[37] ជាកិច្ចឆ្លើយតប អ.វ.ត.ក បានបង្កើតឱ្យមាននូវអង្គភាពគាំពារជនរងគ្រោះ និងអង្គភាពដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងរចនាសម្ព័ន្ធនៃតុលាការ ដើម្បីធានាឱ្យបាននូវសិទ្ធិរបស់ជនរងគ្រោះ។ ការចូលរួមរបស់ជនរងគ្រោះ គឺមានសារៈសំខាន់ណាស់ក្នុងសំណុំរឿងខ្មែរក្រហមនេះ ក៏ព្រោះតែការស្វែងរកឱ្យឃើញនូវហេតុការណ៍ពិតគឺជាចំណុចស្នូលនៃរឿងក្តីព្រហ្មទណ្ឌ។ ហេតុដូច្នេះ ដើម្បីរួមចំណែកជាមួយ អ.វ.ត.ក ក្នុងការស្វែងរកយុត្តិធម៌ជូនខ្លួនឯងផ្ទាល់ ដែលជាជនរងគ្រោះ ក៏ដូចជាតំណាងឱ្យប្រជាជនខ្មែរជាទូទៅ ជនរងគ្រោះមានសិទ្ធិចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌដើម្បីបង្ហាញអំពីអំណះអំណាង ឬ ទឡ្ហីករណ៍នានា ប្រឆាំងនឹងបុគ្គលដែលពាក់ព័ន្ធនឹងការបង្កឱ្យកើតមានឧក្រិដ្ឋកម្មដែលជាកម្មវត្ថុនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។[38]

មិនតែប៉ុណ្ណោះ ជនរងគ្រោះដែលមានបំណងក្នុងការទាមទារសំណងខូចខាត មានសិទ្ធិក្នុងការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ប៉ុន្តែដើម្បីធានាបាននូវភាពត្រឹមត្រូវ អ្នកដាក់ពាក្យសុំត្រូវឆ្លងកាត់ការវាយតម្លៃដោយសហចៅក្រមស៊ើបអង្កេត អំពីភាពពិតប្រាកដនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមុននឹងទទួលបានសិទ្ធិក្នុងការទាមទារសំណង។ ពាក្យសុំនេះ តម្រូវឱ្យជនរងគ្រោះបង្ហាញអំពីអត្តសញ្ញាណឱ្យបានច្បាស់លាស់ និងព្យសនកម្មខាងរូបរាងកាយ ខាងសម្ភារៈ ឬផ្លូវចិត្ត ដែលជាបច្ច័យដោយផ្ទាល់កើតចេញពីបទឧក្រិដ្ឋមួយ ឬ ច្រើនក្នុងចំណោមបទឧក្រិដ្ឋដែលមានចែងក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

ការបង្កើតឱ្យមាននូវអង្គភាពគាំពារជនរងគ្រោះនេះ គឺលាតត្រដាងឱ្យឃើញអំពីការយកចិត្តដាក់របស់ អ.វ.ត.ក ក្នុងការជួយដល់ប្រជាជនខ្មែរដើម្បីស្វែងរកយុត្តិធម៌ និងជាវិធានការក្នុងការព្យាបាលបញ្ហាផ្លូវចិត្តរបស់ជនរងគ្រោះផងដែរ។

### ១.៣.២ ការធានាឱ្យបាននូវសិទ្ធិរបស់ជនជាប់ចោទ

អង្គភាពគាំពារក្តី គឺជាផ្នែកដ៏សំខាន់មួយស្ថិតក្នុងរចនាសម្ព័ន្ធនៃ អ.វ.ត.ក មានតួនាទីក្នុងការធានាឱ្យបាននូវសិទ្ធិរបស់ជនជាប់ចោទស្របតាមបទដ្ឋានជាតិ និងអន្តរជាតិ។ សិទ្ធិរបស់ជនជាប់ចោទ ត្រូវបានផ្តល់ដល់ជនគ្រប់រូបដែលត្រូវបានគេសង្ស័យថាបានប្រព្រឹត្តបទល្មើស ឬទទួលរងនូវការចោទប្រកាន់ គិតចាប់ពីដំណាក់កាលឃាត់ខ្លួន រហូតដល់នីតិវិធីជម្រះក្តីត្រូវបានបញ្ចប់ជាស្ថាពរ។ សិទ្ធិទាំងនេះ មានមុខងារយ៉ាងសំខាន់ក្នុងការការពារផលប្រយោជន៍សេរីភាព កិត្តិយស សេចក្តីថ្លៃថ្នូរ និងសន្តិសុខផ្ទាល់ខ្លួនរបស់ជនសង្ស័យ ឬ

[37] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤ កថាខណ្ឌទី ២ វាក្យខណ្ឌ១។

[38] វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក, វិធាន ២៣, កថាខណ្ឌទី១ ចំណុច ក។

ជនជាប់ចោទ។[39] យោងតាមមាត្រា ១៣ កថាខណ្ឌទី ១ វាក្យខណ្ឌ១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាល បានចែងថា៖

> សិទ្ធិរបស់ជនជាប់ចោទ ដែលមានចែងនៅក្នុងមាត្រា ១៤ និង មាត្រា១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ ១៩៦៦ ស្តីពីសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃជំនុំជម្រះក្តី។...

អាស្រ័យហេតុនេះ ដើម្បីគោរពទៅតាមលក្ខខណ្ឌនៃការព្រមព្រៀងគ្នារវាងរាជរដ្ឋាភិបាល និង អង្គការសហប្រជាជាតិ អង្គភាពគាំពារក្តីត្រូវបង្កើតឡើងក្នុងគោលដៅធានាឱ្យបាននូវសិទ្ធិសំខាន់ៗ របស់ជនសង្ស័យ ឬ ជនជាប់ចោទឱ្យបានជាអប្បបរមា។

### ១.៣.២.១ សិទ្ធិសេរីភាពក្នុងការជ្រើសរើសមេធាវី និងពេលវេលារៀបចំខ្លួន

វត្តមានមេធាវីនៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ គឺមានសារៈសំខាន់ណាស់ក្នុងការការពារសិទ្ធិ និងផលប្រយោជន៍របស់ជនជាប់ចោទ។ ដោយហេតុថា សិទ្ធិជនសង្ស័យ ឬ ជនជាប់ចោទអាចនឹងត្រូវបានរំលោភបំពានដោយកំហុសចេតនា ឬ អចេតនាណាមួយ ក្នុងករណីដែលពុំមានការតាមដានពីបុគ្គលដែលមានចំណេះដឹងក្នុងវិស័យច្បាប់ដែលជាមេធាវី ឬ អាចនិយាយម្យ៉ាងទៀតថា ជនជាប់សង្ស័យអាចនឹងរងការគម្រាមកំហែង បង្ខិតបង្ខំ ឬ ដាក់សម្ពាធផ្នែកស្មារតី ដើម្បឱ្យឆ្លើយសារភាពលើកំហុសដែលខ្លួនមិនបានប្រព្រឹត្ត ឬ សារភាពថាមានពិរុទ្ធជាដើម។[40] ការជ្រើសរើសមេធាវីការពារក្តី គឺធ្វើឡើងដោយឆន្ទៈរបស់ជនល្មើសមានន័យថាជនសង្ស័យទទួលបានសិទ្ធិក្នុងការជ្រើសរើសមេធាវីណាម្នាក់មកធ្វើជាអ្នកតំណាងដើម្បីការពារក្តីឱ្យខ្លួន។ ជាក់ស្តែងនៅក្នុងដំណាក់កាលស៊ើបអង្កេត អ.វ.ត.ក បានកំណត់ឱ្យជនសង្ស័យចាំបាច់ត្រូវតែមានមេធាវីការពារក្តីដោយឥតគិតថ្លៃ បើទោះបីជាគ្មានលទ្ធភាពគ្រប់គ្រាន់ដើម្បីពឹងពាក់មេធាវីក៏ដោយ។[41]

បន្ថែមពីនេះ សិទ្ធិទទួលបាននូវពេលវេលាគ្រប់គ្រាន់សម្រាប់រៀបចំមធ្យោបាយតទល់ត្រូវបានផ្តល់តាមរយៈមេធាវីការពារក្តី ដើម្បីសិក្សា និងវាយតម្លៃភស្តុតាងដែលដាក់បន្ទុកជនសង្ស័យ ហើយដើម្បីស្វែងរកភស្តុតាងសម្រាប់ដោះបន្ទុកកូនក្តីរបស់ខ្លួន។ ក្នុងនោះផងដែរ ការត្រួតពិនិត្យ និងការដេញដោលសួរសាក្សីដែលដាក់បន្ទុកធ្វើឡើងដោយមេធាវីការពារក្តីនៅក្នុងដំណាក់កាលអង្គជំនុំជម្រះ។[42] ក្នុងករណីដែលមានមូលហេតុសមស្របណា

---

[39] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤ កថាខណ្ឌទី ២។

[40] វិសោធនកម្មច្បាប់អ.វ.ត.ក ឆ្នាំ២០០៤, មាត្រា ៣៥ថ្មី (ឆ); កតិកាសសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ, មាត្រា១៤(៣)(ឆ)។

[41] វិសោធនកម្មច្បាប់ អ.វ.ត.ក ឆ្នាំ២០០៤, មាត្រា២៤ថ្មី។

[42] កតិកាសសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ, មាត្រា ១៤(៣)(ង); វិសោធនកម្មច្បាប់អ.វ.ត.ក ឆ្នាំ ២០០៤, មាត្រា៣៥ថ្មី (ង)។

មួយ ការស្នើសុំពន្យាពេលជំនុំជម្រះអាចធ្វើទៅបាន ដោយត្រូវថ្លឹងថ្លែងរវាងផលប្រយោជន៍របស់ជនសង្ស័យ និង ផលប៉ះពាល់ដល់ការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ។[43]

### ១.៣.២.២ សិទ្ធិសន្មតគ្មានទោសរហូតដល់តុលាការផ្ដន្ទាទោសជាស្ថាពរ

ផ្អែកតាមគោលការណ៍សច្ចាធារណ៍នៃនិរទោស ជនណាដែលទទួលរងនូវបទចោទប្រកាន់ទាក់ទងនឹង បទល្មើសព្រហ្មទណ្ឌមានសិទ្ធិទទួលបាននូវការសន្មតទុកជាមុនថាគ្មានទោស រហូតដល់ពិរុទ្ធភាពតាមផ្លូវច្បាប់ ត្រូវបានបង្ហាញ។[44] សិទ្ធិនេះ គឺជាមូលដ្ឋានគ្រឹះនៃការពារសិទ្ធិមនុស្សក្នុងវិស័យព្រហ្មទណ្ឌ ដោយហេតុថាមុន ពេលបុគ្គលណាម្នាក់ត្រូវបានចោទប្រកាន់ក្រោមបទឧក្រិដ្ឋ ស្ថាប័នអយ្យការត្រូវបញ្ជាក់អំពីពិរុទ្ធភាពរបស់ជននោះ ក្នុងកម្រិតដែលលើសពីស្ថានភាពនៃវិមតិសង្ស័យជាមុនសិន។ ក្នុងករណីដែលការចោទប្រកាន់របស់អយ្យការ មិន បានបំពេញលក្ខខណ្ឌគ្រប់ធាតុផ្សំនៃបទល្មើស ឬ គ្មានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់បន្ទុកជននោះទេ គោល ការណ៍ "វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ"[45] នឹងត្រូវយកមកអនុវត្ត ដែលនាំឱ្យជននោះរួចផុត ពីភាពមានពិរុទ្ធ។

### ១.៣.២.៣ សិទ្ធិទទួលបានសវនាការ និងជាសាធារណៈ

អង្គតុលាការ គឺជាស្ថាប័នឯករាជ្យដោយធានាបាននូវភាពត្រឹមត្រូវ តម្លាភាព និងយុត្តិធម៌នៃអំណាច តុលាការដោយគ្មានការជ្រៀតជ្រែកដោយផ្ទាល់ ឬ ដោយប្រយោលពីអ្នកមានអំណាច ឬ ឥទ្ធិពលពីខាងក្រៅណា មួយឡើយ។ ការអនុវត្តសវនាការយុត្តិធម៌ គឺធានាបានការការពារសិទ្ធិរបស់ជនជាប់ចោទ និងសិទ្ធិរបស់ជនរង គ្រោះ រួមទាំងធានាបាននូវជំនឿទុកចិត្តពីប្រជាជនលើដំណើរការនីតិវិធីរបស់តុលាការ។ សិទ្ធិទទួលបានសវនា ការយុត្តិធម៌នេះ ស្តែងឡើងតាមរយៈអំណាចឯករាជ្យនៃអំណាចតុលាការ ដោយការវិនិច្ឆ័យរបស់ចៅក្រមត្រូវ ចៀសវាងនូវភាពអគតិដែលអាចបណ្តាលឱ្យកើតមានភាពលម្អៀងដូចជា ការរើសអើង ឬ ការគិតទុកជាមុនថា ជនល្មើសគឺជាពិរុទ្ធជន។ ជាក់ស្តែង ចៅក្រម ឬ ព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ ត្រូវបានជ្រើសតាំងឡើងដោយ ប្រកាន់ខ្ជាប់ភាពយុត្តិធម៌ សុចរិត មិនលម្អៀង មានស្មារតីខ្ពស់ ភ្ជាប់ជាមួយបទពិសោធន៍នៅក្នុងជំនាញខាង ច្បាប់ព្រហ្មទណ្ឌ ឬ ច្បាប់អន្តរជាតិ ក្នុងនោះរួមមាន ច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សផងដែរ។[46]

[43] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង វិសោធនកម្មលើទី៩, ១៦ មករា ២០១៥។ "ចាប់ពីនេះតទៅសូមហៅកាត់ថា វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក"

[44] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, មាត្រា ១៤ កថាខណ្ឌទី ២។

[45] រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣, មាត្រា ៣៨។

[46] វិសោធនកម្មច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឆ្នាំ២០០៤, មាត្រា ១០ថ្មី។

ការទទួលយក ឬ ស្វែងរកការណែនាំពីរាជរដ្ឋាភិបាល ឬ ពីប្រភពផ្សេងៗ ត្រូវបានហាមឃាត់ ដើម្បីធានាឱ្យបាននូវគោលការណ៍ឯករាជ្យនៃសិទ្ធិអំណាចក្នុងពេលបំពេញមុខងាររបស់ចៅក្រម និងព្រះរាជអាជ្ញា។[47]

មួយវិញទៀត សិទ្ធិទទួលបានសវនាការជាសាធារណៈ ត្រូវធ្វើឡើងដោយបើកចំហដល់សាធារណជន ហើយការប្រកាសអំពីសេចក្តីសម្រេចក៏ត្រូវតែធ្វើជាសាធារណៈដូចគ្នា ដើម្បីធាននូវតម្លាភាព សុក្រឹតភាព នៅក្នុងប្រព័ន្ធយុត្តិធម៌។ មិនត្រឹមតែប៉ុណ្ណោះ អ.វ.ត.ក ត្រូវអនុញ្ញាតឱ្យរដ្ឋបរទេស តំណាងរបស់អគ្គលេខាធិការអង្គការ សហប្រជាជាតិ តំណាងបណ្តាញព័ត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ចូលរួមក្នុងសវនាការផងដែរ ជាអញ្ញត្តកម្ម ក្នុងករណីពិសេស អ.វ.ត.ក អាចសម្រេចជំនុំជម្រះជាសម្ងាត់បានដោយមានហេតុផលត្រឹមត្រូវ ពោលគឺនីតិវិធីជាធរមាន ដែលការផ្សព្វផ្សាយជាសាធារណៈធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌។[48]

### ១.៣.៣ ផលប្រយោជន៍សម្រាប់ប្រទេសកម្ពុជា

ក្រៅពីគោលដៅក្នុងការស្វែងរកយុត្តិធម៌ជូនប្រជាជនខ្មែរ គឺការទប់ស្កាត់ការវិលត្រឡប់នៃរបបខ្មែរក្រហមក៏ជាផ្នែកមួយដ៏សំខាន់ផងដែរ។ ការបង្កើតតុលាការនេះ វាក៏ជាសារក្នុងការដាស់តឿនចំពោះមេដឹកនាំជាន់ខ្ពស់ និងជនដែលមានការទទួលខុសត្រូវខ្ពស់បំផុត ដើម្បីឱ្យមានការត្រិះរិះពិចារណាឱ្យបានគ្រប់ជ្រុងជ្រោយ និងប្រុងប្រយ័ត្នចំពោះសកម្មភាពនានាដែលពាក់ព័ន្ធនឹងអាយុជីវិតរបស់ប្រជាជន ជាពិសេសគឺចៀសវាងឱ្យបាននូវទង្វើដែលអាចបង្កឱ្យកើតមាននូវឧក្រិដ្ឋកម្មដូចករណីខ្មែរក្រហមនេះ។ មួយវិញទៀត បើទោះបីជាសោកនាដកម្មបានកន្លងផុតទៅអស់រយៈពេលជិត ៣០ឆ្នាំយ៉ាងណាក្តី ក៏យុត្តិធម៌នៅតែអាចកើតមានឡើងជានិច្ច។ ឧក្រិដ្ឋកម្មធ្ងន់ធ្ងរប្រភេទនេះ គឺជាអំពើប្រឆាំងនឹងមនុស្សជាតិ ពោលគឺប្រជាជនដែលជាម្ចាស់នៃប្រទេស រួមជាមួយនឹងសមាគមន៍អន្តរជាតិនឹងស្វែងរកមធ្យោបាយដើម្បីចំពោះសកម្មភាពដែលមានលក្ខណៈព្រៃផ្សៃមកលើមនុស្សជាតិ បើទោះបីជាអំពើនោះកន្លងផុតទៅអស់ប៉ុន្មានទសវត្សយ៉ាងណាក្តី។

លើសពីនេះ ក្នុងដំណើរនៃរឿងក្តីខ្មែរក្រហមក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក គឺជាធាតុចូលយ៉ាងសំខាន់សម្រាប់ការសិក្សាបន្ថែមអំពីហេតុការណ៍ដែលជាប្រវត្តិសាស្ត្រកម្ពុជា និងឆ្លុះបញ្ចាំងឱ្យកាន់តែស៊ីជម្រៅអំពីឆន្ទៈរបស់មេដឹកនាំខ្មែរក្រហម យល់ដឹងអំពីរចនាសម្ព័ន្ធនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ សកម្មភាពដែលខ្មែរក្រហមបានប្រព្រឹត្ត និងវិធីសាស្ត្រដែលខ្មែរក្រហមប្រើប្រាស់ដើម្បីធ្វើទារុណកម្ម សម្លាប់ និងទង្វើឃោរឃៅផ្សេងៗទៀត។ មិនតែប៉ុណ្ណោះ អ.វ.ត.ក ជាតុលាការកូនកាត់មួយ ដែលប្រើប្រព័ន្ធជាតិ និងអន្តរជាតិ នឹងជួយពង្រឹងដល់

[47] វិសោធនកម្មច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឆ្នាំ២០០៤, មាត្រា ១០ថ្មី។

[48] ប្រភពដូចខាងលើ, មាត្រា ៣៤ថ្មី។

វិស័យតុលាការនៅប្រទេសកម្ពុជា។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន តំណាងរាជរដ្ឋាភិបាលកម្ពុជា បានធ្វើការកត់សម្គាល់ថា "តុលាការនេះនឹងក្លាយជាគំរូថ្មីមួយសម្រាប់ដំណើរការកាត់ក្តីនៅកម្ពុជា"[49]។

ការបង្កើត អ.វ.ត.ក នៅលើទឹកដីកម្ពុជា ជារឿងដ៏សមហេតុសមផល និងត្រឹមត្រូវបំផុតសម្រាប់ផលប្រយោជន៍ជាតិ ពីព្រោះអ្នករងគ្រោះ សាក្សី និងប្រជាជនខ្មែរអាចចូលរួមក្នុងដំណើរការនៃកិច្ចនីតិវិធីរបស់តុលាការបានយ៉ាងងាយស្រួល។ លើសពីនេះ ប្រព័ន្ធតុលាការ និងកិច្ចនីតិវិធី ដែលធ្វើឡើងដោយតុលាការនឹងជះឥទ្ធិពលជាវិជ្ជមានដល់សង្គមកម្ពុជាក្នុងការពង្រឹងចំណេះដឹងក្នុងវិស័យយុត្តិធម៌ផងដែរ។

[49] ផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក, ការណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម, បោះពុម្ពលើកទី ៤, សេចក្តីផ្តើម។

# ជំពូកទី ២
# យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ
# ក្នុងតុលាការកម្ពុជា

# ជំពូកទី ២ យុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

អ.វ.ត.ក ត្រូវបានបង្កើតឡើងក្នុងប្រព័ន្ធតុលាការដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា ដោយប្រកាន់នូវគោលការណ៍ជាតិ និងអន្តរជាតិដើម្បីធានាឱ្យបាននូវតម្លាភាពតាមស្តង់ដារអន្តរជាតិ។ អ.វ.ត.ក ទទួលភារកិច្ចពិសេសលើរឿងក្តីដែលមានលក្ខណៈស្មុគស្មាញជាប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា។ អ្វីដែលពិសេសនោះ គឺសមត្ថកិច្ចរបស់ អ.វ.ត.ក ត្រូវបានកម្រិតនូវព្រំដែនយ៉ាងជាក់លាក់ទៅលើការវិនិច្ឆ័យសេចក្តីពាក់ព័ន្ធនឹងសំណុំរឿងខ្មែរក្រហម មានន័យថាទាល់តែសំណុំរឿងដែលបានបំពេញស្របទៅតាមលក្ខខណ្ឌដែលច្បាប់បានកំណត់ទើបអនុញ្ញាតឱ្យតុលាការនេះមានសិទ្ធិក្នុងការទទួលយកករណីនោះមកធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តីបាន។ ផ្អែកតាមមាត្រា ១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានចែងថា៖

> ច្បាប់នេះរៀបចំឡើងក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម និងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ៦ មករា ឆ្នាំ១៩៧៩។

យោងតាមខ្លឹមសារនៃបទបញ្ញត្តិខាងលើ គឺបានកំណត់នូវលក្ខខណ្ឌចំនួន០៣ មានដូចជា ពេលវេលាដែលបទល្មើសបានកើតឡើង ឋានៈបុគ្គល និងប្រភេទនៃបទល្មើស។ ដូច្នេះ នៅក្នុងករណីដែលអវត្តមាននូវលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌខាងលើនេះ នឹងនាំឱ្យរឿងក្តីនោះពុំស្ថិតនៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក នោះទេ។

## ២.១ សមត្ថកិច្ចតុលាការតាមពេលវេលា

អំឡុងពេលដែលប្រទេសកម្ពុជាស្ថិតក្រោមការដឹកនាំរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ គឺជាពេលវេលាដែលសង្គមខ្មែរ បានធ្លាក់ចូលទៅក្នុងស្ថានភាពដ៏សែនលំបាក ដែលបង្កឡើងដោយការប្រព្រឹត្តិឧក្រិដ្ឋកម្មធ្ងន់ធ្ងរដោយពួកខ្មែរក្រហម។ អាស្រ័យហេតុនេះ ពេលវេលាដែលបទល្មើសបានកើតឡើង គឺផ្តោតទៅលើអំឡុងពេលដែលអង្គការខ្មែរក្រហមកំពុងតែគ្រប់គ្រងប្រទេសកម្ពុជា។ អំឡុងពេលនេះ ត្រូវគិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជាថ្ងៃដែលខ្មែរក្រហមបានវាយចូលកាន់កាប់ទីក្រុងភ្នំពេញបានដោយជោគជ័យ រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ មុនមួយថ្ងៃដែលរបបនេះត្រូវវាយផ្តួលចេញពីតំណែងដឹកនាំរដ្ឋ។[50]

[50] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឆ្នាំ២០០១, មាត្រា១។

## ២.២ សមត្ថកិច្ចតុលាការផ្តោតតាមឋានៈបុគ្គល

បុគ្គលដែលត្រូវចាត់ឱ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរបបខ្មែរក្រហម គឺមានមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត អនុលោមតាមមាត្រា១ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ចំណោទបញ្ហា គឺលិខិតបទដ្ឋានគតិយុត្តដែលគ្រប់គ្រងដំណើរការនៃ អ.វ.ត.ក ពុំបានផ្តល់ជានិយមន័យ ឬ លក្ខខណ្ឌក្នុងការកំណត់អំពីលក្ខណសម្បត្តិរបស់បុគ្គលពីរប្រភេទនេះទេ។ ដូចនេះ ថាតើ អ.វ.ត.ក ពិចារណាទៅលើមូលដ្ឋានអ្វីខ្លះ ដើម្បីវាយតម្លៃអំពីឋានៈបុគ្គលដែលជាលក្ខខណ្ឌចាំបាច់មួយ ដើម្បីកំណត់អំពីបុគ្គលដែលត្រូវទទួលខុសត្រូវក្នុងរឿងក្តីព្រហ្មទណ្ឌកាលពីរបបខ្មែរក្រហម។

### ២.២.១ មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ

មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ គឺសំដៅលើជនដែលជាកម្មាភិបាលខ្មែរក្រហម មានឥទ្ធិពល និងសិទ្ធិអំណាចក្នុងការចូលរួមបង្កើត និងសេចក្តីសម្រេចចុងក្រោយលើគោលនយោបាយដឹកនាំនានា រួមទាំងមានលទ្ធភាពក្នុងការដឹងអំពីហេតុការណ៍ដែលបានកើតឡើង។[51]

ជាក់ស្តែង នួន ជា និងខៀវ សំផន ត្រូវបាន អ.វ.ត.ក ចាត់ទុកជាប្រភេទបុគ្គលដែលជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលតម្រូវឱ្យពួកគាត់ទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលកើតឡើង។ ដោយហេតុថាពួកគាត់ត្រូវបានចាត់ទុកជាមនុស្សដ៏សំខាន់ ដែលបានចូលរួមចំណែករៀបចំ និងអនុវត្តគោលនយោបាយក្នុងការដឹកនាំក្បាលម៉ាស៊ីននាសម័យកម្ពុជាប្រជាធិបតេយ្យ។

#### ២.២.១.១ តំណែងនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ

**ក- តំណែងរបស់ នួន ជា**

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា ជាសមាជិកនៃអនុលេខានៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា និងជាគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា។[52] បន្ថែមពីនេះ នួន ជា មានតួនាទីជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន ហើយក៏ត្រូវបានតែងតាំងជានាយករដ្ឋមន្ត្រីស្តីទីនៅក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យផងដែរ។[53]

---

[51] អ.វ.ត.ក, សហព្រះរាជអាជ្ញា តទល់នឹង ជនជាប់ចោទ កាំង ហ្គេចអ៊ាវ ហៅ ឌុច, សាលដីកា, សំណុំរឿងលេខ: ០០១/១៨ កក្កដា ២០០៧/អវតក/អជសដ, F28, កថាខណ្ឌទី៥៧ ("តទៅនេះសូមហៅកាត់ថា សាលដីកា ០០១ ឌុច, F28")។ "មេដឹកនាំជាន់ខ្ពស់ម្នាក់មិនមែនជាជនសង្ស័យដោយផ្អែកតែទៅលើតួនាទីជាអ្នកដឹកនាំរបស់ខ្លួនប៉ុណ្ណោះទេ"។

[52] សាលក្រម ០០២/០១ នួនជា និងខៀវសំផន, E313, កថាខណ្ឌទី ៣១៥។

[53] ប្រភពដូចខាងលើ, កថាខណ្ឌទី ៣១៨។ "នួន ជា បានទទួលស្គាល់តំណែងជាប្រធានសភាតំណាងរាស្ត្រ ដោយពុំបដិសេធនោះទេ ប៉ុន្តែតំណែងជានាយករដ្ឋមន្ត្រីស្តីទី ត្រូវបាន នួន ជា បដិសេធពុំទទួលស្គាល់នោះទេ ប៉ុន្តែដោយហេតុថា អ.វ.ត.ក បានរកឃើញភស្តុតាងដែលសបញ្ជាក់ឱ្យឃើញថា នួន ជា មានតំណែងជានាយករដ្ឋមន្ត្រីស្តីទីនៅពេលដែល ប៉ុន ពត អវត្តមាននៅក្នុងប្រទេស ឬមានបញ្ហាសុខភាព"។

**ខ- តំណែងរបស់ ខៀវ សំផន**

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន ជាសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា។ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ក៏បានប្រគល់នូវតួនាទីជាប្រធានគណៈប្រធានរដ្ឋ ជាសមាជិកថ្នាក់ដឹកនាំនៃមន្ទីរ៨៧០ និងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការពារជាតិ និងជាអគ្គមេបញ្ជាការកងទ័ពរំដោះជាតិកម្ពុជា។

**២.២.២.២ សិទ្ធិអំណាច និងសកម្មភាពនៅក្នុងមុខងារ**

**ក- នួន ជា**

ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នួន ជា មានមុខងារជាប្រធានសភាតំណាងប្រជាជន។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បានផ្តល់អំណាចឱ្យសភាតំណាងប្រជាជនកម្ពុជាជាអង្គការទទួលខុសត្រូវក្នុងការធ្វើច្បាប់ ដែលសភានេះប្រមូលផ្តុំទៅដោយសមាជិកចំនួន ២៥០នាក់ ដែលជាតំណាងឱ្យប្រជាជន កសិករ កងទ័ពបដិវត្តកម្មករ និងពលករផ្សេងទៀត។[54] ស្ថិតក្នុងមុខងារជាប្រធានសភាតំណាងប្រជាជន នួន ជា ត្រូវទទួលខុសត្រូវលើការរៀបចំកិច្ចពិភាក្សា និងការអនុម័តច្បាប់។[55]

ការទទួលខុសត្រូវលើការងារបក្ស ឃោសនាការ សង្គមកិច្ច វិប្បធម៌ ការអប់រំកសិករ កម្មាភិបាល និងសមាជិកផ្សេងៗ គឺជាបន្ទុករបស់ នួន ជា ក្នុងការរៀបចំគោលនយោបាយដែលស្តែងឡើងតាមរយៈការរៀបចំនូវវគ្គបណ្តុះបណ្តាល ដោយផ្តោតទៅលើគោលនយោបាយបដិវត្តន៍ គោលនយោបាយសេដ្ឋកិច្ច និងសហករណ៍ គោលនយោបាយបង្កើនស្មារតីប្រុងប្រយ័ត្នចំពោះសត្រូវ រួមទាំងមានតួនាទីក្នុងការត្រួតពិនិត្យរាល់របាយការណ៍ពីកម្មាភិបាលតាមតំបន់ចំពោះការអនុវត្តគោលនយោបាយ ផ្តល់យោបល់លើបញ្ហាវិន័យ និងការដាក់ទណ្ឌកម្ម។[56] បន្ថែមពីនេះ នួន ជា ជាប់ពាក់ព័ន្ធនឹងគោលនយោបាយសន្តិសុខជាតិ តាមរយៈការធ្វើសកម្មភាពយ៉ាងសកម្មជាមួយនឹងមេដឹកនាំក្នុងជួរបក្សដោយការបញ្ចេញមតិយោបល់ ផ្តល់ការណែនាំ និងសម្រេចសេចក្តី ទាក់ទងនឹងការបោសសម្អាតសមាជិកផ្ទៃក្នុងបក្សដែលត្រូវបានចាត់ទុកជាខ្មាំង បញ្ហាព្រំដែនរវាងកម្ពុជា និងប្រទេសវៀតណាម ក៏ដូចជាទទួលរបាយការណ៍អំពីស្ថានភាពសន្តិសុខជាតិពីខាងព្រំដែន និងមន្ទីរសន្តិសុខ២១ ផងដែរ។[57]

---

[54] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឆ្នាំ ១៩៧៦, មាត្រា ៥។

[55] សាលក្រម ០០២/០១ នួន ជា និង ខៀវ សំផន, E313, កថាខណ្ឌទី ៣១៨។ "នួន ជា បញ្ជាក់ថា ក្នុងអំឡុងពេលដែលខ្មែរក្រហមកាន់អំណាចសភានេះ បានបើកកិច្ចប្រជុំបានតែម្តងប៉ុណ្ណោះ ហើយពុំបានអនុម័តច្បាប់ណាមួយឡើយ ដែលនេះលោកហៅថាស្ថាប័នមានតែសំបក"។

[56] ប្រភពដូចខាងលើ, កថាខណ្ឌទី ៣២៤-៣២៨។

[57] អ.វ.ត.ក, *សហព្រះរាជអាជ្ញា តទល់នឹង ជនជាប់ចោទ នួន ជា ខៀវ សំផន*, សាលក្រម, សំណុំរឿងលេខ០០២/០២, ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ, E465, កថាខណ្ឌទី ៥៤១-៥៦០។ "ចាប់ពីនេះសូមហៅកាត់ថា សាលក្រម ០០២/០២ នួន ជា និងខៀវ សំផន, E465"

**ខ- ខៀវ សំផន**

ក្នុងតំណែងជាគណៈប្រធានរដ្ឋ ខៀវ សំផន បានធ្វើសកម្មភាពការទូត និងពិធីការផ្សេងៗ មានជាអាទិ៍ ការដឹកនាំគណៈប្រតិភូធ្វើទស្សនកិច្ចទៅបរទេស សកម្មភាពជំនួបជាមួយបរទេសក្នុងនាមជាម្ចាស់ផ្ទះ រួមជាមួយនឹងការផ្ញើ និងទទួលកំណត់ទូតតំណាងឱ្យរបបកម្ពុជាប្រជាធិបតេយ្យជាដើម។[58]

គណៈកម្មាធិការមជ្ឈិម មានតួនាទីបើកការពិភាក្សាអំពីការអនុវត្តគោលនយោបាយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ហើយមានសិទ្ធិចេញសេចក្ដីបង្គាប់ណែនាំ និងការកែលម្អទៅលើលក្ខខណ្ឌមួយចំនួននៅតាមទីជនបទ។[59] បន្ថែមពីនេះ ខៀវ សំផន មានសិទ្ធិអំណាចពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ចក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយទទួលបន្ទុកត្រួតពិនិត្យ និងគ្រប់គ្រងលើការចែកចាយទំនិញ មានដូចជាការនាំចេញស្រូវ អង្ករ និងទំនិញផ្សេងៗ ទៅអន្តរជាតិ និងទៅតាមតំបន់ភូមិភាគ។[60]

## ២.២.២ ជនដែលទទួលខុសត្រូវខ្ពស់បំផុត

ជនដែលទទួលខុសត្រូវខ្ពស់បំផុតគឺត្រូវតែជាកម្មាភិបាលខ្មែរក្រហម និងស្ថិតក្នុងចំណោមជនដែលត្រូវទទួលខុសត្រូវខ្ពស់បំផុត។[61] ច្បាប់ពុំបានកំណត់ជាលក្ខខណ្ឌឱ្យបានច្បាស់លាស់នោះទេ ប៉ុន្តែយោងតាមការកិច្ចពិភាក្សាក្នុងអំឡុងពេលតាក់តែងច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក តំណាងរាជរដ្ឋាភិបាលបានលើកឡើងថា៖

> ...ពាក់ព័ន្ធនឹងជនទាំងឡាយដែលមិនមែនជាមេដឹកនាំជាន់ខ្ពស់ ប៉ុន្តែបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ដូចមេដឹកនាំជាន់ខ្ពស់ហើយនឹងក្លាយជាមុខសញ្ញារបស់អង្គជំនុំជម្រះវិសាមញ្ញផងដែរ។ ...ជនមួយចំនួនទៀតដែលអាចមិនមែនជាមេដឹកនាំជាន់ខ្ពស់ ប៉ុន្តែអំពើរបស់ពួកគេមានលក្ខណៈធ្ងន់ធ្ងរខ្លាំងជាង ហើយមានភស្តុតាងគ្រប់គ្រាន់បង្ហាញថាពួកគេពិតជាបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរខ្លាំងជាងអ្នកដទៃទៀត។[62]

ជាក់ស្ដែង ក្នុងសំណុំរឿងលេខ០០១ ដែលមានជនជាប់ចោទឈ្មោះ កាំង ហ្កេចអ៊ាវ ហៅឌុច ត្រូវបាន អ.វ.ត.ក សម្រេចឱ្យទទួលខុសត្រូវក្នុងឋានៈជាជនដែលទទួលខុសត្រូវខ្ពស់បំផុត ដោយផ្អែកទៅលើសិទ្ធិអំណាច

---

[58] សាលក្រម ០០២/០២ នួន ជា និងខៀវ សំផន, E465, កថាខណ្ឌទី ៥៩១។

[59] ប្រភពដូចខាងលើ, កថាខណ្ឌទី ៥៩៦។ "ខៀវ សំផន ក៏ទទួលស្គាល់ថាខ្លួនជាសមាជិកនៃគណៈកម្មាធិការនេះផងដែរ"។

[60] ប្រភពដូចខាងលើ, កថាខណ្ឌទី ៣២៥-៣៣២។ "អ.វ.ត.ក ពុំមានភស្តុតាងបញ្ជាក់ឱ្យឃើញថា ខៀវ សំផន បានតែងតាំងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក្ដី ប៉ុន្តែដោយសំអាងទៅលើរបាយការណ៍ពាក់ព័ន្ធនឹងផ្នែកពាណិជ្ជកម្មជាច្រើនដែលបានផ្ញើ ឬចតចម្លង ដោយដាក់ឈ្មោះ ខៀវ សំផន អាស្រ័យហេតុនេះអាចសបញ្ជាក់ឱ្យឃើញថា ខៀវ សំផន ពិតជាមានការទាក់ទិនទៅនឹងការគ្រប់គ្រងវិស័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម នាសម័យកម្ពុជាប្រជាធិបតេយ្យ"។

[61] សាលដីកា ០០១ ឌុច, F28, កថាខណ្ឌទី ៥៧។

[62] ប្រភពដូចខាងលើ, កថាខណ្ឌទី ៥៣។

ក្នុងការមុខតំណែងដែលប្រគល់ឱ្យដោយបក្សកុម្មុយនីស្តកម្ពុជា ហើយដែលបង្កឱ្យកើតមាននូវអំពើឧក្រិដ្ឋកម្មធ្ងន់ធ្ងរ។ ដូច្នេះ ករណី កាំង ហ្កេចអ៊ាវ គឺជាមូលដ្ឋានក្នុងការស្វែងយល់អំពីការវាយតម្លៃរបស់ អ.វ.ត.ក។

**២.២.២.១ តំណែងនៅក្នុងស្ថាប័នសំខាន់ក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ**

កាំង ហ្កេចអ៊ាវ បម្រើការងារនៅក្នុងមន្ទីរសន្តិសុខ ២១ ត្រូវបានតែងតាំងជាប្រធាន និងជាលេខាមន្ទីរស ២១នៅក្នុងខែមីនា ឆ្នាំ១៩៧៦ ក្រោយពីអតីតប្រធានឈ្មោះ អ៊ិន លន ហៅ ណាត ត្រូវបានផ្លាស់ទៅកាន់ផ្នែកសេនាធិការ ។[63] មិនតែប៉ុណ្ណោះ កាំង ហ្កេចអ៊ាវ ក៏បានចូលរួមរៀបចំគោលនយោបាយដើម្បីបង្កើតមន្ទីរនេះ តាមការកោះហៅរបស់ សុន សេន។[64] មន្ទីរស២១ មានវិសាលភាពគ្រប់ដណ្តប់លើទីកន្លែងមួយចំនួនផ្សេងទៀត មានដូចជា មន្ទីរឃុំឃាំងទួលស្លែង ជើងឯក និងព្រៃស ហៅថា ស២៤។[65] ហេតុនេះហើយមន្ទីរនេះ ត្រូវបានចាត់ទុកជាទីកន្លែងសំខាន់ ពីព្រោះវាស្ថិតនៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និងមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងកម្មាភិបាលមជ្ឈិមរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលនេះសបញ្ជាក់អំពីលក្ខណៈពិសេសក្រៅពីមន្ទីរសន្តិសុខដទៃទៀត។

**២.២.២.២ សិទ្ធិអំណាច និងសកម្មភាពនៅក្នុងមុខងារ**

នៅក្នុងតំណែងជាប្រធានមន្ទីរស២១ កាំង ហ្កេចអ៊ាវ មានភារកិច្ចក្នុងការគ្រប់គ្រងបុគ្គលិក និងអង្គភាពដែលចំណុះឱ្យមន្ទីរស២១ មានដូចជា អង្គភាពឯកសារ អង្គភាពសួរចម្លើយ អង្គភាពការពារ និងអង្គភាពផ្សេងៗទៀត។ ក្នុងតួនាទីជាប្រធាន កាំង ហ្កេចអ៊ាវ មានសិទ្ធិក្នុងការជ្រើសរើសបុគ្គលិក បណ្តុះបណ្តាលបុគ្គលិក បញ្ជាឱ្យចាប់ខ្លួន ពិនិត្យចម្លើយសារភាព និងការបញ្ជាឱ្យសម្លាប់។

ការជ្រើសរើសបុគ្គលិកបម្រើការងារនៅក្នុងមន្ទីរនេះ ធ្វើឡើងតាមសំណើរបស់ កាំង ហ្កេចអ៊ាវ ដោយផ្ទាល់ទៅកាន់ សុន សេន ដែលត្រូវជាថ្នាក់លើ។ យុវជនវ័យជំទង់ ជាមុខសញ្ញាអាទិភាពក្នុងការទទួលជ្រើសរើសឱ្យចូលបម្រើការងារ ដោយហេតុថាជនប្រភេទនេះងាយក្នុងការអប់រំ ឬ បញ្ជា ហើយដែលភាគច្រើនជាកូនកសិករក្រីក្រ និងទទួលបានការអប់រំតិចតួច។ នេះ ជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពដើម្បីផ្តល់ភាពងាយស្រួលក្នុងការបញ្ជ្រាបមនោគមន៍វិជ្ជាទៅដល់ពួកគេ។ ការបណ្តុះបណ្តាលនេះទៀតសោត គឺស្ថិតក្រោមការណែនាំ និងបង្រៀនដោយ កាំង ហ្កេចអ៊ាវ ទាក់ទងនឹងវិធីសាស្ត្រសួរចម្លើយដោយប្រើប្រាស់ទារុណកម្មទៅលើរូបរាងកាយ និងផ្លូវចិត្តដើម្បីទទួលបានចម្លើយពីអ្នកជាប់ឃុំក្នុងមន្ទីរស២១ បណ្តុះឱ្យចេះគោរពតាមបង្គាប់ និងការសម្លាប់ជាដើម។ កាំង ហ្កេចអ៊ាវ ក៏មានសិទ្ធិបញ្ជាឱ្យចាប់ខ្លួនបុគ្គលណាមួយផងដែរ ត្បិតជាគោលការណ៍គឺតម្រូវឱ្យមានការ

[63] សាលក្រម ០០១ ឧច, E188, កថាខណ្ឌទី ១២៨។

[64] ប្រភពដូចខាងលើ, កថាខណ្ឌទី ១១៩។

[65] ប្រភពដូចខាងលើ, កថាខណ្ឌទី ១១៩។

សម្រេចពីគណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្សក៏ដោយក្តី ប៉ុន្តែផ្អែកតាម អង្គភាពស៊ើបសួរនៃ អ.វ.ត.ក បានរកឃើញនូវភស្តុតាងមួយចំនួនដែលអាចដាក់បន្ទុកទៅលើ កាំង ហ្គេចអ៊ាវ ពាក់ព័ន្ធនឹងការរួមចំណែកក្នុងការផ្តល់ជាមុខសញ្ញានៃការចាប់ខ្លួនជូនទៅថ្នាក់លើដើម្បីពិចារណា និងធ្វើការសម្រេច។

មួយវិញទៀត នៅក្នុងសកម្មភាពពាក់ព័ន្ធនឹងការសួរចម្លើយ កាំង ហ្គេចអ៊ាវ បានដើរតួនាទីយ៉ាងសកម្មក្នុងការពិនិត្យចម្លើយរបស់ជនជាប់ឃុំ ដែលបានស្រង់ពីសំណាក់បុគ្គលិកផ្នែកសួរចម្លើយ។ ក្នុងករណីដែលចម្លើយពុំទាន់មានលក្ខណៈគ្រប់គ្រាន់ កាំង ហ្គេចអ៊ាវ នឹងធ្វើកំណត់សម្គាល់ ឬ ធ្វើចំណារអំពីចំណុចដែលខ្វះខាត រួមជាមួយនឹងវិធីសាស្ត្រក្នុងការធ្វើទារុណកម្ម ប្រគល់ជូនទៅឱ្យបុគ្គលិករបស់ខ្លួន ដើម្បីបន្តការសួរចម្លើយដោយអនុវត្តទៅតាមបញ្ជា។ មុននឹងបញ្ជូនចម្លើយសារភាពទៅកាន់ថ្នាក់ កាំង ហ្គេចអ៊ាវ បានខិតខំសម្រួលនូវខ្លឹមសារដោយការធ្វើសេចក្តីសង្ខេប និងរៀបចំឱ្យមានរបៀបរាប់រយ។[66]

លើសពីនេះ កាំង ហ្គេចអ៊ាវ មានសិទ្ធិបញ្ជាឱ្យយកអ្នកជាប់ឃុំទៅសម្លាប់ចោលដោយផ្ទាល់ ឬ តាមការបញ្ជាពីថ្នាក់លើ។ អ្នកជាប់ឃុំនៃមន្ទីរស២១ ទាំងអស់នឹងត្រូវយកទៅសម្លាប់ចោល ក្រោយពីយល់ឃើញថាចម្លើយសារភាពរបស់ពួកគេមានលក្ខណៈគ្រប់គ្រាន់។ ឯកសារដែលបញ្ចូលជាភស្តុតាងជាច្រើន អាចបញ្ជាក់យ៉ាងច្បាស់ថា កាំង ហ្គេចអ៊ាវ ពិតជាបានបញ្ជាបុគ្គលិករបស់ខ្លួននាំយកអ្នកជាប់ឃុំទៅសម្លាប់ចោល ហើយនៅចំពោះមុខអង្គជំនុំជម្រះ កាំង ហ្គេចអាវ ក៏បានទទួលស្គាល់នូវឯកសារទាំងនេះផងដែរ។[67]

## ២.៣ សមត្ថកិច្ចតុលាការទាក់ទងពាក់ព័ន្ធនឹងបទល្មើស

ឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក រួមមាន ឧក្រិដ្ឋកម្មដូចដែលមានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម ការបំផ្លេចបំផ្លាញសម្បត្តិវប្បធម៌នៅពេលមានជម្លោះប្រដាប់អាវុធ និងឧក្រិដ្ឋកម្មប្រឆាំងទៅលើអ្នកដែលទទួលបានការការពារជាអន្តរជាតិស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវ។[68]

ផ្អែកតាមគោលការណ៍នៃការស្រូបទោសចំពោះបទល្មើសដូចគ្នា និងគោលការណ៍ច្បាប់អន្តរជាតិ បទល្មើសដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក មានផ្នែកខ្លះមានលក្ខណៈដូចគ្នា។ ហេតុដូច្នេះ មានតែឧក្រិដ្ឋកម្មចំនួន ៣ ប៉ុណ្ណោះដែលនឹងត្រូវយកមកបកស្រាយគឺ ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

[66] សាលក្រម ០០១ ឧច, E188, កថាខណ្ឌទី ១៧៦។

[67] ប្រភពដូចខាងលើ, កថាខណ្ឌទី ១៨២។

[68] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា៣ ដល់ មាត្រា៨។

### ២.៣.១ ឧក្រិដ្ឋកម្មសង្គ្រាម

ឧក្រិដ្ឋកម្មសង្គ្រាម គឺសំដៅលើការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវដែលត្រូវយកមកអនុវត្តនៅក្នុងអំឡុងពេលកើតមានជម្លោះប្រដាប់អាវុធ និងកំណត់អំពីទណ្ឌកម្មលើជនដែលត្រូវទទួលខុសត្រូវ។ អនុសញ្ញានេះ គ្រប់គ្រងលើសកម្មភាពសង្គ្រាមនានាដែលបានប្រព្រឹត្ត នៅក្នុងអំឡុងពេលកើតមានសង្គ្រាមរហូតដល់សង្គ្រាមត្រូវបញ្ចប់ជាស្ថាពរ។ វា គឺជាធាតុសំខាន់បំផុតនៃច្បាប់មនុស្សធម៌អន្តរជាតិ ដោយផ្តោតសំខាន់លើការការពារមនុស្ស ឬ ទ្រព្យសម្បត្តិដែលមិនត្រូវបានក្លាយជាកម្មវត្ថុនៃការវាយប្រហារ។ ការការពារលើមនុស្សជាតិ សំដៅដល់ការការពារជាពិសេសដល់ជនស៊ីវិល[69] ជនដែលមិនបានចូលរួម នៅក្នុងអរិយភាព ឬ ចូលរួមនៅក្នុងសកម្មភាពសង្គ្រាម មានជាអាទិ៍ ទាហាន ដែលមានជំងឺ ឬ មានរបួស និង ឈ្លើយ សឹកជាដើម[70]។ រីឯការការពារលើទ្រព្យសម្បត្តិ សំដៅដល់ការការពារទីកន្លែង វប្បធម៌ និងអរិយធម៌ ជាប្រវត្តិសាស្ត្រ បរិស្ថានធម្មជាតិ សាលារៀន មន្ទីរពេទ្យ ទីកន្លែង សាសនា ទីដែលដាក់សញ្ញាសម្គាល់ថាជាកន្លែងព្យាបាលជំងឺ ឬ សម្រាប់ជួយសង្គ្រោះនៅក្នុងអំឡុងពេលមានសង្គ្រាមកើតឡើង។[71]

មួយវិញទៀតផ្អែកតាមច្បាប់ស្តីពីទំនៀមទម្លាប់អន្តរជាតិ (Customary International Humanitarian Law "CIHL") គោលដៅនៃការវាយប្រហារ គឺសំដៅលើជនដែលជាទាហាន ឬ ជាសមាជិកនៃក្រុមជម្លោះប្រដាប់អាវុធ ឬ ជាជនស៊ីវិលដែលបាត់បង់ការការពារ តាមរយៈការចូលរួមក្នុងអរិយភាពប្រឆាំងទៅនឹងទាហាន ឬ សមាជិកនៃក្រុមជម្លោះប្រដាប់អាវុធម្ខាងទៀត។[72] ចំពោះ អាវុធដែលប្រើនៅក្នុងអំឡុងពេលមានសង្គ្រាម ក៏ត្រូវបានកម្រិតក្នុងលក្ខខណ្ឌមួយ ដែលធ្វើយ៉ាងណាមិនបង្កឱ្យមានមហន្តរាយដល់មនុស្សជាតិមានជាអាទិ៍ អាវុធជីវីសាស្ត្រ អាវុធគីមី ឬ ការប្រើអាវុធនុយក្លេអ៊ែរជាដើម។[73]

ផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី[74] (ICTY) បានកំណត់នូវលក្ខខណ្ឌចំនួន ៥ ដើម្បីចាត់ទុកថាជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ[75]៖

១- ការកើតមានជម្លោះប្រដាប់អាវុធ

---

[69] Geneva Convention IV (អនុសញ្ញាទីក្រុងហ្សឺណែវទី៤)។

[70] Geneva Convention I, II (អនុសញ្ញាទីក្រុងហ្សឺណែវទី១ "ទាហានមានរបួសឬមានជំងឺនៅលើដែនដី", អនុសញ្ញាទីក្រុងហ្សឺណែវទី២" ទានហានមានរបួសឬមានជំងឺនៅលើនាវា")។

[71] Additional Protocol of Geneva Convention III (ពិធីសារបន្ថែមនៃអនុសញ្ញាទីក្រុងហ្សឺណែវ ទី៣)។

[72] ICRC, *Customary International Humanitarian Law (ច្បាប់ស្តីពីទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ)*, (CIHL), មាត្រា៧ ដល់ មាត្រា ១០។

[73] ប្រភពដូចខាងលើ, មាត្រា១៧។

[74] ចាប់ពីនេះតទៅ សូមហៅកាត់ថា "ICTY"។

[75] សាលក្រម ០០១ ឌុច, E188, កថាខណ្ឌទី ៤១០។

២- ប្រភេទនៃជម្លោះប្រដាប់អាវុធ

៣- ទំនាក់ទំនងរវាងអំពើអមនុស្សធម៌ និងជម្លោះប្រដាប់អាវុធ

៤- ការបំពានលើកម្មវត្ថុនៃការការពារក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ និង

៥- ការយល់ដឹងរបស់ជនជាប់ចោទទាក់ទងនឹងជម្លោះប្រដាប់អាវុធ។

### ២.៣.១.១ ជម្លោះប្រដាប់អាវុធ[76]

ជម្លោះប្រដាប់អាវុធត្រូវបានបែងចែកជា២ប្រភេទ គឺជម្លោះប្រដាប់អាវុធ អន្តរជាតិ និងជម្លោះប្រដាប់មិនមានលក្ខណៈអន្តរជាតិ ផ្អែកតាមអនុសញ្ញាទីក្រុងហ្សឺណែវ។ ជម្លោះប្រដាប់អាវុធអន្តរជាតិ គឺជាជម្លោះដែលកើតចេញពីការប្រឈមមុខដាក់គ្នារវាងរដ្ឋមួយ និងបណ្តារដ្ឋមួយទៀត[77] ឬ ជាផ្តល់ជំនួយផ្នែកយោធាពីបណ្តារដ្ឋនៃប្រទេសណាមួយ សម្រាប់ទំនុកបម្រុងដល់ក្រុមប្រដាប់អាវុធប្រឆាំងនឹងរដ្ឋសាមីរបស់ក្រុមប្រដាប់អាវុធនោះ។ រីឯជម្លោះប្រដាប់អាវុធមិនមែនជាលក្ខណៈអន្តរជាតិ គឺសំដៅលើជម្លោះដែលកើតចេញពីការប្រឆាំងតទល់គ្នារវាងរដ្ឋាភិបាល និងក្រុមប្រដាប់អាវុធនៃប្រទេសតែមួយ ឬ ការផ្តល់ជំនួយយោធាពីប្រទេសដទៃឱ្យដល់រដ្ឋាភិបាលដើម្បីប្រឆាំងតទល់នឹងក្រុមប្រដាប់អាវុធនៃប្រទេសនោះ។ លើសពីនេះទៅទៀត បើទោះបីជាគ្មានការទទួលស្គាល់អរិយភាពនៃជម្លោះប្រដាប់អាវុធពីភាគីនៃជម្លោះក៏ដោយក្តី អនុសញ្ញាទីក្រុងហ្សឺណែវនៅតែមានលទ្ធភាពក្នុងការអនុវត្តលើបណ្តារដ្ឋដែលជាភាគីដដែល ព្រោះវាជាការការពារលើប្រយោជន៍បុគ្គល ប្រយោជន៍មនុស្សជាតិជាជាងការបម្រើផលប្រយោជន៍របស់រដ្ឋ។[78] បរិបទនៃជម្លោះប្រដាប់អាវុធនេះ ក៏អនុវត្តចំពោះគ្រប់ករណីនៃការកាន់កាប់ទឹកដីមួយផ្នែក ឬ ទាំងស្រុងរបស់រដ្ឋជាភាគី បើទោះបីជាការកាន់កាប់នោះមិនបានប្រើប្រាស់កម្លាំងប្រដាប់អាវុធក៏ដោយ ដរាបណាជម្លោះប្រដាប់អាវុធនៅតែបន្ត សន្តិភាពរវាងរដ្ឋភាគីមិនទាន់ត្រូវបានរកឃើញ ដូច្នេះជម្លោះប្រដាប់អាវុធនៅតែមានវត្តមានដដែល។[79]

### ២.៣.១.២ ទំនាក់ទំនងរវាងអំពើអមនុស្សធម៌របស់ចារី និងជម្លោះប្រដាប់អាវុធ

ទំនាក់ទំនងរវាងអំពើអមនុស្សធម៌របស់ចារីទៅនឹងជម្លោះប្រដាប់អាវុធ សំដៅដល់ភាពពាក់ព័ន្ធគ្នាយ៉ាងជិតស្និទ្ធតាមរយៈជម្លោះប្រដាប់អាវុធ ដែលជាដើមហេតុបង្កឱ្យមានព្យសន្យកម្មនៃការរំលោភបំពានលើកម្មវត្ថុនៃការការពារក្រោមច្បាប់សង្គ្រាម។ ការឱ្យនិយមន័យនៃទំនាក់ទំនងនៅក្នុងករណីនេះមានភាពខុសប្លែកគ្នា បន្តិចបន្តួចទៅតាមយុត្តិសាស្ត្ររបស់តុលាការនីមួយៗ ដោយអាស្រ័យទៅតាមប្រភេទនៃបទចោទប្រកាន់ដែលព្រះរាជ

[76] ចំណុចនេះនឹងបកស្រាយបញ្ចូលគ្នារវាងធាតុផ្សំទី១ ការកើតមានជម្លោះប្រដាប់អាវុធ និងទី២ ប្រភេទនៃជម្លោះប្រដាប់អាវុធ មកជាជម្លោះប្រដាប់អាវុធជារួម។

[77] Geneva Convention, Common article 2 (អនុសញ្ញាទីក្រុងហ្សឺណែវ, មាត្រា២ រួម)។

[78] សាលក្រម ០០១ ឌុច, E188, កថាខណ្ឌទី ៤១៤។

[79] ប្រភពដូចខាងលើ, កថាខណ្ឌទី៤១១ ដល់ ៤១៥។

អាជ្ញា ឬ រដ្ឋអាជ្ញា បានប្រើប្រាស់ដើម្បីកំណត់ថាតើជម្លោះប្រដាប់អាវុធត្រូវផ្សាភ្ជាប់នឹងអំពើរបស់ចារីយ៉ាងដូចម្តេច? នៅក្នុងករណីខ្លះ ទំនាក់ទំនងរវាងអំពើអមនុស្សធម៌ដែលប្រព្រឹត្តដោយចារី គឺកើតឡើងនៅក្នុងការប្រយុទ្ធគ្នាដោយផ្ទាល់រវាងគូភាគីនៃជម្លោះ មានន័យថាចារីចូលរួមសកម្មភាពបំពានច្បាប់សង្គ្រាមដោយផ្ទាល់។ មួយវិញទៀត ផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការ ICTY ទំនាក់ទំនងនេះមិនមែនសំដៅលើតែការវាយប្រហារនៅក្នុងតំបន់ដែលកំពុងតែមានជម្លោះប្រដាប់អាវុធ ឬ ប្រព្រឹត្តដោយជនជាប់ចោទដែលជាផ្នែកមួយនៃការអនុវត្តគោលនយោបាយ ឬ ធ្វើឡើងដោយភាគីម្ខាងទៀតនៃជម្លោះនោះទេ ពោលគឺឱ្យតែអំពើប្រព្រឹត្តនោះបានកើតឡើងនៅក្នុងអំឡុងពេលកើតមានជម្លោះប្រដាប់អាវុធដោយគ្មានការអើពើ ឬ ការប្រព្រឹត្តិនោះត្រូវបានអនុញ្ញាតពីអាជ្ញាធរគ្រប់គ្រង(ថ្នាក់លើ)ហើយ អំពើនោះ គឺជាគោលនយោបាយដែលគេបានយកមកអនុវត្តចំពោះអ្នកទោស ដូចនេះអំពើនោះនឹងមើលឃើញថាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ។[80]

### ២.៣.១.៣ ការបំពានលើកម្មវត្ថុនៃការការពារក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ

ការបំពានលើកម្មវត្ថុនៃការការពារក្រោមអនុសញ្ញាទីក្រុងហ្សឺណែវ គឺសំដៅដល់អំពើប្រព្រឹត្តប្រឆាំងទៅលើមនុស្ស ឬ ទ្រព្យសម្បត្តិដែលទទួលបានការការពារក្រោមអនុសញ្ញាទីក្រុងហ្សឺណែវដោយអំពើរបស់ចារីនៅអំឡុងពេលកើតមានជម្លោះប្រដាប់អាវុធ។ ស្មារតីនៃអនុសញ្ញានេះ ផ្តោតសំខាន់ទៅលើស្ថានភាពដែលប្រជាជន ឬ ទាហានរបស់រដ្ឋមួយ ត្រូវបានចាប់ខ្លួន ឬ គ្រប់គ្រងដោយទាហាន ក៏ដូចជាក្រុមនៃជម្លោះប្រដាប់អាវុធនោះ ថាតើក្រុមនោះនឹងការពារបុគ្គល និងទ្រព្យសម្បត្តិរបស់រដ្ឋដែលជាគូបដិបក្ខ ឬ ក៏ធ្វើសកម្មភាពបំផ្លិចបំផ្លាញ ឬ សម្លាប់មកលើកម្មវត្ថុនៃការពារ។ សកម្មភាពនៃការបំពានទៅលើបុគ្គល ដែលត្រូវទទួលបានការការពារស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ និងបានកំណត់នៅក្នុងច្បាប់របស់ អ.វ.ត.ក សំដៅដល់៖

- ក- អំពើមនុស្សឃាតដោយចេតនា៖ អំពើមនុស្សឃាតដោយចេតនា គឺជាអំពើសកម្ម ឬ អកម្មរបស់ចារីធ្វើឡើងដោយចេតនាក្នុងគោលបំណងដើម្បីសម្លាប់មនុស្ស និងបង្កគ្រោះថ្នាក់ដល់រាងកាយធ្ងន់ធ្ងររួមទាំងដឹងដោយសមហេតុផលថាទង្វើនេះនឹងបណ្តាលឱ្យជនរងគ្រោះបាត់បង់ជីវិត។[81]
- ខ- ការធ្វើទារុណកម្ម ឬ ការធ្វើបាបដោយអមនុស្សធម៌៖ អំពើទាំងពីរនេះ គឺជាបទល្មើសពីរផ្សេងដាច់ចេញពីគ្នា។ ការធ្វើទារុណកម្ម គឺជាអំពើដែលបង្កឡើងដោយចេតនារបស់ចារីតាមរយៈអំពើសកម្ម ឬ អកម្ម ដែលនាំឱ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រូបកាយ ឬ ផ្លូវចិត្តរបស់ជនរងគ្រោះ។[82] អំពើនេះ ធ្វើ

[80] សាលក្រម ០០១, ឧច, E188, កថាខណ្ឌទី ៤១៦។

[81] ប្រភពដូចខាងលើ, កថាខណ្ឌទី ៣៣១ ដល់ ៣៣៣ និងកថាខណ្ឌទី ៤៣១។ "ធាតុផ្សំនេះដូចគ្នាទៅនឹងធាតុផ្សំនៃមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ"។

[82] ប្រភពដូចខាងលើ, កថាខណ្ឌទី ៣៥៤ ៣៥៥ និង៤៣៩។ "ធាតុផ្សំនេះដូចទៅនឹងធាតុផ្សំឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"។

ឡើងក្នុងគោលបំណង ដើម្បីទទួលបានចម្លើយសារភាពមួយ ពេញលេញនឹងដាក់លាក់ពីជនរងគ្រោះ។[83] រីឯ ការធ្វើបាបដោយអមនុស្សធម៌ គឺជាការប្រព្រឹត្តិដោយចេតនាចេញពីអំពើសកម្ម ឬ អកម្មរបស់ចារីដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ ហើយសកម្មភាពនោះបង្កឱ្យមានព្យសនកម្មផ្លូវចិត្ត ការឈឺចាប់ ឬ រងរបួសផ្នែករាងកាយនឹងស្មារតី។[84]

គ- ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬ ឱ្យមានការឈឺចាប់ដល់រាងកាយ ឬ សុខភាព៖ អំពើនេះ គឺជាសកម្មភាពដែលស្ដែងឡើងតាមរយៈចេតនារបស់ចារីដែលបង្កឱ្យមានការឈឺចាប់ ឬ ព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬ ដោយការធ្វេសប្រហែសទៅលើជនរងគ្រោះ និងមានភស្តុតាងបញ្ជាក់អំពីផលប៉ះពាល់រយៈពេលយូរ។[85]

ឃ- ការបំផ្លាញ ឬ ធ្វើឱ្យខូចខាតធ្ងន់ធ្ងរលើទ្រព្យសម្បត្តិ ដោយមិនមានហេតុផលចាំបាច់ខាងយោធាដែលធ្វើឡើងដោយខុសច្បាប់ និងគ្មានត្រាប្រណី។

ង- ការបង្ខំឱ្យឈ្លើយសឹក ឬ ជនស៊ីវិល បម្រើការនៅក្នុងកងកម្លាំងរបស់គូបដិបក្ខ។

ច- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬ ជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់៖ គឺជាការបំពានសិទ្ធិតាមរយៈការផ្ដន្ទាទោសដោយគ្មានការជំនុំជម្រះ ដោយយុត្តិធម៌ គ្មានប្រព័ន្ធតុលាការ និងមិនផ្ដល់ការធានាតាមផ្លូវតុលាការ ដូចមានចែងនៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវទាក់ទងនឹងសិទ្ធិរបស់ជនជាប់ចោទ។[86] ធាតុផ្សំចាំបាច់នៅក្នុងលក្ខខណ្ឌនេះ រួមបញ្ចូលទាំងសមត្ថភាពខាងឆន្ទៈ និងការធ្វេសប្រហែស។[87]

ឆ- ការនិរទេស ការជម្លៀស ឬ ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់៖ ការឃុំខ្លួនជនស៊ីវិលដោយខុស ច្បាប់ គឺជាដកហូតសិទ្ធិសេរីភាពរបស់ជនស៊ីវិលដោយចេតនា នៅក្នុងស្ថានភាពមួយដែលអាចជឿ បានថាបានមានសុវត្ថិភាព ប៉ុន្តែបែរជាធ្វើការឃុំខ្លួនដោយមិនស្របតាមនីតិវិធីច្បាប់ដែលបានកំណត់។[88]

ជ- ការយកជនស៊ីវិលជាចំណាប់ខ្មាំង។

[83] សាលក្រម ០០១, ឧច, E188, កថាខណ្ឌទី ៣៥៦។ "ជនរងគ្រោះនៅក្នុងករណីនេះគឺសំដៅលើជនរងគ្រោះដែលត្រូវបានចាប់ខ្លួននៅក្នុងអំឡុងពេលកើតមានជម្លោះប្រដាប់អាវុធដោយយោធា ឬ ដោយក្រុមប្រដាប់អាវុធនៃប្រទេសដែលជាសត្រូវ។ ជនរងគ្រោះនឹងត្រូវកាត់ទោស ឬ ដាក់ទណ្ឌកម្ម ដោយមិនស្របច្បាប់ និង គ្មានមូលដ្ឋាននៃការកំណត់ទោសដែលអាចធានានូវសិទ្ធិរបស់ជនជាប់ចោទ។"

[84] ប្រភពដូចខាងលើ, កថាខណ្ឌទី ៤៤០ និង៤៤១។

[85] ប្រភពដូចខាងលើ, កថាខណ្ឌទី ៤៥១។

[86] ប្រភពដូចខាងលើ, កថាខណ្ឌទី ៤៥៩។

[87] ប្រភពដូចខាងលើ, កថាខណ្ឌទី ៤៦០។

[88] ប្រភពដូចខាងលើ, កថាខណ្ឌទី ៤៦៥ និង ៤៦៦។

#### ២.៣.១.៤ ការយល់ដឹងរបស់ជនជាប់ចោទទាក់ទងនឹងជម្លោះប្រដាប់អាវុធ

ការយល់ដឹងរបស់ជនជាប់ចោទទាក់ទងនឹងជម្លោះប្រដាប់អាវុធ សំដៅលើការយល់ដឹងលើអត្ថិភាពនៃជម្លោះប្រដាប់អាវុធ ដែលបានកើតឡើងដោយផ្សារភ្ជាប់នឹងការរំលោភបំពានសិទ្ធរបស់ជនរងគ្រោះក្នុងអំឡុងពេលកើតមានជម្លោះប្រដាប់អាវុធ។[89] ជនជាប់ចោទត្រូវតែមានការយល់ដឹងពីជម្លោះប្រដាប់អាវុធ មិនថាជាលក្ខណៈអន្តរជាតិ ឬ មិនមានជាលក្ខណៈអន្តរជាតិនោះទេ។ មួយវិញទៀត ជនជាប់ចោទត្រូវតែមានការយល់ដឹងថាជនរងគ្រោះ ឬ កម្មវត្ថុដែលជាការបំពាននោះ គឺជាកម្មវត្ថុនៃការការពារស្របតាមអនុសញ្ញាទីក្រុងហ្សឺណែវដែលកម្ពុជាបានក្លាយជារដ្ឋសមាជិក។[90] នេះមានន័យថា អំពើដែលជនជាប់ចោទបានប្រព្រឹត្ត គឺជនជាប់ចោទដឹងយ៉ាងច្បាស់ថាវាផ្ទុយនឹងបទបញ្ញត្តិដែលមានចែងក្នុងច្បាប់សង្គ្រាម។

### ២.៣.២ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ សំដៅដល់ការវាយប្រហារជាទូទៅ ឬ ជាប្រព័ន្ធ ដែលធ្វើឡើងប្រឆាំងនឹងប្រជាជនស៊ីវិលដោយសារមូលហេតុជាតិ នយោបាយ ជាតិពិន្ទុ ពូជសាសន៍ ឬ សាសនាណាមួយ។[91] ក្នុងនោះផងដែរ ធាតុផ្សំដែលអាចចាត់ទុកថាអំពើនោះ គឺជាឧក្រិដ្ឋកម្មប្រឆាំងចាំបាច់ត្រូវតែបង្ហាញដោយភស្តុតាងលើគ្រប់លក្ខខណ្ឌចំនួន៦គឺ[92]៖

១- ការវាយប្រហារ

២- ការវាយប្រហារត្រូវតែមានលក្ខខណៈជាទូទៅ ឬ ជាប្រព័ន្ធ

៣- ការវាយប្រហារសំដៅលើប្រជាជនស៊ីវិល

៤- មូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា

៥- ទំនាក់ទំនងរវាងអំពើរបស់ចារីនិងការវាយប្រហារ និង

៦- ជនជាប់ចោទ ឬ ចារីបានដឹងជាចាំបាច់អំពីការវាយប្រហារ។

#### ២.៣.២.១ ការវាយប្រហារ

ការវាយប្រហារ គឺជាការប្រព្រឹត្តិដោយហិង្សាច្រើន[93] ទៅលើប្រជាជនស៊ីវិល។ រាល់អំពើហិង្សាទាំងអស់មិនរាប់បញ្ចូលថាជាឧក្រិដ្ឋកម្មប្រឆាំងៗនឹងមនុស្សជាតិនោះទេ ដរាបណាការវាយប្រហារនោះមិនស្របតាមមាត្រា

[89] សាលក្រម ០០១ ឧច, E188, កថាខណ្ឌទី ៤២០ ដល់ ៤២២។

[90] ប្រភពដូចខាងលើ, កថាខណ្ឌទី ៤២២។

[91] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា៥។

[92] សាលក្រម ០០១ ឧច, E188, កថាខណ្ឌទី ២៩៧។

[93] ប្រភពដូចខាងលើ, កថាខណ្ឌទី២៩៨។

៥ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក។ ក្នុងលក្ខខណ្ឌនេះ ការវាយប្រហារត្រូវប្រព្រឹត្តឡើងតាមរយៈ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់នៅក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬ សាសនា ឬ អំពើអមនុស្សធម៌ផ្សេងទៀត។[94] ការវាយប្រហារ មិនតម្រូវឱ្យបំពេញគ្រប់សកម្មភាពទាំងអស់នេះនោះទេ ពោលគឺអំពើរបស់ចារីគ្រាន់តែបំពេញគ្រប់ធាតុផ្សំនៃផ្នែកមួយនៃការវាយប្រហារ ដូចជា ការសម្លាប់រង្គាល ក៏ចាត់ទុកថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ។ នៅក្នុងការវាយប្រហារមួយ ក៏អាចកើតមាននូវហិង្សាជាច្រើនដែលប្រឆាំងទៅនឹងជនរងគ្រោះ។[95] សញ្ញាណនៃការវាយប្រហារ មានលក្ខណៈខុសពីជម្លោះប្រដាប់អាវុធ មានន័យថាវាអាចកើតឡើងមុន អាចអូសបន្លាយរយៈពេលយូរ ឬ បន្តមានរហូតក្នុងអំឡុងពេលនៃជម្លោះប្រដាប់អាវុធ។[96]

### ២.៣.២.២ ទម្រង់នៃការវាយប្រហារ

ទម្រង់នៃការវាយប្រហារត្រូវបានបែងចែកជា២ គឺជាការវាយប្រហារលក្ខណៈទូទៅ និងការវាយប្រហារជាប្រព័ន្ធ។ ការវាយប្រហារលក្ខណៈជាទូទៅ សំដៅលើការវាយប្រហារដោយអំពើអមនុស្សធម៌ដែលមានទ្រង់ទ្រាយធំទៅជនរងគ្រោះដែលមានចំនួនច្រើន។[97] រីឯការវាយប្រហារជាប្រព័ន្ធ គឺសំដៅលើហិង្សាដែលមានការរៀបចំ ហើយអំពើនោះមិនអាចកើតឡើងដោយចៃដន្យនោះទេ មានន័យថាជនល្មើសធ្វើសកម្មភាពនោះដដែលៗ ជាប្រព័ន្ធទៅតាមគោលដៅដែលបានកំណត់ទុក។[98]

### ២.៣.២.៣ ការវាយប្រហារសំដៅលើប្រជាជនស៊ីវិល

ជនស៊ីវិល គឺជាជនដែលត្រូវបានសន្មតជាទូទៅថាជាភ្នាក់ងារអនុវត្តច្បាប់សង្គ្រាមរបស់រដ្ឋមួយ ឬ ជាបុគ្គល ដែលមិនអាចកំណត់ឋានៈច្បាស់លាស់ថាជាប្រជាជន ឬ ជាទាហាន។ ផ្ទុយទៅវិញ សមាជិកនៃជម្លោះប្រដាប់ អាវុធ ឬ ទាហាន ដែលបាត់បង់សមត្ថភាពក្នុងការចូលរួមប្រយុទ្ធ មិនត្រូវទទួលបានឋានៈជាជនស៊ីវិលទេ។[99] ប្រជាជន មិនសំដៅលើតែប្រជាជនទាំងអស់ ដែលរស់នៅក្នុងភូមិសាស្ត្រណាមួយនៃការវាយប្រហារនោះទេ ឱ្យតែអាចកំណត់បានថា ប្រជាជននៅក្នុងក្រុមនោះមានចំនួនល្មម គឺអាចកំណត់ជាគោលដៅនៃការវាយប្រហារ ប៉ុន្តែមិនមែនជាចំនួនតិចតួច ឬ ត្រូវបានជ្រើសរើសខ្លះនោះ ត្រូវបានសន្មតថាមានការវាយប្រហារសំដៅលើជនស៊ី

[94] ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក, មាត្រា៥។

[95] សាលក្រម ០០១ ឌុច, E188, កថាខណ្ឌទី២៩៨ ។

[96] ប្រភពដូចខាងលើ, កថាខណ្ឌទី២៩៩។

[97] សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី ១៧៩។ Prosecutor v. Jadranko Prlić, Case No. IT-04-74-T, Judgement (TC), 29 May 2013, paras. 41.

[98] សាលក្រម ០០១ ឌុច, E188, កថាខណ្ឌទី៣០០។

[99] សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី ១៨៥។

វិលនោះទេ។[100] ការវាយប្រហារ មិនសំដៅទៅលើតែការវាយប្រហារពីសត្រូវមកលើប្រជាជនរបស់ប្រទេសមួយប៉ុណ្ណោះទេ ប៉ុន្តែវាក៏ "រួមបញ្ចូលទាំងការវាយប្រហាររបស់រដ្ឋមួយ មកលើប្រជាជននៃរដ្ឋសាមីនោះផងដែរ"[101]។

**២.៣.២.៤ មូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា**

មូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា គឺជាកម្មវត្ថុនៃដែលធ្វើឱ្យកើតមានការវាយប្រហារទៅលើប្រជាជនស៊ីវិល។ ចារីជាអ្នកដែលកំណត់ថា នរណាគឺជាជនរងគ្រោះដែលត្រូវវាយប្រហារ "ដោយសារតែបុគ្គលនោះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ឬ មានសមានចិត្តចំពោះក្រុមជនរងគ្រោះ"[102]។ ប្រសិន បើបុគ្គលទាំងនោះត្រូវបានសង្ស័យថាជាសមាជិកនៃក្រុមសាសនា នយោបាយ ជាតិពន្ធុ ជនរងគ្រោះក៏អាចជាមូលហេតុនៃការរើសអើងផងដែរ។[103] ធាតុផ្សំនៃការរើសអើងនឹងត្រូវបានបំពេញ បើទោះបីជាមានការបង្ហាញភស្តុតាងនៃការសង្ស័យនោះមិនត្រឹមត្រូវក៏ដោយ។ ដោយហេតុថា ការសន្មតរបស់ចារីទៅក្រុមបុគ្គលទាំងនោះបាន លេចចេញនូវការវាយប្រហាររួចទៅហើយ ទោះបីជាចំណាត់ថ្នាក់ដែលចារីកំណត់ទៅជនរងគ្រោះមិនត្រឹមត្រូវ តាមលក្ខខណ្ឌសត្យានុម័តក្តី ក៏ទង្វើរបស់ចារីនៅតែជាមូលដ្ឋាននៃការរើសអើង។[104]

**២.៣.២.៥ ទំនាក់ទំនងរវាងអំពើរបស់ចារីនិងការវាយប្រហារ**

ការវាយប្រហារត្រូវតែកើតចេញពីអំពើរបស់ចារី មិនថាការវាយប្រហារនោះជាអំពើប្រភេទណាក៏ដោយ[105] ប្រសិនបើអំពើរបស់ចារីទាក់ទងនឹងការវាយប្រហារមិនទាន់បញ្ឈប់ទាំងស្រុងទេនោះ អំពើរបស់ចារីនៅតែមានទំនាក់ទំនងនឹងការវាយប្រហារ។ លក្ខខណ្ឌនេះ ទាមទារឱ្យមានទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងអំពើរបស់ចារី និងកម្មវត្ថុនៃការវាយប្រហារតាមរយៈ "ការពិចារណាលើបរិបទ និងកាលៈទេសៈដែលបទល្មើសនោះ ត្រូវបានប្រព្រឹត្តឡើង"[106]។ នៅក្នុងករណីដែលវាមានភាពដាច់ដោយឡែកពីគ្នាពីការវាយប្រហារ និងចេតនារបស់ចារី នោះមិនចាត់ទុកថាមានទំនាក់ទំនងរវាងអំពើ និងការវាយប្រហារនោះទេ។

**២.៣.២.៦ ការយល់ដឹងជាចាំបាច់របស់ជនជាប់ចោទអំពីការវាយប្រហារ**

ការយល់ដឹងរបស់ចារីទាក់ទងនឹងការវាយប្រហារ គឺមិនចាំបាច់ទាល់តែចារីបានដឹងលម្អិតពីការវាយប្រហារ ឬរួមចំណែកដឹងពីគោលបំណង ឬ គោលដៅនៃការវាយប្រហារនោះទេ[107] ឱ្យតែដឹងថាមានការវាយប្រហារ

---

[100] សាលក្រម ០០១ ឌុច, E188, កថាខណ្ឌទី ៣០៣។

[101] ប្រភពដូចខាងលើ, កថាខណ្ឌទី ៣១២។

[102] ប្រភពដូចខាងលើ, កថាខណ្ឌទី ៣១៧។

[103] ប្រភពដូចខាងលើ, កថាខណ្ឌទី ៣១៧។

[104] ប្រភពដូចខាងលើ, កថាខណ្ឌទី ៣១៧។

[105] សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី ១៩០។

[106] សាលក្រម ០០១ ឌុច, E188, កថាខណ្ឌទី ៣១៨។

[107] សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី ១៩១។

លើជនស៊ីវិល ហើយអំពើរបស់ចារីក៏ជាផ្នែកមួយនៃការវាយប្រហារ។ ចំពោះការអះអាងភស្តុតាងទាក់ទងនឹងការយល់ដឹងគឺវាអាស្រ័យទៅលើប្រភេទនៃបទល្មើសដែលបានប្រព្រឹត្ត ស្របតាមមាត្រា៥ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក តាមកាលៈទេសៈជាក់ស្តែង។

### ២.៣.៣ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

អំពើប្រល័យពូជសាសន៍ គឺជាបទឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុត ដោយការបំផ្លិចបំផ្លាញ ឬ កម្ទេចចោល ឬ សម្លាប់ ក្រុមមនុស្សមួយក្រុមទៅតាមអម្បូរ និងសាសនាមិនឱ្យមានវត្តមានតទៅទៀត។ ចំពោះអំពើនេះ បើទោះបីជាកើតឡើងក្នុងពេលមានសន្តិភាព ឬ នៅពេលមានសង្គ្រាមក្តី ក៏វានៅតែជាឧក្រិដ្ឋកម្មតាមលក្ខណៈច្បាប់អន្តរជាតិ។[108] ផ្អែកតាមមាត្រា៤ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក លក្ខខណ្ឌដែលចាត់ទុកថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ លុះត្រាតែអំពើនោះកើតឡើងក្នុងគោលបំណង ដើម្បីបំផ្លេចបំផ្លាញទាំងស្រុង ឬ មួយផ្នែកនៃប្រជាជាតិ ក្រុមជាតិពន្ធុ ពូជសាសន៍ ឬ សាសនា។ ហេតុនេះ ធាតុផ្សំចំនួន៣ ដែលកំណត់ថាជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានបំពេញ ដែលមានដូចជា[109]៖

១- គោលដៅនៃការបំផ្លាញ

២- ធាតុផ្សំសត្យានុម័តនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

៣- ធាតុផ្សំអត្តនោម័តនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

#### ២.២.៣.១ គោលដៅនៃការបំផ្លាញ

ការបំផ្លាញ គឺត្រូវតែសំដៅទៅលើក្រុមដែលទទួលបានការការពារក្រោមអនុសញ្ញាស្តីពីការបង្កា និង ផ្តន្ទាទោសចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ក្រុមទាំងនោះ សំដៅទៅលើប្រជាជាតិមួយក្រុម ជាតិពន្ធុមួយ ក្រុមជាតិសាសន៍មួយ ឬ ក្រុមសាសនាមួយ។[110] នៅ អ.វ.ត.ក អង្គជំនុំជម្រះយល់ឃើញថាលក្ខខណ្ឌដែលអាចកំណត់ថា ក្រុមនោះជាក្រុមដែលទទួលបានការការពារ លុះត្រាតែបំពេញធាតុផ្សំពីរផ្សេងទៀតគឺ ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។ ធាតុសត្យានុម័ត គឺផ្អែកតាមការកំណត់អត្តសញ្ញាណជាក់លាក់លើក្រុមមួយដែលមានលក្ខណៈខុសប្លែកពីក្រុមទូទៅ។ រីឯធាតុអត្តនោម័ត គឺជាវិធីដែលចារីធ្វើឱ្យសមាជិកនៃក្រុមនោះក្លាយទៅជាជនរងគ្រោះ ឬ វិធីដែលធ្វើឱ្យសមាជិកនៃក្រុមនោះយល់ឃើញថាពួកគេ គឺជាជនរងគ្រោះ។[111]

[108] អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, មាត្រា១។

[109] សាលក្រម ០០២/០២ នួនជា និង ខៀវសំផន, E465, កថាខណ្ឌទី ៧៩០ ដល់ ៨០៥។

[110] អនុសញ្ញាស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍, មាត្រា២។

[111] សាលក្រម ០០២/០២ នួនជា និង ខៀវសំផន, E465, កថាខណ្ឌទី ៧៩៥។

### ២.៣.៣.២ ធាតុផ្សំសត្យានុម័តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

ធាតុផ្សំសត្យានុម័ត សំដៅលើទង្វើជាមូលដ្ឋានរួមទាំងទង្វើពិសេសរបស់ចារី។ ទង្វើជាមូលដ្ឋានរួមមាន ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម[112] ការធ្វើឱ្យរបួសយ៉ាងធ្ងន់ធ្ងរដល់រូបរាងកាយ ឬ សតិបញ្ញា ទៅលើសមាជិកនៃក្រុមការធ្វើដោយចេតនា ដើម្បីឱ្យក្រុមនេះទទួលរងនូវស្ថានភាពរស់នៅមួយដែលបានរៀបចំឡើងសម្រាប់បំផ្លិចបំផ្លាញរាងកាយទាំងស្រុង ឬ មួយផ្នែក ដូចជាការដាក់នូវិធានការនានាដែលមានបំណងរារាំងមិនឱ្យមានការផ្តល់កំណើតទារក ឬ ការបញ្ជូនកុមារដោយបង្ខំពីក្រុមមួយទៅឱ្យក្រុមមួយផ្សេងទៀតជាដើម។[113]

### ២.៣.៣.៣ ធាតុអត្តនោម័តនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

ធាតុអត្តនោម័តរបស់ចារី សំដៅលើចេតនាពិសេស ឬ ចេតនាជាក់លាក់របស់ចារី ក្នុងការបំផ្លិចបំផ្លាញទៅលើក្រុមមនុស្សដែលទទួលបានការការពារ។ ការសន្និដ្ឋានអំពីចេតនាជាក់លាក់ "ត្រូវធ្វើឡើងដោយមានហេតុផលសមរម្យ និងផ្អែកលើភស្តុតាង"[114] ដោយពិចារណាលើ "បរិបទទូទៅនៃការប្រព្រឹត្តិបទល្មើសផ្សេងៗដែលបានប្រព្រឹត្តឡើងជាប្រព័ន្ធសំដៅប្រឆាំងនឹងក្រុមតែមួយ ទំហំនៃអំពើឃោរឃៅដែលបានប្រព្រឹត្ត ការកំណត់ជនរងគ្រោះធ្វើជាគោលដៅជាលក្ខណៈប្រព័ន្ធ ដោយសារសមាជិកភាពរបស់ពួកគេស្ថិតក្នុងក្រុមណាមួយ ឬ ការប្រព្រឹត្តិជាបន្តបន្ទាប់នូវសកម្មភាពបំផ្លិចបំផ្លាញ និងការរើសអើង"[115]។ មួយវិញទៀត ធាតុផ្សំចាំបាច់នៃចេតនា ជាក់លាក់របស់ចារី គឺផ្អែកលើស្ថានភាពផ្លូវចិត្តរបស់ចារី ជាមួយនឹងសមាជិកផ្សេងទៀតនៃសហឧក្រិដ្ឋកម្មរួម មិនសំដៅ តែទៅលើចេតនាផ្ទាល់នៃអំពើទាំងឡាយរបស់ចារីនោះទេ។[116]

---

[112] សាលក្រម ០០២/០២ នួនជា និង ខៀវសំផន, E465, កថាខណ្ឌទី ៧៩៧។ "ធាតុផ្សំសត្យានុម័តទៅលើបទល្មើសមួយនេះ មិនតម្រូវឱ្យមានការវាយតម្លៃជាតួលេខទៅលើមនុស្សដែលត្រូវបានសម្លាប់ និងកំណត់ចំនួននោះទេ គឺវាផ្អែកលើការប្រព្រឹត្តិចំពោះសមាជិកម្នាក់ ឬ ច្រើននាក់នៃក្រុមធៀបនឹងចំនួនសមាជិកនៃក្រុមនោះ"។

[113] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា៤។

[114] សាលក្រម ០០២/០២ នួនជា និង ខៀវសំផន, E465, កថាខណ្ឌទី ៨០៣។

[115] ប្រភពដូចខាងលើ។

[116] ប្រភពដូចខាងលើ, កថាខណ្ឌទី ៨០៤។

# ជំពូកទី ៣

# ចំណាត់ការរបស់អង្គជំនុំជម្រះវិសាមញ្ញ ក្នុងតុលាការកម្ពុជាលើរឿងក្តីខ្មែរក្រហម

# ជំពូកទី ៣

# ចំណាត់ការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាលើរឿងក្តីខ្មែរក្រហម

នៅក្នុងចំណាត់ការរបស់ អ.វ.ត.ក ទៅលើរឿងក្តីខ្មែរក្រហម អ្វីដែលគួរឱ្យកត់សម្គាល់ក្រៅតែពីសមាសភាពអន្តរជាតិនោះ គឺការស្វែងរកយុត្តិសាស្ត្រដែលជាបទដ្ឋានគតិយុត្តស្ថិតក្នុងកម្រិតអន្តរជាតិមកធ្វើជាមូលដ្ឋានក្នុងការបកស្រាយច្បាប់ នៅក្នុងករណីដែលអវត្តមាន ឬ ពុំមានភាពច្បាស់លាស់នៃច្បាប់កម្ពុជា។ មានន័យថាចៅក្រមមានឆន្ទានុសិទ្ធិក្នុងការបកស្រាយច្បាប់ដោយផ្អែកលើយុត្តិសាស្ត្ររបស់តុលាការផ្សេងៗ នៅពេលដែលច្បាប់ជាតិមានចន្លោះខ្វះខាត យោងតាមមាត្រា៣៣ថ្មី វាក្យខណ្ឌ២ នៃច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

ក្នុងជំពូកនេះ នឹងសិក្សាអំពីពិរុទ្ធភាពរបស់ជនជាប់ចោទ ក៏ដូចជាមូលហេតុនៃការទទួលខុសត្រូវ និងចុងក្រោយគឺការប្រកាសអំពីទណ្ឌកម្មផ្នែកព្រហ្មទណ្ឌ និងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងសំណុំរឿងលេខ ០០១ និងសំណុំរឿងលេខ ០០២ តែប៉ុណ្ណោះ ដោយពុំស្វែងយល់អំពីយុត្តិសាស្ត្រដែលតុលាការយកមកប្រើប្រាស់ក្នុងការបកស្រាយច្បាប់នោះទេ។ គប្បីបញ្ជាក់ថាទោសព្រហ្មទណ្ឌដែល អ.វ.ត.ក មានសិទ្ធិប្រកាសទៅលើជនជាប់ចោទបែងចែកចេញជា ទោសដាក់ពន្ធនាគារ ដែលមានអប្បបរមាកំណត់ត្រឹម ០៥ឆ្នាំ ដល់មួយជីវិត និងការរឹបអូសទ្រព្យសម្បត្តិមានចលនវត្ថុ និងអចលនវត្ថុ ក៏ដូចជាលុយកាក់ដែលទទួលបានដោយខុសច្បាប់ ឬ បានដោយការប្រព្រឹត្តិអំពើឧក្រិដ្ឋកម្ម ហើយទ្រព្យដែលរឹបអូសនឹងត្រូវប្រគល់ជូនរដ្ឋ។[117]

## ៣.១ សំណុំរឿងលេខ ០០១ កាំង ហ្គេចអ៊ាវ ហៅ ឌុច

### ៣.១.១ ពិរុទ្ធភាពរបស់ជនជាប់ចោទដែល អ.វ.ត.ក បានរកឃើញ

អ.វ.ត.ក បានរកឃើញអំពីពិរុទ្ធភាពលើជនជាប់ចោទ កាំង ហ្គេចអ៊ាវ ពាក់ព័ន្ធនឹងបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩។

#### ៣.១.១.១ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលប្រព្រឹត្តដោយ កាំង ហ្គេចអ៊ាវ

មន្ទីរស២១ ត្រូវបានបង្កើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពោលគឺចាប់ផ្តើមធ្វើប្រតិបត្តិការពេញលេញក្នុងខែតុលា ឆ្នាំ១៩៧៥ ប្រមាណជាកន្លះឆ្នាំក្រោយពីខ្មែរក្រហមបានវាយចូលកាន់កាប់ទីក្រុងភ្នំពេញបានដោយជោគជ័យ។[118] មន្ទីរស២១ ដែលគ្របដណ្តប់ទៅលើ ស២៤ និងជើងឯក ជាផ្នែកមួយដ៏សំខាន់ស្ថិតក្នុងរចនាសម្ព័ន្ធនៃបក្សកុម្មុយនីស្តកម្ពុជា ហើយជាទីកន្លែងដែលធ្វើការវាយប្រហារជាលក្ខណៈទូទៅ និងជាប្រព័ន្ធ

---

117 ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ៣៩ថ្មី។

118 សាលក្រម ០០១ ឌុច, E188, កថាខណ្ឌទី ១១៩។

ដែលមានទម្រង់ជាឧក្រិដ្ឋកម្មទៅលើបុគ្គលមិនរើសមុខ។ ការធ្វើទុក្ខបុកម្នេញមិនរើសមុខ[119] ស្តែងឡើងក្រោមរូបភាពនៃការចាប់ និងបញ្ជូនខ្លួនមកកាន់មន្ទីរស២១ ឬ ស២៤ ដែលជនទាំងនោះត្រូវបានសន្មតថាជាខ្មាំង មានជាអាទិ៍ អតីតមន្ត្រី និងទាហាននៃរបបសាធារណរដ្ឋខ្មែរ និស្សិត បញ្ញវន្ត ព្រះសង្ឃ ជនបរទេស និងជនជាតិភាគតិច ហើយបន្ទាប់មកក៏មានការបោសសម្អាតផ្ទៃក្នុងបក្សដោយមានការចាប់ខ្លួន យុទ្ធជន និងកម្មាភិបាលនៃបក្សកុម្មុយនីស្ត ក្រោមហេតុផលថា មានបំណងប្រឆាំងនឹងគោលនយោបាយបក្សកុម្មុយនីស្ត ឬ មានទំនាក់ទំនងជាមួយនឹងភ្នាក់ងារស៊ើបការណ៍សម្ងាត់នៃរដ្ឋបរទេស ជាអាទិ៍ ស៊ីអាយអេ (CIA) ខេជីប៊ី (KGB) និងរដ្ឋការវៀតណាមជាដើម។[120]

អ្នកជាប់ឃុំនៅមន្ទីរស២១ ប្រមាណជា ១២,២៧២នាក់ ត្រូវបានសម្លាប់ដោយបុគ្គលិករបស់មន្ទីរ ក្រោមការគ្រប់គ្រងរបស់ កាំង ហ្កេចអ៊ាវ។[121] អាស្រ័យហេតុនេះ អ.វ.ត.ក បានកំណត់ថាអំពើនេះគឺជាការធ្វើមនុស្សឃាត និងសម្លាប់រង្គាល ដោយសំអាងទៅលើចំនួននៃការសម្លាប់អ្នកជាប់ឃុំដ៏ច្រើនសន្ធឹកសន្ធាប់។ បន្ថែមពីនេះ បុគ្គលដែលជាប់ឃុំនៅស២៤ តម្រូវឱ្យធ្វើពលកម្មដែលបានដាក់ចេញដោយអង្គភាពនៃមន្ទីរស២១ ដោយគ្មានសិទ្ធិក្នុងការតវ៉ាឡើយ។[122] ទង្វើនេះបង្កើតបានជាអំពើទាសភាព ស្តែងក្រោមសកម្មភាពនៃការឃុំខ្លួន និងបង្ខំឱ្យធ្វើការងារ។ ការរំលោភបំពាននូវសិទ្ធិសេរីភាពរបស់មនុស្សយ៉ាងធ្ងន់ធ្ងរ ក៏បានកើតមានឡើងតាមរយៈការចាប់ខ្លួន និងឃុំខ្លួនដោយគ្មានមូលហេតុផ្លូវច្បាប់។

មន្ទីរស២១ ក៏ចាត់ទុកជាទីកន្លែងសម្រាប់ប្រមូលចម្លើយពីអ្នកជាប់ឃុំឃាំង ដោយការប្រើប្រាស់នូវអំពើអមនុស្សធម៌ដើម្បីទទួលបានចម្លើយ ហើយដែលទង្វើនេះត្រូវបានចាត់ទុកជាការធ្វើទារុណកម្មយ៉ាងព្រៃផ្សៃទៅលើមនុស្ស ក៏មានផងដែលអំពើរំលោភបំពានផ្លូវភេទ[123] ដែលជាទម្រង់នៃការធ្វើទារុណកម្ម។ បុគ្គលិកនៃមន្ទីរបានប្រើប្រាស់នូវឧបករណ៍ដែលនាំឱ្យមានព្យសនកម្មដល់រូបរាងកាយ ផ្លូវចិត្ត ក្រោមរូបភាពនៃការវាយដំ ដកក្រចក ការឆក់ខ្សែភ្លើង។ល។[124] លើសពីនេះ ស្ថានភាពដែលបុគ្គលិកមន្ទីរស២១ បានប្រព្រឹត្តអំពើទៅលើអ្នក

[119] សាលដីកា ០០១ ឌុច, F28, កថាខណ្ឌទី ២៨៤។ "អង្គជំនុំជម្រះតុលាការកំពូល បានកែតម្រូវសេចក្តីសន្និដ្ឋានរបស់អង្គជំនុំសាលាដំបូងពី ការធ្វើទុក្ខបុកម្នេញនយោបាយ មកជាការធ្វើទុក្ខបុកម្នេញដោយមិនរើសមុខវិញ"

[120] សាលក្រម ០០១ ឌុច, E188, កថាខណ្ឌទី ៣៨៣ ដល់៣៨៧។

[121] ប្រភពដូចខាងលើ, កថាខណ្ឌទី ៣៤០។

[122] ប្រភពដូចខាងលើ, កថាខណ្ឌទី ៣៤៦។

[123] ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ, សហចៅក្រមស៊ើបអង្កេត, ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨, កថាខណ្ឌទី ១៣៧។ "ភស្តុតាងដែលមាននៅក្នុងសំណុំរឿងបានបង្ហាញថាយ៉ាងហោចមានករណីរំលោភមួយដែលបានកើតឡើងនៅក្នុងមន្ទីរស២១"

[124] សាលក្រម ០០១ ឌុច, E188, កថាខណ្ឌទី ៣៦០។

ជាប់ឃុំ មានជាអាទិ៍ដូចជា ការដាក់ខ្នោះ ឬ ច្រវាក់ កង្វះខាតម្ហូបអាហារ កង្វះអនាម័យ និងការថែទាំសុខភាពជាដើម គឺជាត្រូវបានកំណត់ថាជាជាអំពើអមនុស្សធម៌។[125]

ជារួម កាំង ហ្កេចអ៊ាវ ជាប់ពាក់ព័ន្ធនឹងសកម្មភាព ដូចជា ការធ្វើទុក្ខបុកម្នេញ អំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម (រួមទាំងការរំលោភផ្លូវភេទមួយករណី) និងអំពើអមនុស្សធម៌ដទៃទៀត ដែលបានធ្វើឡើងចំពោះអ្នកជាប់ឃុំក្នុងមន្ទីរស២១។ រីឯ ចេតនា និងការដឹងរបស់ កាំង ហ្កេចអ៊ាវ អំពីហេតុការណ៍ដែលបានកើតឡើង ត្រូវបានបង្ហាញតាមរយៈសកម្មភាពនៃចូលរួមជាមួយថ្នាក់ដឹកនាំនៃបក្សកុម្មុយនីស្តក្នុងការបង្កើតមន្ទីរស២១ និងការអនុវត្តនូវគោលនយោបាយរបស់បក្សយ៉ាងយកចិត្តទុកដាក់រហូតទទួលបានការផ្តល់នូវសេចក្តីទុកចិត្តពីថ្នាក់លើ ដោយទទួលបាននូវតួនាទីដ៏មានឥទ្ធិពលមួយ គឺជាលេខានៃមន្ទីរសន្តិសុខ ២១។

### ៣.១.១.២ ការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ១៩៤៩ ដែលប្រព្រឹត្តដោយ កាំង ហ្កេច អ៊ាវ

ក្នុងចំណោមអ្នកជាប់ឃុំនៅមន្ទីរស២១ មានបុគ្គលប្រហែល ៤00នាក់ ដែលត្រូវបានចាត់ទុកជាជនដែលស្ថិតក្រោមការការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ មានដូចជា ឈ្លើយសឹកដែលត្រូវចាប់បានខ្លួននៅសមរភូមិ ជនស៊ីវិលវៀតណាមដែលរងការចោទប្រកាន់ថាជា "គិញ" និងខ្មែរដែលមានទំនោរទៅខាងវៀតណាម ត្រូវបានស្លាប់ដោយសារតែលក្ខខណ្ឌនៃការឃុំខ្លួន ឬ សម្លាប់ចោលដោយបុគ្គលិករបស់មន្ទីរ។[126]

អំពើទារុណកម្មក៏បានកើតចំពោះជនប្រភេទនេះ ដូចគ្នាទៅនឹងអ្នកជាប់ឃុំដទៃទៀតដែរ ប៉ុន្តែអាចមានកម្រិតស្រាលជាងពួកអ្នកទាំងនោះ។ ដោយសារតែគោលបំណងគឺ គ្រាន់តែដើម្បីយកសំឡេងពួកគេទៅចាក់ផ្សាយតាមវិទ្យុតែប៉ុណ្ណោះ។[127] ប៉ុន្តែបើទោះបីជាទារុណកម្មមានលក្ខណៈមិនសូវធ្ងន់ធ្ងរក៏ដោយក្តី តែស្ថានភាពនៃការឃុំខ្លួន និងវិធីសាស្ត្រក្នុងការសួរចម្លើយដោយបង្ខំទៅលើជនទាំងនេះ បង្ហាញឱ្យឃើញពីអំពើអមនុស្សធម៌ដែលបំពានទៅនឹងសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។ លក្ខខណ្ឌនៃការឃុំខ្លួន ក៏មិនខុសពីអ្នកឃុំឃាំងដទៃទៀត ពោលគឺពួកគេទទួលរងនូវការវាយដំ ការដាក់ខ្នោះ ឬ ច្រវាក់ ការហូបចុកមិនសមរម្យ កង្វះអនាម័យ និងមិនទទួលបានការមើលថែព្យាបាលដែលបណ្តាលឱ្យប៉ះពាល់ដល់ផ្លូវកាយ និងផ្លូវចិត្តជាទម្ងន់។ មិនតែប៉ុណ្ណោះ ឈ្លើយសឹក និងជនស៊ីវិល ត្រូវបានឃុំខ្លួនដោយខុសច្បាប់ និងមិនទទួលបាននូវសិទ្ធិកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ឡើ

[125] សាលក្រម ០០១ ឌុច, E188, កថាខណ្ឌទី ៣៧០។

[126] ប្រភពដូចខាងលើ, កថាខណ្ឌទី ៤២៥ និង ៤៣៣ ដល់ ៤៣៧។

[127] ប្រភពដូចខាងលើ, ទំព័រ២៦១, កថាខណ្ឌទី ៤៤៦។

យ។[128] មានន័យថា ឈ្លើយសឹក និងជនស៊ីវិលដែលស្ថិតក្រោមការការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវមិនមានសិទ្ធិក្នុងការតវ៉ា ឬ ដឹងអំពីមូលហេតុនៃចាប់ខ្លួន និងឃុំខ្លួនឡើយ ពោលគឺសិទ្ធិរបស់ពួកគេត្រូវបានរំលោភបំពានយ៉ាងធ្ងន់ធ្ងរ ហើយអ្វីដែលពួកគេនឹងត្រូវជួបប្រទះនោះគឺការស្លាប់ដោយសារលក្ខខណ្ឌនៃការឃុំខ្លួន ឬ ការសម្លាប់ចោលក្រោយពីប្រមូលបាននូវព័ត៌មានគ្រប់គ្រាន់។

អ្វីដែលសំខាន់នោះគឺ កាំង ហ្កេចអ៊ាវ បានដឹងអំពីវត្តមាននៃបុគ្គលដែលត្រូវទទួលបានការការពារ ដោយសំអាងទៅលើសកម្មភាពជាសត្យានុម័តដែលខ្លួនបានបញ្ជាឱ្យបុគ្គលិកក្រោមបង្គាប់ នាំជនជាតិវៀតណាមដែលចាប់បានពីសមរភូមិមកកាន់មន្ទីរស២១ និងបានដឹងអំពីហេតុការណ៍ដែលបក្សកុម្មុយនីស្តធ្វើសកម្មភាពបោសសម្អាតជនទាំងឡាយណាដែលពាក់ព័ន្ធជាមួយនឹងបរទេសជាដើម។ និយាយម្យ៉ាងទៀតថា ជនជាប់ចោទ បានដឹងថាបុគ្គលទាំងនោះគឺជាឈ្លើយសឹក ឬ ជាជនស៊ីវិលវៀតណាម ប៉ុន្តែខ្លួននៅតែធ្វើសកម្មភាពដែលនាំប៉ះពាល់ដល់ក្រុមមនុស្សដែលស្ថិតក្រោមកិច្ចការពារដោយអនុសញ្ញាទីក្រុងហ្សឺណែវ តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ដែលបណ្តាលឱ្យប៉ះពាល់ដល់ផ្លូវកាយ ផ្លូវចិត្ត និងការបំពានសិទ្ធិរបស់ពួកគេ។

### ៣.១.២ ការទទួលខុសត្រូវរបស់ជនជាប់ចោទ

មូលហេតុដែល កាំង ហ្កេចអ៊ាវ ត្រូវទទួលខុសត្រូវចំពោះបទល្មើសឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ ដោយហេតុថា កាំង ហ្កេចអ៊ាវ ជាប់ពាក់ព័ន្ធនឹងសកម្មភាពនៃការចូលរួមបង្កើតមន្ទីរស២១ ជាមួយនឹងថ្នាក់ដឹកនាំដទៃទៀត ដោយដឹងយ៉ាងច្បាស់ថាមន្ទីរនេះនឹងក្លាយទៅជាទីកន្លែងសម្រាប់ប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ក៏ដូចជាបានជួយជ្រំជ្រែងឱ្យដំណើរការប្រព្រឹត្តិទៅនៃមន្ទីរនេះកាន់តែមានភាពល្អប្រសើរឡើង។ ទង្វើនេះ តម្រូវឱ្យជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មទាំងនេះក្រោមទម្រង់ជាប្រព័ន្ធនៃសហឧក្រិដ្ឋកម្មរួម។[129]

ក្នុងនាមជាលេខានៃមន្ទីរស២១ ជនជាប់ចោទបានដឹង និងមានចេតនាឱ្យអំពើឃោរឃៅកើតមានឡើងតាមរយៈការបញ្ជាឱ្យអ្នកថ្នាក់ក្រោមអនុវត្តនូវគោលនយោបាយរបស់បក្សទៅលើបុគ្គលជាប់ឃុំដូចជា ការបញ្ជាឱ្យធ្វើទារុណកម្ម ចាប់ខ្លួន និងសម្លាប់ជាដើម ដែលសកម្មភាពទាំងនោះសុទ្ធសឹងតែជាបទឧក្រិដ្ឋ។[130] ទិដ្ឋភាពមួយទៀត គឺជនជាប់ចោទបានធ្វើសកម្មភាពញុះញ៉ង់ដើម្បីជំរុញឱ្យកើតបទល្មើស ដោយការបង្កើតនូវវគ្គបំពាក់បំប៉ននូវទ្រឹស្តីមនោគមន៍វិជ្ជាដល់បុគ្គលិកមន្ទីរ ក្នុងគោលបំណងលើកទឹកចិត្ត និងដាស់ស្មារតីពួកគេឱ្យអនុវត្តនូវភារកិច្ច

128 សាលក្រម ០០១ ឧច, E188, កថាខណ្ឌទី ៤៥៩។

129 ប្រភពដូចខាងលើ, កថាខណ្ឌទី ៥១៤ ដល់ ៥១៧។

130 ប្រភពដូចខាងលើ, កថាខណ្ឌទី ៥៥១។

ស្របតាមនយោបាយដែលជាមាគ៌ាបក្ស។[131] ទង្វើរបស់ជនជាប់ចោទ គឺជាកត្តាលីករក្នុងការជំរុញឱ្យអំពើល្មើស កាន់តែមានលទ្ធផលជាវិជ្ជមាន។

ជារួម ក្នុងនាមជនជាប់ចោទជាថ្នាក់លើ និងមានសិទ្ធិអំណាចអាចប្រើប្រាស់បានយ៉ាងមានប្រសិទ្ធភាព គឺពិតជាបានដឹងអំពីឧក្រិដ្ឋកម្មដែលកើតមាននៅក្នុងមន្ទីរនេះ ហើយគ្មានចេតនាក្នុងការបញ្ឈប់ ឬ ទប់ស្កាត់ទង្វើ ដែលបង្កឱ្យក្លាយទៅជាសោកនាដកម្មនោះទេ ពោលគឺមានតែជំរុញឱ្យកើតមានបន្ថែម។ អាស្រ័យហេតុ មាន ធាតុផ្សំគ្រប់គ្រាន់ ដើម្បីដាក់បន្ទុកទៅលើជនជាប់ចោទឱ្យទទួលខុសត្រូវចំពោះបទល្មើសព្រហ្មទណ្ឌទាំងនេះ។

### ៣.១.៣ ការបដិសេធរបស់ជនជាប់ចោទចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌ

ការធ្វើតាមបញ្ជារបស់ថ្នាក់លើ ឬ ក្រោមការបង្ខិតបង្ខំត្រូវបាន កាំង ហ្កេចអ៊ាវ លើកឡើងជាមូលហេតុ ដើម្បីឱ្យ អ.វ.ត.ក ពិចារណារឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ឬ ទទួលបានការពិចារណាលើស្ថាន សម្រាលទោស មានន័យថាខ្លួនបានធ្វើសកម្មភាពក្រោមការបញ្ជារបស់អាជ្ញាធរ ឬ ស្ថិតក្នុងកាលៈទេសៈដែលធ្វើ អំពើល្មើសដោយសារឥទ្ធិពលក្រៅឆន្ទៈ ដើម្បីការពារផលប្រយោជន៍ខ្លួនជាដើម។ ជាគោលការណ៍ព្រហ្មទណ្ឌ បុគ្គលដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរ ឬ ក្រោមការបង្ខិតបង្ខំ ពុំទទួលខុសត្រូវព្រហ្មទណ្ឌ ឬ អាចជា មូលហេតុក្នុងការទទួលបាននូវស្ថានសម្រាលទោស។ ប៉ុន្តែ យោងតាមមាត្រា ២៩ថ្មី កថាខណ្ឌទី៤ នៃច្បាប់ស្តី វិសោធនកម្មនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានបញ្ញត្តិថា៖

> ប្រការដែលថា ជនសង្ស័យបានប្រព្រឹត្តអំពើឧក្រិដ្ឋកម្មទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជា ធិបតេយ្យ ឬ របស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះឱ្យរួចផុតពីការទទួលខុសត្រូវ ចំពោះបទឧក្រិដ្ឋកម្មនេះបានឡើយ។

ផ្អែកតាមខ្លឹមសារនៃមាត្រាខាងលើនេះ ការលើកឡើងអំពីការប្រព្រឹត្តិអំពើល្មើសតាមការបញ្ជារបស់ថ្នាក់ លើពុំអាចជួយឱ្យ កាំង ហ្កេចអ៊ាវ រួចផុតពីការទទួលខុសត្រូវបានឡើយ។ ការចែងបែបនេះ គឺស្របទៅនឹងយុត្តិ សាស្ត្ររបស់តុលាការអន្តរជាតិ ក៏ព្រោះតែបទល្មើសទាំងនេះសុទ្ធតែជាឧក្រិដ្ឋកម្មដែលមានចរិតធ្ងន់ធ្ងរ។ ប៉ុន្តែ ចំពោះការលើកឡើងអំពីបញ្ហាពាក់ព័ន្ធនឹងការបង្ខិតបង្ខំ ផ្អែកតាមតុលាការអន្តរជាតិគឺ "ការបង្ខិតបង្ខំមិនអាចគ្រប់ គ្រាន់សម្រាប់ការពារជនជាប់ចោទឱ្យរួចផុតពីការចោទប្រកាន់ទាំងស្រុងពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬ ឧក្រិដ្ឋ កម្មសង្គ្រាម ដែលពាក់ព័ន្ធនឹងការសម្លាប់ជីវិតជនស្លូតត្រង់នោះទេ ប៉ុន្តែគេអាចយកមកពិចារណាជាស្ថាន សម្រាលដល់ការផ្តន្ទាទោសបាន"។[132] ការលើកឡើងរបស់ជនជាប់ចោទ ពាក់ព័ន្ធនឹងការបង្ខិតបង្ខំនេះគឺតុលាការ

[131] សាលក្រម ០០១ ឧប, E188, កថាខណ្ឌទី ៥២៦ និង ៥៣៧។

[132] ប្រភពដូចខាងលើ, កថាខណ្ឌទី ៥៥៤។

មានឆន្ទានុសិទ្ធិក្នុងការពិចារណាទៅលើស្ថានសម្រាលទោស ឬ មិនផ្តល់ឱ្យដោយថ្លឹងថ្លែងរវាងអំពើល្មើស និង បរិយាកាសនៃស្ថានភាពនយោបាយនាសម័យកម្ពុជាប្រជាធិបតេយ្យ។

### ៣.១.៤ ជោគវាសនារបស់ កាំង ហ្កេចអ៊ាវ

#### ៣.១.៤.១ ការសម្រេចអំពីទណ្ឌកម្មក្នុងដំណាក់កាលអង្គជំនុំជម្រះសាលាដំបូង

អង្គជំនុំជម្រះសាលាដំបូង (អ.ជ.ស.ដ) បានតម្រូវឱ្យ កាំង ហ្កេចអ៊ាវ ទទួលខុសត្រូវចំពោះបទល្មើស ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ផ្សេងទៀត ដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដោយស្រូបបញ្ចូលទៅក្នុងបទធ្វើទុក្ខបុកម្នេញនយោបាយដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្រោយពីបានពិចារណាទៅលើយុត្តិសាស្ត្រក្នុងការអនុវត្តវិធាននៃបទល្មើសត្រួតគ្នា។[133] បន្ថែមពីនេះ គឺជនជាប់ចោទត្រូវទទួលខុសត្រូវចំពោះអំពើរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩ លើបទល្មើស ការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម និងការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬ ឱ្យមានការឈឺចាប់ដល់រូបរាងកាយ ឬ សុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬ ជនស៊ីវិលនូវសិទ្ធិទទួលបានការទោសដោយយុត្តិធម៌ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

ជាចុងក្រោយ អ.ជ.ស.ដ បានសម្រេចប្រកាសទោសពន្ធនាគារលើ កាំង ហ្កេចអ៊ាវ កំណត់រយៈពេល ៣៥ ឆ្នាំ ដោយបានពិចារណាផ្តល់នូវស្ថានសម្រាលឱ្យជនជាប់ចោទផ្អែកទៅតាមកិច្ចសហប្រតិបត្តិការជាមួយអង្គជំនុំជម្រះ ការទទួលស្គាល់នូវកំហុស ការសម្តែងវិប្បដិសារី រួមជាមួយនឹងបរិយាកាសនយោបាយនាសម័យកម្ពុជាប្រជាធិបតេយ្យ និងសក្តានុពលដែលអាចស្តារនីតិសម្បទា។

#### ៣.១.៤.២ ការសម្រេចចុងក្រោយអំពីទណ្ឌកម្មដោយអង្គជំនុំជម្រះតុលាការកំពូល

បណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី និងសហព្រះរាជអាជ្ញា ដោយបានលើកឡើងអំពីកំហុសចំនួន ០៣ ធំៗ ពាក់ព័ន្ធនឹងអង្គច្បាប់ដែល អ.ជ.ស.ដ បានវិនិច្ឆ័យ។ មេធាវីការពារក្តីឱ្យជនជាប់ចោទបានរៀបរាប់អំពីកំហុសពាក់ព័ន្ធនឹងយុត្តាធិការលើរូបបុគ្គល ដែលចុងក្រោយអង្គជំនុំជម្រះតុលាការកំពូល (អ.ជ.ត.ក) សម្រេចបដិសេធលើករណីនេះទាំងស្រុង។[134] ចំណែកឯ សហព្រះរាជអាជ្ញា បានលើកឡើងអំពីការវិនិច្ឆ័យផ្នែកច្បាប់ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិរបស់ អ.ជ.ស.ដ ប៉ុន្តែកត្តាសំខាន់ដែលជិះឥទ្ធិពលធ្វើឱ្យប្រែប្រួលការសម្រេចអំពីទោសចំពោះជនជាប់ចោទនោះ គឺការវិនិច្ឆ័យអំពីធាតុផ្សំនៃអំពើធ្វើទុក្ខបុកម្នេញដែលនាំឱ្យប៉ះពាល់ដល់ការសម្រេចអំពីការស្រូបទោសបញ្ចូលគ្នា។ មានន័យថា អ.ជ.ស.ដ មានកំហុសក្នុងការស្រូបបទល្មើស

---

[133] សាលក្រម ០០១ ឧច, E188, កថាខណ្ឌទី៥៥៩ ដល់ ៥៦៨។

[134] សាលដីកា ឧច ០០១, កថាខណ្ឌទី ២១ ដល់ ៨១។

ទាំងឡាយដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទៅក្នុងបទល្មើសការធ្វើទុក្ខបុកម្នេញនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

ក្រោយពី អ.ជ.ត.ក បានពិចារណាឡើងវិញអំពីការប្រើប្រាស់យុត្តិសាស្ត្ររបស់ អ.ជ.ស.ដ ក្នុងការស្រូបទោសរួចរាល់ហើយ អ.ជ.ត.ក បានសម្រេចមិនស្រូបបញ្ចូលបទល្មើសដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សទៅក្នុងបទធ្វើទុក្ខបុកម្នេញនោះទេ លើកលែងតែអំពើមនុស្សឃាតដោយចេតនា ដែលអាចស្រូបបញ្ចូលជាមួយនឹងបទសម្លាប់រង្គាល។ មានន័យថា ជនជាប់ចោទត្រូវទទួលការអនុវត្តទោសត្រួតគ្នាចំពោះបទល្មើស ការសម្លាប់រង្គាល (ស្រូបបញ្ចូលជាមួយនឹងអំពើមនុស្សឃាត) បទធ្វើជាទាសករ បទដាក់ក្នុងមន្ទីរឃុំឃាំង បទធ្វើទារុណកម្ម (ការរំលោភផ្លូវភេទមួយករណី) បទធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ផ្សេងៗ ក៏ព្រោះតែធាតុផ្សំសត្យានុម័តនៃបទល្មើសមានលក្ខណៈដាច់ដោយឡែកពីគ្នា។

ជាចុងក្រោយ អ.ជ.ត.ក បានសម្រេចកែប្រែរយៈពេលដាក់ពន្ធនាគារចំពោះ កាំង ហ្គេចអ៊ាវ ពី៣៥ឆ្នាំ មកជាដាក់ពន្ធនាគារអស់មួយជីវិត ក៏ព្រោះតែឧក្រិដ្ឋកម្មដែលជនជាប់ចោទបានប្រព្រឹត្ត គឺជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតចំពោះមនុស្សជាតិ។[135] និយាយម្យ៉ាងទៀតថា ព្យសនកម្មនៃអំពើល្មើសមានភាពធ្ងន់ធ្ងរខ្លាំងពេក ដែលនាំឱ្យស្ថានភាពនៃការឃុំខ្លួនខុសនីតិវិធីរបស់តុលាការយោធា និងស្ថានសម្រាល ពុំអាចយកមកពិចារណាបានទេ ដែលនេះគឺជាមូលហេតុដែលនាំឱ្យ អ.ជ.ត.ក សម្រេចកែប្រែរយៈពេលនៃការផ្តន្ទាទោសចំពោះ កាំង ហ្គេចអ៊ាវ។

## ៣.២.សំណុំរឿង ០០២/០១

យុត្តាធិការពេលវេលានៃសំណុំរឿង ០០២ ត្រូវបានកំណត់ចាប់ពី ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រហូតដល់ ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩។ នៅក្នុងរយៈពេលនេះ មានឧក្រិដ្ឋកម្មជាច្រើនត្រូវបានប្រព្រឹត្តិឡើងចេញគោលនយោបាយរួមរបស់បក្សកុម្មុយនីស្តកម្ពុជា។ ក្នុងនោះ ថ្នាក់ដឹកនាំរបស់បក្សកុម្មុយនីស្តកម្ពុជា ព្យាយាមសម្រេចលើគោលនយោបាយរួមមួយដើម្បីរំដោះប្រទេសកម្ពុជា និងបង្កើតរដ្ឋសង្គមនិយមក្នុង៤ ដំណាក់កាល[136]៖

- ដំណាក់កាលទី១ គឺការកសាងបក្សកុម្មុយនីស្តកម្ពុជា ចាប់ពីខែកញ្ញា ឆ្នាំ១៩៦០ ដល់ ខែមករា ឆ្នាំ ១៩៦៨។
- ដំណាក់កាលទី២ គឺការផ្តួចផ្តើមបដិវត្តន៍ប្រដាប់អាវុធ ចាប់ពីខែមីនា ឆ្នាំ១៩៦៨ ដល់ ខែមីនា ឆ្នាំ ១៩៧០។

135 សាលដីកា ០០១ ឌុច, F28, ផ្នែកសម្រេចសេចក្តី។

136 សាលក្រមសំណុំរឿង ០០២/០១ នួន ជា និង ខៀវ សំផន,E313 , កថាខណ្ឌទី៧៧៧។

- ដំណាក់កាលទី៣ គឺការធ្វើបដិវត្តន៍ប្រជាធិបតេយ្យ ចាប់ពីខែមីនា ឆ្នាំ១៩៧០ ដល់ ខែមេសា ឆ្នាំ ១៩៧៥។
- ដំណាក់កាលទី៤ គឺការធ្វើបដិវត្តន៍សង្គមនិយម ចាប់ពីខែមេសា ឆ្នាំ១៩៧៥ ដល់ ខែមករា ឆ្នាំ ១៩៧៩។

ទាក់ទងនឹងគោលនយោបាយរួមរបស់បក្សនៃការធ្វើបដិវត្តន៍សង្គមនិយមនៅដំណាក់កាលទី៤ បក្សកុម្មុយនីស្តកម្ពុជា បានអនុម័តជាសាធារណៈលើគោលនយោបាយថ្មីមួយទៀតលើមាគ៌ាបក្សដើម្បីការពារ និងការកសាងប្រទេសឱ្យបានលឿនតាមរយៈបដិវត្តន៍សង្គមនិយមឆាប់រហ័ស តាមសន្ទុះមហាលោតផ្លោះដើម្បីការពារសត្រូវផ្ទៃក្នុង ក៏ដូចជាសត្រូវខាងក្រៅ[137] តាមរយៈ៖

- ការកាន់កាប់ និងគ្រប់គ្រងអំណាចជាបណ្តោះអាសន្នរបស់បក្សកុម្មុយនីស្តកម្ពុជាក្រោយពេលរំដោះ។ បក្សកុម្មុយនីស្តកម្ពុជា បានបង្កើតឱ្យមានគោលនយោបាយ និងដាក់ចេញនូវការផ្សព្វផ្សាយទាក់ទងនឹងការជម្លៀសប្រជាជន ការពិភាក្សាអំពីគោលនយោបាយផែនការកសាង និងការពារសង្គមនិយម ខ្លួនទីពឹងខ្លួនឱ្យបានឆាប់រហ័ស ការរៀបចំបង្កើតសហករណ៍ លុបបំបាត់ទ្រព្យឯកជន លុបបំបាត់រូបិយប័ណ្ណ និងទីផ្សារ ការកសាងទំនប់ទឹក និងប្រឡាយទឹកជាអាទិ៍ រួមទាំងការកសាងប្រទេសដោយពឹងផ្អែកលើវិស័យកសិកម្មបែបទំនើបក្នុងរយៈពេល ១០ ទៅ១៥ឆ្នាំ។[138]
- ការចងបង្កើតមាគ៌ាបក្ស ផ្តើមចេញពីការបង្កើតរដ្ឋធម្មនុញ្ញថ្មីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ក្នុងនោះក៏មានការធានាឱ្យមានសង្គមមួយគ្មានវណ្ណៈ ហើយជាសង្គមដែលប្រជាជនខិតខំបង្កបង្កើនផលិតផលកសិកម្ម ឧស្សាហកម្មដើម្បីកសាង និងការពារប្រទេស។ នៅក្នុងមហាសន្និបាតរបស់បក្សលើកទី៤ បក្សកម្មុយនីស្តកម្ពុជាកំណត់លក្ខខណ្ឌមួយថា ខ្លួនគឺជាតុលាការកំពូលនៅកម្ពុជា ដែលបញ្ជាលើគ្រប់ការងារទាំងអស់នៅក្នុងការធ្វើបដិវត្តន៍សង្គមនិយម នៅក្នុងករណីដែលមានថ្នាក់បក្សណាមួយ ឬ បេក្ខជនណាមួយប្រឆាំងនិងគោលជំហររបស់បក្ស និងត្រូវបណ្តេញចេញពីតួនាទី និងចេញពីបក្ស។[139]
- ការរំលាយរាជរដ្ឋាភិបាលរួបរួមជាតិ ដោយការស្នើសុំរំលាយរដ្ឋាភិបាលរួបរួមជាតិរបស់ ប៉ែន នុត និងការចូលនិវត្តរបស់សម្តេច នរោត្តម សីហនុ។ គោលនយោបាយមួយរបស់បក្សកុម្មុយនីស្ត គឺការប្រែ

[137] សាលក្រមសំណុំរឿង ០០២/០១ នួន ជា និង ខៀវ សំផន, E313, កថាខណ្ឌទី៧៣៧ ដល់ ៧៣៨។

[138] ប្រភពដូចខាងលើ, កថាខណ្ឌទី៧៣៩ និង ៧៤០។

[139] ប្រភពដូចខាងលើ, កថាខណ្ឌទី៧៥៤ និង ៧៥៥។

ក្លាយខ្លួនឱ្យទៅជារដ្ឋាភិបាលស្របច្បាប់ដែលមានការទទួលស្គាល់ពីអន្តរជាតិ តាមការចូលរួមរបស់បុគ្គលទាំងពីរនៅតាមទីជនបទ គឺជាល្បិចកលរបស់ពួកខ្មែរក្រហមក្នុងគោលបំណងជំរុញលើកទឹកចិត្តប្រជាជនជាសាធារណៈយល់ថានេះជាការគាំទ្ររបស់ពួកគាត់ចំពោះខ្មែរក្រហម។[140]

- កម្ពុជាប្រជាធិបតេយ្យ ត្រូវកំណត់គោលដៅជារួមក្នុងការគ្រប់គ្រងបក្សដោយគណៈកម្មាធិការមជ្ឈិម។ គណៈកម្មាធិការនេះ បង្កើតការគាំទ្រឱ្យមានការបោះឆ្នោតសភាតំណាងប្រជាជន កំណត់ថារដ្ឋាភិបាលជាអង្គការដែលស្ថិតនៅក្រោមបក្ស និងកំណត់ស្ថាប័នភូមិភាគ និងមជ្ឈិមផ្សេងទៀតដែលមានសិទ្ធិ កម្ទេចទាំងក្នុងនិងក្រៅបក្ស រួមទាំងកំណត់គោលដៅបដិវត្តដែលផ្តល់អំណាចទៅដល់កសិករ។[141]

នៅក្នុងដំណាក់កាលទី៤នៃគោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា បទល្មើសដែលបានប្រព្រឹត្តិកើតចេញពីគោលនយោបាយរួមរបស់បក្សមានទំហំច្រើន។ អង្គជំនុំជម្រះយល់ឃើញថា វិសាលភាពនៃសំណុំរឿងមានភាពស្មុគស្មាញក្នុងការកំណត់បទចោទទៅលើជនល្មើស ជាហេតុធ្វើឱ្យអង្គជំនុំជម្រះសម្រេចចេញដីកាបំបែកសំណុំរឿង ០០២ ជាពីរ គឺ ០០២/០១ និង ០០២/០២។ មួយវិញទៀត ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ មានចំនួន ៤រូប គឺ អៀង សារី អៀង ធីរិទ្ធ នួន ជា និងខៀវ សំផន។ ដោយហេតុថា ជនជាប់ចោទ អៀង សារី បានទទួលមរណៈភាពជាហេតុធ្វើឱ្យបណ្តឹងអាជ្ញាត្រូវបានរលត់ ហើយជនជាប់ចោទ អៀង ធីរិទ្ធ មិនមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមនៅក្នុងអង្គជំនុំជម្រះបានដោយសារតែជំងឺវង្វេងស្មារតី ទើបធ្វើជនជាប់ចោទទាំងពីរត្រូវបានដកចេញពីសំណុំរឿង០០២។[142]

នៅក្នុងសំណុំរឿង ០០២ អង្គជំនុំជម្រះសាលាដំបូងមានយុត្តាធិការពេលវេលាត្រឹមការធ្វើបដិវត្តន៍សង្គមនិយមចាប់ពីពេលដែលខ្មែរក្រហមបានបញ្ចប់នូវជម្លោះប្រដាប់អាវុធជាមួយរបបសាធារណរដ្ឋខ្មែរនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ដែលស្របនឹងយុត្តាធិការរបស់អង្គជំនុំជម្រះ។ ផ្ទុយទៅវិញ តាមរយៈដីការបំបែកសំណុំរឿង បានកម្រិតយុត្តាធិការពេលវេលានៅក្នុងសំណុំរឿង ០០២/០១ គិតចាប់ពីថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ខែធ្នូ ឆ្នាំ ១៩៧៧។[143] បន្ថែមពីនេះទៅទៀត ជនជាប់ចោទនៅក្នុងសំណុំរឿង ០០២/០១ គឺមានតែ នួន ជា និង ខៀវ សំផន ប៉ុណ្ណោះ។

---

[140] សាលក្រមសំណុំរឿង ០០២/០១ នួន ជា និង ខៀវ សំផន, E313 , កថាខណ្ឌទី ៧៦១ និង ៧៦២។

[141] ប្រភពដូចខាងលើ, កថាខណ្ឌទី ៧៦៣ និង ៧៦៤។

[142] *សំណុំរឿង ០០២*, អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, https://www.eccc.gov.kh/km/case/topic/119, (ទស្សនាចុងក្រោយ ០៨/០៨/២០២៣)។

[143] ប្រភពដូចខាងលើ, កថាខណ្ឌទី ៧២៥។

### ៣.២.១ ពិរុទ្ធភាពរបស់ជនជាប់ចោទទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

អង្គជំនុំជម្រះ បានរកឃើញពិរុទ្ធភាពលើជនជាប់ចោទ នួន ជា និង ខៀវ សំផន ទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលបានប្រព្រឹត្តនៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជានៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥ រហូតដល់ឆ្នាំ ១៩៧៧។ បទមនុស្សឃាត ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បានកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ប្តូរទីលំនៅប្រជាជនក្នុងដំណាក់កាលទី ១ ដំណាក់កាលទី២ និងនៅទួលពោធិ៍ជ្រៃ។

#### ៣.២.១.១ អំពើមនុស្សឃាត

អំពើមនុស្សឃាត កើតមានឡើងនៅក្រោយពេលដែលខ្មែរក្រហមទទួលបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរ។ ផ្តើមចេញពីការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញភ្លាមៗ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នាយទាហាន និងមន្ត្រីរដ្ឋការស៊ីវិលជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ ត្រូវបានខ្មែរក្រហមកំណត់គោលដៅរួចជាស្រេចសម្រាប់ការប្រហារជីវិត។ ក្នុងអំឡុងពេលជម្លៀសប្រជាជននៅក្នុងដំណាក់កាលទី១នេះ គឺធ្វើឡើងដោយគ្មានការជូនដំណឹងជាមុន និងបញ្ឆោតថានឹងវិលមកវិញនៅក្នុងរយៈពេល ៣ ថ្ងៃខាងមុខ។ មិនតែប៉ុណ្ណោះ ខ្មែរក្រហមនឹងបាញ់សម្លាប់ចោលភ្លាមៗ ចំពោះប្រជាជនណាដែលមិនព្រមចាកចេញពីផ្ទះ ឬ រឹងទទឹងមិនធ្វើតាមការណែនាំ។ រីឯអ្នកដែលត្រូវបានជម្លៀស មិនទទួលបានជំនួយណាមួយនៅក្នុងអំឡុងពេលធ្វើដំណើរ ពោលគឺមិនមានការផ្តល់ថ្នាំ ឬ ចំណីអាហារដល់ប្រជាជន ជាពិសេស កុមារ ជនចាស់ជរា ស្ត្រីមានជំងឺ និងអ្នកជំងឺផ្សេងទៀតនោះទេ។[144] អ.ជ.ស.ដ យល់ឃើញថា "ចេតនារបស់ចារី គឺអាចប្រមើលមើលដឹងអំពីលទ្ធភាពនៃអំពើរបស់ខ្លួនដែលអាចបណ្តាលឱ្យមានមនុស្សស្លាប់ ប៉ុន្តែចារីបានបន្តអនុវត្តសកម្មភាពរបស់ខ្លួនដោយចេតនាមិនចំពោះ"[145]។ ដោយហេតុថា ខ្មែរក្រហមធ្លាប់មានបទពិសោធន៍ជម្លៀសប្រជាជនពីតំបន់ដែលខ្មែរក្រហមបានកាន់កាប់ទៅកាន់តំបន់រំដោះមុនខែមេសា ឆ្នាំ១៩៧៥ រួមផ្សំនឹងភស្តុតាងផ្សេងទៀតទាក់ទងនឹងការអះអាងរបស់ជនជាប់ចោទ នួន ជា ដោយទទួលស្គាល់ថា "ថ្នាក់ដឹកនាំមិនមានពេលវេលាក្នុងការកំណត់អំពីផលប៉ះពាល់ដោយសារតែការជម្លៀសនោះទេ"[146]។ អ.ជ.ស.ដ យល់ឃើញថា យ៉ាងហោចណាស់ខ្មែរក្រហមបានដឹងពីការជម្លៀសប្រជាជនជាពិសេសជនងាយរងគ្រោះ ស្ថិតនៅក្នុងលក្ខខណ្ឌលំបាកខ្លាំងដែលអាចបណ្តាលឱ្យមានមនុស្សស្លាប់។[147] ហេតុ

[144] សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី ៥៥៣ ដល់ ៥៥៥។
[145] ប្រភពដូចខាងលើ, កថាខណ្ឌទី ៥៥៦។
[146] ប្រភពដូចខាងលើ, កថាខណ្ឌទី ៥៥៧។
[147] ប្រភពដូចខាងលើ, កថាខណ្ឌទី ៥៥៨។

នេះ ការស្លាប់របស់ជនរងគ្រោះដែលបានបាញ់សម្លាប់ នៅក្នុងអំឡុងពេលជម្លៀសចេញពីទីក្រុងភ្នំពេញ និងប្រជាជនដែលត្រូវស្លាប់ដោយសារតែការខ្វះជំនួយ គឺជាការធ្វើមនុស្សឃាត។[148]

បន្ថែមពីនេះ អតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ មានដូចជា ទាហាន និងជនដែលសុំចុះចាញ់ ត្រូវបានខ្មែរក្រហមដឹកជញ្ជូនយកទៅសម្លាប់ចោលនៅទីតាំងមួយកន្លែងដែលគេស្គាល់ថា ទួលពោធិ៍ជ្រៃ[149]។ សកម្មភាពដែលប្រព្រឹត្តិឡើងដោយខ្មែរក្រហមទៅលើអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ តាមរយៈការធ្វើឱ្យស្លាប់ដោយចេតនា គឺបានបំពេញគ្រប់ធាតុផ្សំនៃបទការធ្វើមនុស្សឃាត។[150]

### ៣.២.១.២ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

នៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជននៅក្នុងដំណាក់កាលទី១ ប្រជាជនត្រូវបានកំណត់ចេញជា ០៣ក្រុម ដែលខ្មែរក្រហមចាត់ទុកថាជាសត្រូវបដិវត្តន៍សង្គមនិយម ឬ ប្រឆាំងនឹងគោលនយោបាយរបស់ខ្លួន។ បុគ្គលទាំងនោះរួមមាន ១) នាយទាហាន និងមន្ត្រីរដ្ឋការស៊ីវិលជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ ២) អ្នកមានតួនាទីនៅក្នុងអតីតរបបសាធារណរដ្ឋខ្មែរទាំងទាហាន និងអ្នករដ្ឋការស៊ីវិល ៣) ប្រជាជនដែលរស់នៅក្នុងទីក្រុងភ្នំពេញដែលហៅថាប្រជាជន ១៧ មេសា ឬ ប្រជាជនថ្មី។[151] កងទ័ពខ្មែរក្រហម បានកំណត់អត្តសញ្ញាណប្រជាជនទាំង ៣ក្រុមជារួមថាជា "ប្រជាជនថ្មី" ដោយរួមបញ្ចូលអ្នកដែលជាសត្រូវ និងអ្នកដែលប្រឆាំងនឹងមនោគមន៍របស់បក្សកុម្មុយនីស្តកម្ពុជាជាកម្មវត្ថុនៃការរើសអើង។ តាមរយៈការផ្លាស់ទីលំនៅដោយបង្ខំ ដោយការគម្រាមកំហែង និងការគាបសង្កត់ផ្លូវចិត្ត បានរំលោភលើសិទ្ធិសេរីភាពជាសារវ័ន្តនៃការផ្លាស់ទីលំនៅរបស់ប្រជាជនដោយការប្រព្រឹត្តិរបស់កងទ័ព និងកម្មាភិបាលខ្មែរក្រហម ត្រូវបានកំណត់ថាជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។[152]

### ៣.២.១.៣ អំពើអមនុស្សធម៌ដទៃទៀត

អំពើអមនុស្សធម៌ដទៃទៀត ត្រូវបានរកឃើញតាមរយៈអង្គហេតុនៃការផ្លាស់ទីប្រជាជនដោយបង្ខំនៅក្នុងដំណាក់កាលទី១ និងទី២ ដែលធ្វើឡើងដោយគ្មានការជូនដំណឹង និងស្ថិតនៅក្រោមស្ថានភាពភ័យខ្លាចនិងមានលក្ខណៈជាហិង្សា។ ជាក់ស្តែង ការជម្លៀសប្រជាជននៅក្នុងដំណាក់កាលទី១ គឺជាគោលនយោបាយនៃការជម្លៀសប្រជាជនដែលរស់នៅក្នុងទីក្រុងទៅកាន់ទីជនបទ។ នេះ គឺជាលក្ខខណ្ឌធ្ងន់ធ្ងរនៃការជម្លៀសប្រជាជន

---

[148] សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី ៥៥៩។

[149] ប្រភពដូចខាងលើ, កថាខណ្ឌទី ៦៥៩។ "ទីតាំងនេះស្ថិតនៅក្នុងស្រុកកណ្តៀងតំបន់៧ នៃភូមិភាគពាយ័ព្យ និង មានបឹងមួយដែលគេបោះសាកសពចូល"។

[150] ប្រភពដូចខាងលើ, កថាខណ្ឌទី ៦៨៣។

[151] ប្រភពដូចខាងលើ, កថាខណ្ឌទី ៥៦៩។

[152] ប្រភពដូចខាងលើ, កថាខណ្ឌទី ៦៥៦ និង៦៥៧។

ដោយមិនគិតគូរអំពីសុខុមាលភាពប្រជាជន ដែលបណ្តាលឱ្យប្រជាជនរស់នៅទីក្រុង ជាពិសេសជនងាយរងគ្រោះត្រូវបាត់បង់ជីវិតក្នុងអំឡុងពេលធ្វើដំណើរ។ មានការអះអាងមួយពីចារីដែលថា ការផ្លាស់ទីលំនៅធ្វើឡើងដោយត្រឹមត្រូវ និងស្របច្បាប់ ដើម្បីចៀសវាងពីការទម្លាក់គ្រាប់បែកដែលនឹងអាចកើតមានឡើង។ ផ្ទុយទៅវិញហេតុការណ៍នៃការទម្លាប់គ្រាប់បែកត្រូវបានបញ្ចប់តាំងពីខែសីហា ឆ្នាំ១៩៧៣ ហើយផ្អែកតាមភស្តុតាងនៅក្នុងឆ្នាំ១៩៧៧[153] អាចសន្និដ្ឋានបានថា គោលបំណងនៃការជម្លៀស គឺធ្វើឡើងដើម្បីឱ្យថ្នាក់ដឹកនាំអាចគ្រប់គ្រងប្រជាជនបានល្អ និងការពារកុំឱ្យខ្មាំងបង្កអស្ថិរភាពដល់កងទ័ពបក្សកុម្មុយនីស្តកម្ពុជា ពោលគឺមិនមែនដើម្បីការពារប្រជាជនពីការទម្លាក់គ្រាប់បែកនោះទេ។

រីឯការជម្លៀសប្រជាជននៅក្នុងដំណាក់កាលទី២វិញ ប្រជាជនដ៏ច្រើនលើសលុបដែលខ្មែរក្រហមធ្លាប់បានផ្លាស់ទីលំនៅម្តងរួចមកហើយនៅមុខ ខែកញ្ញា ឆ្នាំ១៩៧៥ ត្រូវបានស្លាប់ដោយសារតែលក្ខខណ្ឌនៃគោលនយោបាយផ្លាស់ទីលំនៅរបស់បក្សកុម្មុយនីស្តកម្ពុជា ពីតំបន់មួយទៅតំបន់មួយទៀត។ នៅក្នុងកាលទេសៈនេះខ្មែរក្រហមមិនបានអើពើនឹងសុខទុក្ខរបស់ប្រជាជន ដោយពុំបានផ្តល់ស្បៀង ឬ ជំនួយវេជ្ជសាស្ត្រ និងសម្ភារៈអនាម័យគ្រប់គ្រាប់ មិនខុសពីស្ថានភាពនៃការជម្លៀសកាលពីដំណាក់កាលទី ១ នោះទេ។ បន្ថែមពីនេះ អំពើអមនុស្សធម៌ត្រូវបានរកឃើញ តាមរយៈការបំបែកក្រុមគ្រួសារឱ្យចេញពីគ្នា ការបាញ់សម្លាប់ ភាពអត់ឃ្លាន និងកើតជំងឺអំឡុងពេលធ្វើដំណើរ។ ហេតុនេះ វាហួសពីវិមតិសង្ស័យដែលថា ការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី២ បានបង្កឱ្យមាននូវអំពើអមនុស្សធម៌ផ្សេងទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។[154]

### ៣.២.២ ការទទួលខុសត្រូវព្រហ្មទណ្ឌជាឯកត្តបុគ្គល

ជនជាប់ចោទ នួន ជា និងខៀវ សំផន មានពិរុទ្ធភាពលើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិចំពោះការរៀបចំផែនការ ការញុះញង់ ការជួយនិងជំរុញ។ បន្ថែមពីនេះ ជនជាប់ចោទ នួន ជា មានជាប់ទាក់ទងនឹងការបញ្ជានៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មនេះ ដោយផ្អែកលើមូលដ្ឋាននៃការទទួលខុសត្រូវរបស់ថ្នាក់លើ និងក្នុងនាមជាអ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមនៃទម្រង់១។ ទម្រង់នេះត្រូវបានកំណត់តាមរយៈ អ្នកចូលរួមទាំងអស់ប្រព្រឹត្តដោយចេតនាទៅតាមគោលបំណងរួម និងមានចេតនាឧក្រិដ្ឋដូចគ្នា។[155] ប្រសិនបើត្រូវបានរកឃើញថា ចារីម្នាក់ក្នុងចំណោមសហចារីទាំងអស់ដែលមានគោលបំណងរួម បានប្រព្រឹត្តបទល្មើស នោះសហចារីផ្សេងទៀតដែលប្រើចារីឱ្យសម្រេចនូវគោលបំណងរួមដោយផ្ទាល់នោះ ក៏ត្រូវទទួលខុសត្រូវក្នុងនាមជាសហចារីផងដែរ។

[153] សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី ៨៥៣ និង៨៥៤។

[154] អ.វ.ត.ក, សហព្រះរាជអាជ្ញា និង ជនជាប់ចោទ នួន ជា និង ខៀវ សំផន,សាលដីកា, ០០២/១៩ កញ្ញា ២០០៧/អវតក/អជតក, F36, កថាខណ្ឌទី ៦៥៨ ដល់ ៦៦០។ "ចាប់ពីនេះតទៅសូមហៅកាត់ថា សាលដីកា ០០២/០១ នួនជា និង ខៀវសំផន, F36"

[155] សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី ៦៩៤។

គប្បីបញ្ជាក់ថា គោលបំណងរួម គឺជាការបង្កើតបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាមរយៈសន្ទុះមហាលោតផ្លោះដើម្បីការពារបក្សប្រឆាំងនឹងសត្រូវផ្ទៃក្នុង និងសត្រូវខាងក្រៅ។ មានភស្តុតាងជាច្រើនបានបង្ហាញថា ថ្នាក់ដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមជាច្រើននាក់ គាំទ្រនឹងគោលនយោបាយបក្ស និងបានចូលរួមផ្សព្វផ្សាយនូវគោលនយោបាយទាំងនោះដែលធ្វើឱ្យមានការកាប់សម្លាប់ប្រជាជន និងរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរនៅអំឡុងពេលជម្លៀសក្នុងដំណាក់កាលទី១ ទី២ និងនៅទួលពោធិ៍ជ្រៃដោយកងទ័ពខ្មែរក្រហម។ ឧក្រិដ្ឋកម្មទាំងនោះជាប់ពាក់ព័ន្ធនឹងការសម្រេចនូវគោលបំណងរួម ឬ គោលបំណងរបស់បក្ស។ ហេតុដូច្នេះ ការទទួលខុសត្រូវជាឯកត្តបុគ្គលក្នុងការចូលរួមចំណែកនៅក្នុងគោលបំណងរួមរបស់ជនជាប់ចោទ គឺទាក់ទងនឹងតួនាទីចេតនាប្រព្រឹត្ត និងការយល់ដឹងរបស់ជនជាប់ចោទទៅនឹងឧក្រិដ្ឋកម្មដែលកើតចេញពីគោលបំណងរួម។

**៣.២.២.១ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា**

ផ្អែកតាមដីកាដំណោះស្រាយ នួន ជា បានចូលរួមដោយចេតនា ឬ បានរួមចំណែកក្នុងការរៀបចំ និងអនុវត្តគោលបំណងរួម ដែលបណ្តាលឱ្យមានឧក្រិដ្ឋកម្ម និង/ឬ ជាប់ពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្មទាំងមុន និងក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ។ ការរួមចំណែករបស់ នួន ជា គឺទាក់ទងនឹងតួនាទីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងការរៀបចំគោលបំណងរួមនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។

នៅក្នុងតួនាទីជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា សមាជិកគណៈកម្មាធិការយោធា សមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ នួន ជា បានចូលរួមក្នុងកិច្ចប្រជុំនានា ដែលទាក់ទងនឹងការបង្កើតគោលនយោបាយរបស់បក្សតាមរយៈការឃោសនា និងវគ្គសិក្សានយោបាយ រួមទាំងមានសិទ្ធិទទួលបាននូវការជូនដំណឹងដែលទាក់ទងនឹងបទល្មើសដែលបានកើតឡើង ភាពកង្វះស្បៀងអាហាររបស់ប្រជាជន ការស្នាក់នៅ និងការកើតជំងឺជាដើម។ លើសពីនេះ នួន ជា ក៏ជាអ្នកបណ្តុះបណ្តាលដល់ថ្នាក់ក្រោមឱ្យមានការប្រុងប្រយ័ត្នចំពោះខ្មាំងសត្រូវខាងក្រៅ និងខាងក្នុង ជាពិសេសប្រជាជនថ្មី និងអតីតរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ។ គោលបំណងនៃការបណ្តុះបណ្តាល គឺមានចេតនាបញ្ជ្រាបមនោគមន៍វិជ្ជាដែលប្រគល់អំណាចដល់វណ្ណៈអធនគ្រប់គ្រងប្រទេស ដោយដឹងយ៉ាងច្បាស់ថា វណ្ណៈថ្មីនេះទទួលបាននូវការអប់រំតិចតួចបំផុត និងមិនអាចវិនិច្ឆ័យសេចក្តីបានត្រឹមត្រូវនោះឡើយ។ គោលការណ៍ដែលពឹងផ្អែកលើកសិករថ្នាក់ទាបបំផុត ឱ្យគ្រប់គ្រងប្រទេសអាចបង្កើតឱ្យមាននូវហិង្សា និងការកាប់សម្លាប់លើប្រជាជន បើទោះបីជាមានភស្តុតាងមួយចំនួនលើកឡើងថា ការអប់រំវណ្ណៈទាំងនោះធ្វើឡើងដោយតឹងរ៉ឹងក៏ដោយក្តី។

នួន ជា បានដឹងគ្រប់វិធីសាស្ត្រនៃការអនុវត្តផែនការ និងគោលនយោបាយជម្លៀសប្រជាជនចេញពីតំបន់ប្រជុំជន និងការកំណត់គោលដៅលើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរដែលបង្កើតឱ្យមានការប្រព្រឹត្តិ

ឧក្រិដ្ឋកម្មនៅក្នុងអំឡុងពេលនៃការជម្លៀសប្រជាជននៅក្នុងដំណាក់កាលទី១ ទី២ និងនៅទួលពោធិ៍ជ្រៃ។[156] ដោយហេតុថា នៅក្នុងនាមជាអនុលេខាបក្ស នួន ជា មានអំណាចក្នុងការសម្រេចសេចក្ដីចុងក្រោយជាមួយនឹង ប៉ុល ពត ទាំងការបង្កើតផែនការនយោបាយ រៀបចំគោលនយោបាយដំបូង និងការអនុវត្តគោលនយោបាយ យ៉ាងសកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ ទាំងតាក់តែងគោលជំហរបក្សស្ដីពីហិង្សាបដិវត្តន៍ និងការប្រើប្រាស់ការ តស៊ូប្រដាប់អាវុធដើម្បីសម្រេចគោលបំណងបក្ស។ នួន ជា ក៏បានទទួលស្គាល់ថាខ្លួនបានចូលរួមនៅក្នុងការ សម្រេចជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ។ បើទោះបីជាគាត់មិនបានប្រព្រឹត្តបទឧក្រិដ្ឋនោះដោយផ្ទាល់ប៉ុន្តែ ចេតនាប្រយោលរបស់គាត់តាមរយៈគោលនយោបាយរបស់បក្ស បានបង្កនូវព្យសនកម្មធ្ងន់ធ្ងរ។ ហេតុនេះ ធាតុ ផ្សំនៃការទទួលខុសត្រូវក្នុងនាមជាសហឧក្រិដ្ឋកម្មរួមត្រូវបានបំពេញ។

**៣.២.២.២ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ ខៀវ សំផន**

ផ្អែកតាមដីកាដំណោះស្រាយ ខៀវ សំផន បានចូលរួមដោយចេតនា ឬ បានរួមចំណែកក្នុងការរៀបចំ ផែនការ និងការអនុវត្តគោលបំណងរួមដែលធ្វើឱ្យមានការប្រព្រឹត្តិឧក្រិដ្ឋកម្មជាច្រើនទាំងមុនពេល និងនៅក្នុង អំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ។

ផ្ដើមចេញពីតួនាទីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានចូលរួមកិច្ចប្រជុំរបស់គណៈ អចិន្ត្រៃយ៍ ឬ កិច្ចប្រជុំគោលនយោបាយ[157] កិច្ចប្រជុំណែនាំ[158] កិច្ចការសេដ្ឋកិច្ចវិទូ[159] សេចក្ដីថ្លែងការជាសាធារ ណៈ[160] និងកម្មាភិបាលតំណាងទូត[161] ក្នុងគោលបំណងផ្សព្វផ្សាយគោលនយោបាយខ្មែរក្រហមដល់កម្មាភិ បាលថ្នាក់ក្រោម ផ្ដល់ការគាំទ្រ និងមានការឯកភាពគ្នាទាក់ទងនឹងគោលបំណងរួមនៃគោលនយោបាយរបស់ ខ្មែរក្រហម។ គួរបញ្ជាក់ផងដែរថាគោលបំណងរួម "មានគោលដៅបង្កើតរដ្ឋមួយដោយខ្លួនទីពឹងខ្លួន រដ្ឋមួយពឹង ផ្អែកលើកសិកម្មសម័យទំនើបក្នុងរយៈពេល ១០ទៅ១៥ឆ្នាំ និងបន្ទាប់មក ជារដ្ឋមួយដែលពឹងផ្អែកលើសេដ្ឋកិច្ច ឧស្សាហកម្ម"[162]។ រីឯ ផែនការនៃការជម្លៀសប្រជាជនចេញពីទីក្រុងក៏ជាផ្នែកមួយនៃគោលបំណងរួម ដោយ កំណត់គោលដៅលើប្រជាជនថ្មីបង្កបង្កើនផលលើដីប្រជាជនចាស់ដើម្បីជំរុញគោលនយោបាយសេដ្ឋកិច្ច។

---

[156] សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី ៨៤៦ និង៨៤៩ (ទាក់ទងនឹងអង្គហេតុដែលជានជាប់ចោទបាន សារភាព) ដល់ ៨៥៤។

[157] ប្រភពដូចខាងលើ, កថាខណ្ឌទី ៩៦៤ ដល់ ៩៧២។

[158] ប្រភពដូចខាងលើ, កថាខណ្ឌទី ៩៧២ ដល់ ៩៧៦។

[159] ប្រភពដូចខាងលើ, កថាខណ្ឌទី ៩៧៧ ដល់ ៩៧៩។

[160] ប្រភពដូចខាងលើ, កថាខណ្ឌទី ៩៨០ ដល់ ៩៨៧។

[161] ប្រភពដូចខាងលើ, កថាខណ្ឌទី ៩៨៨ ដល់ ៩៩២។

[162] ប្រភពដូចខាងលើ, កថាខណ្ឌទី ៩៧៩។

ចេតនារបស់ ខៀវ សំផន ស្តែងឡើងតាមការចូលរួមក្នុងការកំណត់អត្តសញ្ញាណពួកនាយទុន និងពួកមូលធននិយមថាជាខ្មាំង និងកំណត់ជាទូទៅចំពោះប្រជាជនថ្មីទាំងអស់ គឺត្រូវតែធ្វើការលត់ដំ។[163] នេះបង្ហាញឱ្យឃើញពីចេតនាចូលរួមចំណែករបស់ ខៀវ សំផន នៅក្នុងការបន្តការអនុវត្តគោលនយោបាយរួម បើទោះបីជាដឹងថាឧក្រិដ្ឋកម្មនានាកំពុងត្រូវបានប្រព្រឹត្តឡើងក៏ដោយ។ ហេតុនេះ ខៀវ សំផន បានដឹងអំពីគោលនយោបាយ និងឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តដោយពួកខ្មែរក្រហម ថែមទាំងដឹងថាអំពើហិង្សាមានលក្ខណៈជាឧក្រិដ្ឋកម្មដែលធ្វើឡើងដើម្បីប្រឆាំងនឹងជនស៊ីវិលក្នុងការអនុវត្តគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា។

### ៣.២.៣ ការបដិសេធការទទួលខុសត្រូវព្រហ្មទណ្ឌរបស់សហជនជាប់ចោទ

មួយក្នុងចំណោមបណ្តឹងសាទុក្ខដទៃទៀត ដែលសហជនជាប់ចោទប្តឹងមក អ.ជ.ត.ក គឺទាក់ទងនឹងបទដ្ឋានគតិយុត្តនៃការចូលរួមចំណែកនៅក្នុងគោលបំណងរួម។ នួន ជា បានលើកឡើងថា ការចូលរួមចំណែករបស់គាត់ គឺបានរួមចំណែកយ៉ាងសំខាន់ដល់បដិវត្តន៍សង្គមនិយមមួយ មិនមែនមានន័យថា នួន ជា បានចូលរួមចំណែកក្នុងការប្រព្រឹត្តិបទល្មើសនោះទេ។ រីឯ ខៀវ សំផន បានលើកឡើងអំពីវត្តមាននៃការចូលរួមនៅក្នុងកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល ការថ្លែងសុន្ទរកថា តួនាទីជាការទូត និងការរួមចំណែកនៅក្នុងអំឡុងពេលនៃព្រឹត្តិការណ៍ដែលកើតឡើងនៅក្នុងសម័យនោះ ឬ ក្រោយពេលការជម្លៀសប្រជាជន មិនអាចចាត់ទុកជាមូលដ្ឋាននៃលក្ខខណ្ឌចូលរួមរបស់គាត់ ទៅក្នុងសហឧក្រិដ្ឋកម្មរួមនោះទេ។[164] ហេតុនេះ ការចូលរួមចំណែករបស់ នួន ជា និង ខៀវ សំផន គឺជាការចូលរួមចំណែកនៅក្នុងការកសាងបដិវត្តន៍សង្គមនិយម ដែលពុំមែនជាបទឧក្រិដ្ឋជាក់លាក់សម្រាប់ធ្វើជាមូលដ្ឋាននៃការរួមចំណែកយ៉ាងសំខាន់នៅក្នុងឧក្រិដ្ឋកម្មរួមនោះទេ។

ផ្អែកតាមយុត្តិសាស្ត្រ ICTY និងការបកស្រាយរបស់ អ.ជ.ស.ដ បានលើកឡើងថា៖

> ការចូលរួមនៅក្នុងគោលបំណងរួមអាចតាមរយៈអំពើសកម្ម ឬ អំពើអកម្ម។ ភាពសំខាន់នៃការចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មត្រូវកំណត់ទៅតាមករណីនីមួយៗ ដោយពិចារណាលើកត្តាជាច្រើន រួមទាំងតួនាទីរបស់ជនជាប់ចោទ កម្រិត និងប្រសិទ្ធភាពនៃការចូលរួម និងកិច្ចខិតខំប្រឹងប្រែងទប់ស្កាត់បទឧក្រិដ្ឋ។ ការចូលរួមរបស់ជនជាប់ចោទ មិនតម្រូវទាល់តែមានការចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ឬ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នោះទេ ព្រោះវាអាចកើតចេញពីការជួយជ្រំជ្រែង និងការអនុវត្តគោលបំណងរួម។ អ្នកចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួម អាចតម្រូវឱ្យមានការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយចារី...ប្រសិនបើត្រូវបានរកឃើញថា ឧក្រិដ្ឋកម្មទាំងនោះអាចត្រូវបានដាក់ឱ្យទទួលខុសត្រូវ យ៉ាង

[163] សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី ៩៤៥។

[164] សាលដីកា ០០២/០១ នួនជា និង ខៀវសំផន, F36, កថាខណ្ឌទី ៩៧៧។

ហោចណាស់ទៅលើអ្នកចូលរួមណាម្នាក់នៃសហឧក្រិដ្ឋកម្មរួម ហើយអ្នកចូលរួមនេះបានប្រើប្រាស់ចារីដើម្បីសម្រេចគោលបំណងរួមនោះ។[165]

យោងតាមខ្លឹមសារខាងលើនេះ ការរួមចំណែករបស់សហជនជាប់ចោទក្នុងការកសាងបដិវត្តន៍សង្គមនិយម គឺជាការជំរុញដល់ការអនុវត្តគោលនយោបាយបក្ស ឬ គោលបំណងរួម។ ដោយហេតុថា តាមរយៈតួនាទីនិងមុខងាររបស់សហជនជាប់ចោទក្នុងជួររដ្ឋាភិបាលនៃរបបខ្មែរក្រហម ការកសាងបដិវត្តន៍សង្គមនិយម គឺផ្តើមចេញពីការជម្លៀសប្រជាជន។ ការជម្លៀសនេះ ស្របតាមគោលនយោបាយនៃការផ្លាស់ទីលំនៅប្រជាជនដើម្បីសម្រេចគោលបំណងរួមដែលវាជាប់ពាក់ព័ន្ធយ៉ាងជិតស្និទ្ធទៅនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម។ បន្ថែមពីនេះទៅទៀត សហជនជាប់ចោទជាអ្នកដាក់ចេញ និងបានផ្សព្វផ្សាយគោលនយោបាយរួមដើម្បីឱ្យថ្នាក់ក្រោមយកទៅអនុវត្ត។ ហេតុនេះ នួន ជា និង ខៀវ សំផន មិនអាចរួចផុតពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។

### ៣.២.៤ ទោសទណ្ឌរបស់សហជនជាប់ចោទ

#### ៣.២.៤.១ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

សេចក្តីសម្រេចរបស់ អ.ជ.ស.ដ ក្នុងសំណុំរឿង ០០២/០១ ចែកចេញពីរ ផ្នែកគឺការផ្តន្ទាទោស និងការទទួលខុសត្រូវ។ ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី១ អង្គជំនុំជម្រះយល់ឃើញថា ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលផ្អែកលើការសម្លាប់តែមួយ ហើយការសម្លាប់នៅទួលពោធិ៍ជ្រៃ ក៏ផ្អែកទៅលើការសម្លាប់តែមួយដូចគ្នា។ បើទោះបីជាអំពើមនុស្សឃាតទាមទារឱ្យមានមនុស្សស្លាប់ រីឯការសម្លាប់រង្គាលត្រូវមានការសម្លាប់នៅក្នុងទ្រង់ទ្រាយធំ ក៏ការសម្លាប់រង្គាលដែលជាបទល្មើសជាក់លាក់ស្រូបបញ្ចូលការធ្វើមនុស្សឃាត។ បន្ថែមពីនេះ បទល្មើសផ្សេងទៀតមានធាតុផ្សំដោយឡែកពីគ្នាជាសត្យានុម័តដែលមិនមានចែងត្រួតគ្នានៅក្នុងបទល្មើសណាមួយផ្សេងទៀត។ ហេតុនេះ អង្គជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទចំពោះ បទល្មើសការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ផ្សេងទៀត (រួមមាន ការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស)។[166] ចំពោះការទទួលខុសត្រូវ គឺផ្អែកលើឋានៈ តួនាទី និងចំណេះដឹងខ្ពង់ខ្ពស់របស់ជនជាប់ចោទ។ ជនជាប់ចោទ អាចយល់ដឹងអំពីបច្ច័យទាំងឡាយដែលកើតចេញពីសកម្មភាពដែលបានប្រព្រឹត្ត។ ទោះជាយ៉ាងណាក្តី ស្តានសម្រាល ធ្វើឡើងដោយផ្អែកតាមការបង្ហាញពីវិប្បដិសារី ត្រូវតែមានលក្ខណៈស្មោះត្រង់ និងពិតប្រាកដ។ ជនជាប់ចោទ នួន ជា បង្ហាញពីវិប្បដិសារី ចំពោះអំពើរបស់ជនក្បត់ (មិនត្រូវបានកំណត់អត្តសញ្ញាណ) ហើយ

[165] សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី ៦៩៣។

[166] ប្រភពដូចខាងលើ, កថាខណ្ឌទី ១០៦០។

កំណត់ការទទួលខុសត្រូវរបស់ខ្លួនត្រឹមតែការខកខានមិនបានគ្រប់គ្រងដិតដល់ ដែលវាមិនអាចក្លាយជាតម្លៃនៃការពិចារណាលើស្ថានសម្រាលនោះទេ។[167]

អ.ជ.ស.ដ ពិចារណាឃើញថា បើទោះបីជាស្ថានទម្ងន់នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា ធ្ងន់ធ្ងរជាង ខៀវ សំផន ក្តី ក៏ការសម្រេចផ្តន្ទាទោសឱ្យជនជាប់ចោទទាំងពីរ ជាប់ពន្ធនាគារមួយជីវិតគឺជាការសមស្របបំផុត។[168] ចុងក្រោយ អ.ជ.ស.ដ សម្រេចផ្តន្ទាទោសជាប់ពន្ធនាគារមួយជីវិតចំពោះ[169]ជនជាប់ចោទ នួន ជា និង ខៀវ សំផន មានពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជា ក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៩។ បទល្មើសរួមមាន ការសម្លាប់រង្គាល (រួមបញ្ចូលទាំងការធ្វើមនុស្សឃាត) ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងៗទៀត (រួមមានការផ្លាស់ទីលំនៅដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ និងការប៉ះពាល់ដល់សេក្តីថ្លៃថ្នូររបស់មនុស្ស។

### ៣.២.៤.២ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល

អ.ជ.ត.ក រកឃើញថា អ.ជ.ស.ដ មានកំហុសអង្គច្បាប់ទាក់ទងនឹងការប្រកាសទោស ក្រោយពីទទួលបណ្តឹងសាទុក្ខរបស់សហជនជាប់ចោទ និងសហព្រះរាជអាជ្ញា។ ការផ្តន្ទាទោសលើសហជនជាប់ចោទនៅដំណាក់កាល អ.ជ.ស.ដ ពីបទសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ និងទី២ បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ និងបទសម្លាប់រង្គាល និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយប្រព្រឹត្តិឡើងនៅទួលពោធិ៍ជ្រៃ ធ្វើឡើងដោយពុំត្រឹមត្រូវនោះទេ។[170] ផ្ទុយទៅវិញ អ.ជ.ត.ក បានដាក់ពិរុទ្ធលើជនជាប់ចោទ នួន ជា និងខៀវ សំផន ទៅលើព្រឹត្តិការណ៍ដែលកើតឡើងនៅដំណាក់កាលទី១ និងទី២ ហើយបដិសេធការដាក់ពិរុទ្ធភាពលើសហជនជាប់ចោទលើអង្គហេតុដែលកើតឡើងនៅទួលពោធិ៍ជ្រៃ។

ទាក់ទងនឹងអង្គហេតុដែលកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ អ.ជ.ត.ក រកឃើញថា អ.ជ.ស.ដ មានកំហុសក្នុងការយល់ឃើញថាបទសម្លាប់រង្គាលត្រូវបានរកឃើញនៅក្នុងដំណាក់កាលទី១។ ផ្ទុយទៅវិញ ការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើឱ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្សមិនមែនជាបទឧក្រិដ្ឋដោយឡែក ព្រោះវាស្ថិតនៅក្រោមអំពើអមនុស្សធម៌ដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំង

---

[167] សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី ១០៩៣។

[168] ប្រភពដូចខាងលើ, កថាខណ្ឌទី ១១០៥។

[169] ប្រភពដូចខាងលើ, ផ្នែកសេចក្តីសម្រេច។

[170] សាលដីកា ០០២/០១ នួនជា និង ខៀវសំផន, F36, កថាខណ្ឌទី ១១០៤។

មនុស្សជាតិ ដែលកើតចេញពីគោលបំណងរួម។[171] រីឯ អំពើមនុស្សឃាតនៅក្នុងដំណាក់កាលទី ១នេះ គឺរាប់បញ្ចូលទាំងការស្លាប់ដែលបណ្តាលមកពីលក្ខខណ្ឌជម្លៀស ការសម្លាប់ជនស៊ីវិល រួមទាំងការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ក៏រួមបញ្ចូលនៅក្នុងគោលបំណងរួមផងដែរ។ បន្ថែមពីនេះទៅទៀត អំពើមនុស្សឃាតលើទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បានបង្ហាញដោយប្រយោលថាជាផ្នែកមួយនៃគោលបំណងរួម។[172] ដោយហេតុថា បើទោះបីជាគ្មានបទបញ្ជាឱ្យសម្លាប់ ក៏ជនទាំងនោះត្រូវបានសម្លាប់ក្រោមហេតុផលជាជនស៊ីវិលដែលបដិសេធមិនព្រមចាកចេញពីតំបន់ដែលកំពុងរស់នៅដែរ។

ចំពោះអង្គហេតុដែលកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជននៅក្នុងដំណាក់កាលទី ២ អ.ជ.ត.ក ពិចារណាឃើញថាវាមានការបង្ហាញហួសពីវិមតិសង្ស័យ។ ដោយហេតុថា គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងកាលៈទេសៈនោះ គឺជាចំណុចស្នូលដែលធ្វើឱ្យប្រជាជនមួយចំនួនធំ រងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរតាមរយៈការជម្លៀស និងស្លាប់ដោយសារលក្ខខណ្ឌនៃការផ្លាស់ទីលំនៅដែលស្តែងឡើងតាមរយៈអំពើអនុស្សធម៌ដទៃទៀតដូចជា ការបំបែកចេញពីគ្រួសារ ការបាញ់សម្លាប់ ភាពអត់ឃ្លាន និងកើតជំងឺជាដើម។[173] មួយវិញទៀត ហេតុការណ៍នៃការធ្វើមនុស្សឃាតនៅក្នុងដំណាក់កាលទី ២នេះ ពុំមែនជាអំពើសម្លាប់រង្គាលនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឡើយ។ ដោយហេតុថា ប្រជាជនត្រូវបានសម្លាប់ដោយលក្ខខណ្ឌនៃការជម្លៀស និងការសម្លាប់ដោយកងទ័ពដែលមានភារកិច្ចជម្លៀស បានរួមបញ្ចូលទៅក្នុងគោលបំណងរួម។ ដូចនេះ គោលនយោបាយផ្លាស់ទីលំនៅប្រជាជន បានរួមបញ្ចូលដោយប្រយោលនូវបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។[174]

ផ្ទុយទៅវិញ អង្គហេតុដែលកើតឡើងនៅទួលពោធិ៍ជ្រៃ អ.ជ.ត.ក យល់ឃើញថា អត្ថិភាពនៃគោលនយោបាយកំណត់គោលដៅពុំត្រូវបង្ហាញដោយសមហេតុផលឡើយ។ ដោយសារតែ ការបំបែកកិច្ចដំណើរការនៃសំណុំរឿង០០២ ទើបធ្វើឱ្យសំណុំរឿង០០២/០១ បានកម្រិតព្រឹត្តិការណ៍ដែលកើតឡើងនៅទួលពោធិ៍ជ្រៃត្រឹមចុងខែមេសា ឆ្នាំ១៩៧៥ និងធ្វើឱ្យភស្តុតាងពេលវេលានៃអត្ថិភាពគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាអនុម័តនៅឆ្នាំ១៩៧៦ មិនជាប់ពាក់ព័ន្ធនឹងគោលបំណងរួមនៃការសម្លាប់នៅទួលពោធិ៍ជ្រៃ។ ហេតុនេះ គោល

[171] សាលដីកា ០០២/០១ នួនជា និង ខៀវសំផន, F36, កថាខណ្ឌទី ៨៤៥ និង៨៥០។

[172] ប្រភពដូចខាងលើ, កថាខណ្ឌទី ៨៦០។

[173] ប្រភពដូចខាងលើ, កថាខណ្ឌទី ៨៦៥ ដល់ ៨៦៧។

[174] ប្រភពដូចខាងលើ, កថាខណ្ឌទី ៨៦៨។

បំណងរួមនៃការប្រព្រឹត្តិបទល្មើសទាក់ទងនឹងព្រឹត្តិការណ៍នៅទួលពោធិ៍ជ្រៃមិនត្រូវបានបង្ហាញ ជាហេតុធ្វើឱ្យជនជាប់ចោទពុំត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដោយផ្អែកលើសហឧក្រិដ្ឋកម្មរួមនេះឡើយ។[175]

ជាចុងក្រោយ អ.ជ.ត.ក សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារមួយជីវិតលើ នួន ជា និង ខៀវ សំផន៖[176]

- ទាក់ទងនឹងអង្គហេតុដែលកើតឡើងនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជន ដំណាក់កាលទី១៖ ពីបទមនុស្សឃាត បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និង
- ទាក់ទងនឹងអង្គហេតុដែលបានកើតឡើង នៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២៖ បទអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងកែប្រែប្រភេទនៃគតិយុត្តនៃបទល្មើសដោយសម្រេចដាក់ពិរុទ្ធភាពលើសហជនជាប់ចោទពីបទមនុស្សឃាតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិវិញ។
- លើកលែងការចោទប្រកាន់ការដាក់ពិរុទ្ធភាពលើសហជនជាប់ចោទ ទាក់ទងនឹងអង្គហេតុដែលបានកើតឡើងនៅទួលពោធិ៍ជ្រៃ៖ ពីបទសម្លាប់រង្គាល បទមនុស្សឃាត និងបទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។

## ៣.៣ សំណុំរឿង ០០២/០២

នៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងមានយុត្តាធិការពេលវេលា ចាប់ពី ទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩។ ក្នុងនោះផងដែរ ជនជាប់ចោទ នៅក្នុងដំណាក់កាលអង្គជំនុំជម្រះសាលាដំបូង មាន នួន ជា និង ខៀវ សំផន។ ផ្ទុយទៅវិញ នៅដំណាក់កាលនៃបណ្តឹងសាទុក្ខទៅតុលាការកំពូល នួន ជា ទទួលមរណៈភាពដោយសារជំងឺជាហេតុធ្វើឱ្យបណ្តឹងសាទុក្ខរបស់ នួន ជា ត្រូវរលត់ដោយសារតែមរណៈភាពរបស់ជនជាប់ចោទ។ ហេតុនេះ សាលដីកានៃសំណុំរឿង០០២/០២ គឺមានតែ ខៀវ សំផន តែម្នាក់ប៉ុណ្ណោះ។

### ៣.៣.១ ពិរុទ្ធភាពរបស់ជនជាប់ចោទទាក់ទងនឹងឧក្រិដ្ឋកម្ម

#### ៣.៣.១.១ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

##### ក. សហករណ៍ត្រាំកក់

សកម្មភាពដែលត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្ម ត្រូវបានកើតឡើងនៅក្នុងស្រុកត្រាំកក់ នៃខេត្តតាកែវដែលបង្កឡើងដោយខ្មែរក្រហមមកលើសហករណ៍ត្រាំកក់។ ប្រជាជននៅទីនោះ បានបាត់បង់ជីវិតដោយសារ

[175] សាលដីកា ០០២/០១ នួនជា និង ខៀវសំផន, F36, កថាខណ្ឌទី ៩៧២។

[176] ប្រភពដូចខាងលើ, ផ្នែកសម្រេចសេចក្តី។

ការមិនអើពើអំពីកង្វះខាតស្បៀងអាហារ លក្ខខណ្ឌការងារហួសកម្លាំងកាយ និងកង្វះខាតការព្យាបាលផ្នែកវេជ្ជសាស្ត្រ ដែលត្រូវបានចាត់ទុកជាអំពើមនុស្សឃាត ដោយសារតែចារីមានចេតនាឱ្យកើតមាននូវលទ្ធផលបែបនេះមកលើប្រជាជន។[177]

ការប្រើប្រាស់នូវអំណាចយ៉ាងតឹងរឹងដោយកម្មាភិបាលខ្មែរក្រហមនៃតំបន់នោះ ទៅលើប្រជាជនដោយការបង្ខំឱ្យធ្វើការដែលផ្ទុយពីឆន្ទៈ ការបង្អត់អាហារដែលជាទណ្ឌកម្មចំពោះការមិនស្តាប់បង្គាប់ ឬ មិនសម្រេចបាននូវលទ្ធផលការងារដែលបានផ្តល់ឱ្យ គឺបង្កើតបានជាអំពើទាសភាព។ ការប្រតិបត្តិផ្នែកសាសនា និងប្រពៃណីទំនៀមទម្លាប់ត្រូវបានលុបបំបាត់ ដោយការចាប់បង្ខំឱ្យព្រះសង្ឃជាច្រើនអង្គផ្សឹក ការបំផ្លាញនិមិត្តរូបតំណាងព្រះពុទ្ធសាសនា ដែលជាទម្រង់នៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ពោលគឺខ្មែរក្រហមបានរំលោភបំពានសិទ្ធិជាមូលដ្ឋានក្នុងការគោរព ឬ ជំនឿទៅលើសាសនា។ មិនតែប៉ុណ្ណោះ ប្រជាជនថ្មីក្រោយថ្ងៃរំដោះ និងអតីតមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ បានទទួលរងនូវលក្ខខណ្ឌការងារ និងរបបហូបចុក ខុសប្លែកពីប្រជាជនចាស់ដែលភាគច្រើនជាកសិករក្រីក្រ និងថ្នាក់ក្រោម ពោលគឺពួកគេស្ថិតក្នុងស្ថានភាពមួយដែលងាយរងគ្រោះជាងប្រជាជនទូទៅដោយការចាប់ខ្លួន និងសម្លាប់ចោល ហើយដែលទង្វើនេះគឺជាការធ្វើទុក្ខបុកម្នេញនយោបាយ។ ការបង្គាប់ឱ្យធ្វើការជាទម្ងន់ កង្វះខាតនូវចំណីអាហារ ទីជម្រកមិនសមរម្យ និងខ្វះខាតផ្នែកវេជ្ជសាស្ត្រ ដែលសហករណ៍ត្រាំកក់បានជួបប្រទះ គឺជាធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ ជានិច្ចកាល មានការដកហូតសិទ្ធិសេរីភាពរបស់បុគ្គលតាមរយៈការចាប់ខ្លួនដោយគ្មានមូលហេតុ ឬ ការបាត់ខ្លួនជាបន្តបន្ទាប់ ដែលទិដ្ឋភាពនេះបានប៉ះពាល់ដល់សិទ្ធិជនរងគ្រោះក៏ដូចជាបង្កឱ្យមានភាពភ័យខ្លាចដល់ប្រជាជនដទៃទៀត ដែលត្រូវបានចាត់ទុកជាអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ។

ក្រៅពីប្រជាជនខ្មែរដែលរស់នៅស្រុកត្រាំកក់នេះ ក៏មានវត្តមានប្រជាជនវៀតណាម ដែលត្រូវបានបង្ខំឱ្យចាកចេញពីស្រុកត្រាំកក់ ទៅកាន់ប្រទេសវៀតណាមវិញនៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ ១៩៧៦ ដែលជាទម្រង់នៃការរើសអើងពូជសាសន៍ ក៏ព្រោះតែជនជាតិនេះត្រូវបានខ្មែរក្រហមកំណត់គោលដៅថា ជាពូជសាសន៍ផ្សេង ហើយក៏បានបញ្ជាឱ្យបញ្ជូនទៅកាន់ប្រទេសរបស់ពួកគេវិញ។[178] ដូច្នេះ ការបង្ខំឱ្យចាកចេញពីទឹកដីកម្ពុជាដោយមូលហេតុពូជសាសន៍ គឺជាបទល្មើសនិរទេស និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍។

**ខ- ការដ្ឋានការងារ (ទំនប់ត្រពាំងថ្ម ទំនប់១ មករា ព្រលានយន្តហោះយោធាកំពង់ឆ្នាំង)**

[177] សាលដីកា ០០២/០២ នួន ជា និង ខៀវ សំផន, E465, កថាខណ្ឌទី ១១៨៥។

[178] ប្រភពដូចខាងលើ, កថាខណ្ឌទី ១១៥៦ ដល់ ១១៥៩។

ការដ្ឋានការងារចំនួន ០៣ រួមមានទំនប់ត្រពាំងថ្ម ទំនប់១ មករា និងព្រលានយន្តហោះយោធាកំពង់ឆ្នាំង ត្រូវបានរកឃើញថាជាទីតាំងដែលបង្កឱ្យកើតមាននូវសោកនាដកម្មចំពោះកម្មករដែលធ្វើការនៅទីនោះ។ បទល្មើសដែលកើតឡើងនៅតាមការដ្ឋាននីមួយៗ សឹងតែដូចគ្នាទាំងស្រុង គ្រាន់តែកម្មករដែលធ្វើការនៅព្រលានយន្តហោះយោធាកំពង់ឆ្នាំងគឺមានតួនាទីជាយោធាខ្មែរក្រហម។

កម្មករនៃការដ្ឋានចំនួន ០៣កន្លែងនេះ ត្រូវបានស្លាប់ជាច្រើននាក់ ដែលបណ្តាលមកពីការធ្វើការហួសពីកម្លាំង កត្តាអាកាសធាតុ ស្ថានភាពសុខភាព ការហូបចុកមិនគ្រប់គ្រាន់ កង្វះអនាម័យ និងខ្វះខាតផ្នែកវេជ្ជសាស្ត្រនៅពេលមានជំងឺដង្កាត់ជាដើម។ បើទោះបីជាគណៈគ្រប់គ្រងនៅតាមការដ្ឋាននីមួយៗបានជ្រាបអំពីបញ្ហានេះ ប៉ុន្តែពួកគេមិនអើពើឡើយ ដែលជាហេតុបណ្តាលឱ្យមានការបាត់បង់អាយុជីវិតរបស់កម្មករជាបន្តបន្ទាប់ មានន័យថាថ្នាក់លើមានចេតនាក្នុងការទទួលយកលទ្ធផលដែលកើតចេញពីបញ្ហាទាំងនេះ ដែលជាទម្រង់មួយនៃការធ្វើមនុស្សឃាត។ បន្ថែមពីនេះ គណៈគ្រប់គ្រងនៃការដ្ឋានបានអនុវត្តនូវវិន័យយ៉ាងតឹងរឹងដើម្បីគ្រប់គ្រងទៅលើកម្មករ ពោលគឺកម្មករស្ថិតក្រោមទិដ្ឋភាពជាកម្មសិទ្ធិរបស់ថ្នាក់លើ ដោយមិនមានសិទ្ធិតវ៉ាចំពោះការងារដែលបានដាក់ជូន ត្រូវប្រតិបត្តិឱ្យបានខ្ជាប់ខ្ជួននូវវិន័យ និងមានការដាក់ទណ្ឌកម្មដូចជាការបង្អត់អាហារចំពោះជនដែលមិនសម្រេចកិច្ចការតាមបំណង ដែលទង្វើនេះគឺជាអំពើនៃការធ្វើឱ្យទៅជាទាសករ។

បន្ថែមពីនេះ អតីតរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ប្រជាជនថ្មី ប្រជាជនដែលវិលត្រឡប់មកពីបរទេស និងកម្មាភិបាលដែលចាប់ខ្លួនដោយការបោសសម្អាតផ្ទៃក្នុងបក្ស ត្រូវបានចាត់ទុកថាជាខ្មាំង។ បុគ្គលប្រភេទនេះត្រូវបានទទួលនូវការរើសអើង ដែលស្តែងតាមរយៈលក្ខខណ្ឌការងារ របបហូបចុក និងការដាក់ទណ្ឌកម្ម ពោលគឺការរស់នៅរបស់ពួកគេមានលក្ខណៈពិបាកជាងប្រជាជនមូលដ្ឋាន ដែលខ្មែរក្រហមចាត់ទុកជាប្រជាជនចាស់ អំពើនេះគឺជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ មិនខុសពីប្រជាជននៅស្រុកត្រាំកក់នោះទេ កម្មករដែលធ្វើការនៅការដ្ឋាន ក៏ជួបនឹងបញ្ហាការទទួលទានមិនគ្រប់គ្រាន់ ពលកម្មហួសកម្លាំង កង្វះខាតផ្នែកវេជ្ជសាស្ត្រ និងលក្ខខណ្ឌរស់នៅមិនសមរម្យដទៃទៀត ដែលបង្កឱ្យឈឺចាប់ដល់រូបរាងកាយ និងផ្លូវចិត្ត ដែលច្បាប់ត្រូវបានចាត់ទុកជាអំពើអមនុស្សធម៌ផ្សេងទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ ការចាប់ខ្លួនកម្មករ ដោយទាហាន ឬ កងឈ្លប និងការបាត់ខ្លួនកម្មករជាបន្តបន្ទាប់ ដោយមិនផ្តល់មូលហេតុអំពីការចាប់ខ្លួន ឬ ព័ត៌មានអំពីជោគវាសនារបស់កម្មករដែលត្រូវបានចាប់ខ្លួន ដែលជាហេតុបង្កឱ្យមានផលប៉ះពាល់ផ្នែកផ្លូវចិត្តទៅលើជនរងគ្រោះ និងកម្មករដទៃទៀត ពោលគឺខ្មែរក្រហមបានបង្កឱ្យមាននូវបរិយាកាសនៃភាពភ័យខ្លាច ដែលត្រូវបានកំណត់ថាជាអំពើអមនុស្សធម៌ផ្សេងទៀតក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការបាត់ខ្លួនដោយបង្ខំ។

លើសពីនេះ ចំពោះការដ្ឋានទំនប់ ១មករា មានការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាទៅលើជនជាតិចាម ដោយខ្មែរក្រហមបានហាមឃាត់ និងរឹតត្បិតមិនឱ្យមានបដិបត្តិសាសនា ក៏ដូចជាប្រើប្រាស់នូវភាសាដើមរបស់ពួកគេឡើយ ដែលអំពើនេះជាការរំលោភបំពានសិទ្ធិទាក់ទងនឹងសាសនា។

**គ- ទីកន្លែងឃុំឃាំងមនុស្ស (មន្ទីរសន្តិសុខស២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង មន្ទីរសន្តិសុខភ្នំក្រោល)**

មន្ទីរឃុំឃាំងមនុស្សចំនួន ០៤ កន្លែងដែលមាន មន្ទីរស២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រោល បានបង្កឱ្យកើតមាននូវឧក្រិដ្ឋកម្មយ៉ាងព្រៃផ្សៃដល់អ្នកជាប់ឃុំឃាំងដែលប្រព្រឹត្តឡើងដោយបុគ្គលិកនៃមន្ទីរនីមួយៗ។

អ្នកជាប់ឃុំឃាំងក្នុងមន្ទីរត្រូវបានស្លាប់ដោយអំពើសកម្មរបស់ចារី ហើយខ្លះទៀតត្រូវបាត់បង់ជីវិតដោយសារតែលក្ខខណ្ឌនៃការឃុំខ្លួន មានជាអាទិ៍ការបង្អត់អាហារ កង្វះអនាម័យ ការមិនអើពើចំពោះការផ្តល់ជំនួយផ្នែកវេជ្ជសាស្ត្រ ដែលត្រូវបានចាត់ទុកជាការធ្វើមនុស្សឃាតទៅលើអ្នកជាប់ឃុំ។ បន្ថែមពីនេះ មន្ទីរស២១ មន្ទីរក្រាំងតាចាន់ និងមន្ទីរអូរកន្សែង ត្រូវបានស្វែងរកឃើញអំពីការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ និងមានលក្ខណៈរួម ដែលឈានដល់ការកំណត់ថាមន្ទីរចំនួន ០៣ នេះ បានបង្កឱ្យមាននូវបទសម្លាប់រង្គាល ដោយមន្ទីរស២១ មានការសម្លាប់ប្រមាណជាង ១ម៉ឺននាក់[179] មន្ទីរក្រាំងតាចាន់យ៉ាងតិច ១០០០នាក់[180] និងមន្ទីរអូរកន្សែងយ៉ាងហោចណាស់ ១១១នាក់[181]។ ខ្មែរក្រហមតម្រូវឱ្យអ្នកជាប់ឃុំធ្វើការជាទម្ងន់ ដោយគ្មានសិទ្ធិក្នុងការតវ៉ានោះទេ ពោលគឺពួកគេប្រៀបបានដូចជាកម្មសិទ្ធិរបស់អង្គការបក្ស ដែលទង្វើនេះគឺជាការធ្វើឱ្យទៅជាទាសករ។ ការចាប់ខ្លួនបុគ្គលទាំងឡាយមកឃុំខ្លួនគឺធ្វើឡើងដោយទំនើងចិត្ត និងគ្មានស្ថាប័នណាមួយក្នុងការវិនិច្ឆ័យអំពីកំហុស ឬ ប្រាប់អំពីមូលហេតុ នៃការចាប់ខ្លួននោះទេ។ ការរើសអើងចំពោះជនដែលត្រូវបានសន្មតថាជាខ្មាំងដែលសង្ស័យថាមានទំនាក់ទំនង ជាមួយនឹងបរទេស ឬ មានបំណងប្រឆាំងនឹងអង្គការ ត្រូវទទួលរងនូវផលវិបាកខ្លាំងជាអ្នកជាប់ឃុំដទៃទៀត ដែលជាអំពើនៃការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ។ លើសពីនេះ មន្ទីរស២១ និងមន្ទីរក្រាំងតាចាន់ ត្រូវបានរកឃើញថាមានការធ្វើទារុណកម្មទៅលើអ្នកជាប់ឃុំ ដោយការប្រើប្រាស់នូវហិង្សា ឬ ឧបករណ៍ផ្សេងៗ ដែលបណ្តាលឱ្យមានការឈឺចាប់ដល់ផ្លូវកាយ និងផ្លូវចិត្ត។ ជាពិសេសមន្ទីរស២១ ដែលជាទីកន្លែងធ្វើទារុណកម្មយ៉ាងព្រៃផ្សៃមួយទៅលើអ្នកជាប់ឃុំ ដើម្បីទទួលបាននូវចម្លើយសារភាព។

---

[179] សាលក្រម ០០២/០២ នួន ជា និង ខៀវ សំផន, E465, កថាខណ្ឌទី ២៥៧០។

[180] ប្រភពដូចខាងលើ, កថាខណ្ឌទី ២៨១៩។

[181] ប្រភពដូចខាងលើ, កថាខណ្ឌទី ២៩៦៨។

អ្នកជាប់ឃុំនៃមន្ទីរនីមួយៗ ជួបប្រទះនូវការផ្តល់អាហារមិនគ្រប់គ្រាន់ កង្វះអនាម័យ លក្ខខណ្ឌនៃការឃុំឃាំង លក្ខខណ្ឌការងារ កង្វះខាតការព្យាបាល ការធ្វើបាបផ្លូវកាយ និងផ្លូវចិត្ត ដែលទិដ្ឋភាពទាំងនេះជាអំពើអមនុស្សធម៌ផ្សេងទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។ ក្រៅពីនេះ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិសាសន៍ ក៏កើតមានលើជនជាតិវៀតណាមដែលជាប់ឃុំនៅមន្ទីរស២១ និងមន្ទីរអូរកន្សែង តាមរយៈការចាប់ខ្លួន ឃុំខ្លួន ការធ្វើទារុណកម្ម និងសម្លាប់ចោល ក៏ព្រោះតែខ្មែរក្រហមបានចាត់ទុកពួកគេថាជាពូជសាសន៍ផ្សេង។ ការនាំខ្លួនអ្នកជាប់ឃុំចាកចេញ ដោយមិនមានមូលហេតុ ឬ ផ្តល់ដំណឹងអំពីជោគវាសនារបស់ពួកគេ បានបង្កឱ្យមានកើតមាននូវបរិយាកាសភ័យខ្លាច និងប៉ះពាល់ដល់ផ្លូវចិត្តដល់អ្នកជាប់ឃុំដទៃទៀត ត្រូវបានកំណត់ថាជាអំពើអមនុស្សធម៌ផ្សេងទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ដែលប្រព្រឹត្តនៅក្នុងមន្ទីរក្រាំងតាចាន់ និងមន្ទីរភ្នំក្រោល។

**ឃ- សកម្មភាពប្រឆាំងនឹងជនជាតិចាម**

ខ្មែរក្រហមបានធ្វើសកម្មភាពរំលោភបំពានទៅលើជនជាតិចាមដែលរស់នៅលើដែនដីកម្ពុជា ជាពិសេសនៅភូមិភាគកណ្តាល និងស្រុកក្រូចឆ្មារ។ ជនជាតិចាម ត្រូវស្លាប់ដោយសារលក្ខខណ្ឌនៃការឃុំខ្លួន ក៏ដូចជាមានការសម្លាប់ក្នុងទ្រង់ទ្រាយធំក្រោយពីបានចាប់ខ្លួន និងយកទៅឃុំនៅមន្ទីរសន្តិសុខ អូរត្រកួន និងមន្ទីរសន្តិសុខភូមិទ្រា ដែលជាបទការធ្វើមនុស្សឃាត និងសម្លាប់រង្គាល។ ការចាប់ខ្លួន និងឃុំខ្លួនទៅលើជនជាតិចាម គឺធ្វើឡើងដោយទំនើងចិត្ត ពោលគឺជាការដកហូតសិទ្ធិសេរីភាពដោយគ្មានមូលហេតុ ឬ ស្ថាប័នណាមួយមកវិនិច្ឆ័យអំពីកំហុសដែលឈានដល់ការចាប់ខ្លួន និងឃុំខ្លួននោះទេ ត្រូវកំណត់ជាបទការដាក់ក្នុងមន្ទីរឃុំឃាំង។ ទន្ទឹមនឹងនេះ ក៏មានទារុណកម្មក្នុងទម្រង់ជាការវាយដំ និងការសួរចម្លើយ ដែលបណ្តាលឱ្យប៉ះពាល់ដល់ផ្លូវកាយ និងផ្លូវចិត្តរបស់ពួកគេ។

ក្រោយពីមានការបះបោរ ជនជាតិចាមត្រូវបានចាត់ទុកថាជាខ្មាំងត្រូវបានខ្មែរក្រហម បំបែកពួកគេចេញពីសហគមន៍ ដែលជាការធ្វើទុក្ខបុកម្នេញនយោបាយ។ ចេតនាកំណត់មុខសញ្ញាដើម្បីបង្ខំឱ្យចាកចេញពីទីកន្លែងដែលធ្លាប់រស់នៅ បណ្តាលឱ្យប៉ះពាល់ដល់ដល់ផ្លូវចិត្ត និងផ្លូវកាយរបស់ពួកគេ ហើយក៏ត្រូវបានចាត់ទុកជាអំពើអមនុស្សធម៌ផ្សេងទៀត ក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំ។ មិនតែប៉ុណ្ណោះ អំពើធ្វើទុក្ខបុកម្នេញសាសនាបានកើតឡើង ដោយការបង្ខំឱ្យបរិភោគសាច់ជ្រូក ហាមឃាត់ការប្រតិបត្តិសាសនា ទំនៀមទម្លាប់ ប្រពៃណី រួមទាំងការប្រើប្រាស់ភាសាកំណើតជាដើម។

**ង- សកម្មភាពប្រឆាំងនឹងជនជាតិវៀតណាម**

ជនជាតិវៀតណាមត្រូវបានខ្មែរក្រហមធ្វើសកម្មភាពសម្លាប់ដោយចេតនា នៅទីកន្លែងនានានៃដែនដីកម្ពុជា។ តួយ៉ាងបក្សកុម្មុយនីស្តកម្ពុជាបានចេញបញ្ជាឱ្យវាយប្រហារទៅលើទូកនេសាទ ដែលបណ្តាលឱ្យជនស៊ី

វិលជាច្រើនបានស្លាប់បាត់បង់ជីវិត។ ជនជាតិវៀតណាម ក៏ជាមុខសញ្ញាដែលកំណត់ទុកជាមុនដើម្បីយកទៅសម្លាប់ចោលជាលក្ខណៈទ្រង់ទ្រាយធំ ដែលទង្វើនេះត្រូវបានចាត់ទុកជាការធ្វើមនុស្សឃាត និងសម្លាប់រង្គាល។

ក្រៅពីនេះ ការបញ្ជាឱ្យបញ្ជូនប្រជាជនវៀតណាមឱ្យចាកចេញពីប្រទេសកម្ពុជា ក្រោមទម្រង់ជាការបង្ខិតបង្ខំ និងគម្រាមកំហែង គឺជាអំពើការនិរទេស។ បន្ថែមពីនេះ ខ្មែរក្រហមបានធ្វើសកម្មភាពចាប់ខ្លួន ឃុំខ្លួន និងសម្លាប់ចោលដោយសារតែមូលហេតុពូជសាសន៍ គឺជាអំពើបំពានសិទ្ធិជាមូលដ្ឋាន ដែលជាបទធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍។

**ច- អំពើទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍**

ការរៀបអាពាហ៍ពិពាហ៍ធ្វើឡើងដោយបង្ខំ ក្រោមការគម្រាមកំហែង បំពានទៅនឹងប្រពៃណី វប្បធម៌ និងទំនៀមទម្លាប់របស់កម្ពុជា ពោលគឺអង្គការខ្មែរក្រហមបានរំលោភបំពានសិទ្ធិស្វ័យសម្រេចរបស់បុគ្គល ដែលតម្រូវឱ្យពួកគេធ្វើតាមបញ្ជា។ ការប្រព្រឹត្តិដូច្នេះ បានបង្កឱ្យមានផលវិបាកផ្នែកស្មារតី ផ្លូវកាយ និងផ្លូវចិត្ត ក៏ដូចជាសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិផងដែរ ដែលជាអំពើអមនុស្សធម៌ផ្សេងៗក្រោមទម្រង់ជាការប្រព្រឹត្តិដែលកំណត់ថាជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយដែលព្រឹត្តិការណ៍នេះបានកើតឡើងនៅទូទាំងប្រទេស។

បន្ទាប់ពីកិច្ចអាពាហ៍ពិពាហ៍ត្រូវបានបញ្ចប់ ប្តីប្រពន្ធតម្រូវឱ្យរួមភេទក្រោមទម្រង់ជាការបង្ខំ និងក្រោមស្ថានភាពនៃការគម្រាមកំហែង ពោលគឺសកម្មភាពរបស់ពួកគេត្រូវបានតាមដានពីសំណាក់កងឈ្លបតាមការបញ្ជាពីថ្នាក់លើ។ វិធានការអប់រំ ការដាក់ទណ្ឌកម្ម និងការគម្រាមដល់អាយុជីវិត ត្រូវបានអនុវត្តចំពោះប្តីប្រពន្ធណាដែលមិនប្រតិបត្តិតាមការបញ្ជារបស់អង្គការ។ ទង្វើនេះត្រូវបានចាត់ទុកជាការរំលោភបំពានផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលជាអំពើអមនុស្សធម៌ផ្សេងៗនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។

**៣.៣.១.២ ការបំពានយ៉ាងធ្ងន់ធ្ងរទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ**

ចំពោះអំពើដែលរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ គឺកើតឡើងនៅក្នុងមន្ទីរស២១ ទៅលើជនដែលស្ថិតនៅក្រោមការការពារដោយអនុសញ្ញានេះ ដែលទាក់ទងនឹងសំណុំរឿងលេខ០០១ ពាក់ព័ន្ធនឹងអំពើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ និងការបំពានសិទ្ធិ ការបំពានសិទ្ធិ ដែលធ្វើឡើងដោយបុគ្គលិកមន្ទីរទៅលើឈ្លើយសឹកដែលបានចាប់ខ្លួន និងជនស៊ីវិលវៀតណាមប្រមាណជា ៤០០នាក់។[182]

[182] សាលក្រម ០០២/០២ នួន ជា និង ខៀវ សំផន, E465, កថាខណ្ឌទី ២៦១៩ ដល់ ២៦៣៥។

### ៣.៣.១.៣ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍

#### ក. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិវៀតណាម

បទប្រល័យពូជសាសន៍ ត្រូវបានរកឃើញតាមរយៈការធ្វើមនុស្សឃាតលើសមាជិកនៃក្រុមជនជាតិវៀតណាមនៅទូទាំងប្រទេសកម្ពុជាដែលជាក្រុមពូជសាសន៍ជាតិពន្ធុ ចាប់ពីខែមេសា ឆ្នាំ១៩៧៧ ដល់ថ្ងៃទី ០៦ ខែមករា ឆ្នាំ១៩៧៩។[183] ការសម្លាប់ ធ្វើឡើងជាប្រព័ន្ធ និងកំណត់គោលដៅជាក់លាក់ដោយបក្សកុម្មុយនីស្តកម្ពុជាទៅលើជនជាតិវៀតណាមដែលមានវត្តមាននៅក្នុងប្រទេសកម្ពុជា ឬ រស់នៅប្រទេសកម្ពុជា ឬបានចូលក្នុងប្រទេសកម្ពុជានៅក្នុងអំឡុងពេលជម្លោះប្រដាប់អាវុធ។ ស្តែងឡើងតាមការសម្លាប់ ១)អ្នកនេសាទ និងជនភៀសខ្លួនជនជាតិវៀតណាមដែលបានឆ្លងដែនមកកម្ពុជានៅផែអូរឈើទាលក្រោយខែមេសា ឬខែឧសភា ឆ្នាំ ១៩៧៧ និង ២) ជនជាតិវៀតណាមដែលចាប់បានដោយកងពល១៦៤ នៅថ្ងៃទី១៩ និងទី២០ ខែមីនា ឆ្នាំ ១៩៧៨ និងជនជាតិវៀតណាម ៧៨០នាក់ នៅមន្ទីរស២១ និងមន្ទីរសន្តិសុខអូរកន្សែង។ បុគ្គលទាំងនេះ សុទ្ធសឹងតែជាក្រុមដែលត្រូវទទួលបានការការពារ និងត្រូវបានកំណត់គោលដៅសម្រាប់ការបំផ្លាញដោយខ្មែរក្រហម។ មួយវិញទៀតការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តស្វាយរៀង ក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យ ខេត្តកំពង់ឆ្នាំង វត្តខ្សាច់ និងខេត្តក្រចេះភ្ជាប់នឹងអត្ថិភាពនៃគោលនយោបាយដែលបង្កើតឡើងដោយមជ្ឈិម ក្នុងការកំណត់គោលដៅលើជនជាតិវៀតណាមដែលចាត់ទុកជាសត្រូវ ក៏ជាការសម្លាប់នៅក្នុងនៅឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិវៀតណាមដែរ។ អ.ជ.ស.ដ រកឃើញថា ចារីមានចេតនាជាក់លាក់ក្នុងការបំផ្លាញក្រុមជនជាតិវៀតណាមទាំងអស់ដែលស្ថិតនៅក្នុងប្រទេសកម្ពុជា ព្រោះជាក្រុមមួយដាច់ដោយឡែកដែលត្រូវលុបបំបាត់ចោល។ នេះមានន័យថា ប្រសិនបើការបំផ្លាញទទួលបានជោគជ័យជនជាតិវៀតណាមនឹងបាត់ចេញ ឬ ផុតពូជពីប្រទេសកម្ពុជា។ ហេតុនេះ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិវៀតណាមត្រូវបានបង្ហាញ។[184]

#### ខ. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍លើជនជាតិចាម

ផ្អែកតាមគោលនយោបាយទូទាំងប្រទេស និងការអនុវត្តគោលនយោបាយដែលកម្រិតត្រឹមមន្ទីរសន្តិសុខភូមិទ្រា និងមន្ទីរសន្តិសុខអូរត្រកួន ការធ្វើមនុស្សឃាត លើសមាជិកនៃក្រុមជនជាតិចាមចាប់តាំងពីឆ្នាំ ១៩៧៧ គឺជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។[185] ចាប់ផ្តើមពី ការដាក់ចេញនូវគោលនយោបាយនៅទូទាំងប្រទេស ក្នុងការរឹតបន្តឹងលើការអនុវត្តវប្បធម៌ និងសាសនា ការវាយបង្ក្រាបយ៉ាងឃោរឃៅចំពោះការបះបោរ ការ

---

[183] សាលក្រម ០០២/០២ នួន ជា និង ខៀវ សំផន, E465, កថាខណ្ឌទី ៣៣៦០។

[184] អ.វ.ត.ក, *សហព្រះរាជអាជ្ញា តទល់នឹង ជនជាប់ចោទ នួន ជា និង ខៀវ សំផន*, សាលដីកាសំណុំរឿង ០០២/០២, ១៩ កញ្ញា ២០០៧/អវតក /អជសដ, F76, កថាខណ្ឌទី ១៥៩២ ដល់ ១៦៣៨ ។ "ចាប់ពីនេះសូមហៅកាត់ថា សាលដីកាសំណុំរឿង ០០២/០២ នួនជា និង ខៀវសំផន, F76"

[185] សាលក្រមសំណុំរឿង ០០២/០២ នួន ជា និង ខៀវ សំផន, E465, កថាខណ្ឌទី ៣១៨៤ (១)។

បំបែកសហគមន៍ចាម និងបទបញ្ជាឱ្យបោសសម្អាតចោលជនជាតិចាមទាំងអស់ដែលមិនបានសម្របខ្លួនចូលក្នុងសង្គមខ្មែរ។ គោលនយោបាយខ្មែរក្រហម បានកំណត់គោលដៅជាក់លាក់ចំពោះជនជាតិចាមថាជាក្រុមជាតិពន្ធុ និងជាក្រុមនៃសាសនាដោយឡែក ហើយនៅត្រឹមឆ្នាំ ១៩៧៧ កម្មាភិបាល បក្សកុម្មុយនីស្តកម្ពុជា បានផ្សព្វផ្សាយបទបញ្ជាឱ្យសម្លាប់ជនជាតិចាមទាំងអស់ ដែលការចាប់ខ្លួន និងការសម្លាប់ទ្រង់ទ្រាយធំចាប់ផ្ដើមឡើងនៅក្នុងស្រុកកងមាស និងនាំទៅសម្លាប់នៅវត្តអូរត្រកួន។ អង្គជំនុំជម្រះរកឃើញថា "ចារីនៅមន្ទីរសន្តិសុខវត្តអូរត្រកួន និងមន្ទីរសន្តិសុខភូមិទ្រា មានចេតនាប្រល័យពូជសាសន៍ចំពោះជនជាតិចាមដែលត្រូវបានរកឃើញថាស្លាប់គឺស្ថិតក្នុងទីតាំងទាំងនោះ"[186]។ ហេតុនេះ អ.ជ.ស.ដ សន្និដ្ឋានថា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តលើជនជាតិចាម។[187]

### ៣.៣.២ ការទទួលខុសត្រូវព្រហ្មទណ្ឌជាឯកត្តបុគ្គល

មេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជាដែលដឹកនាំប្រទេសក្នុងរបបខ្មែរក្រហម មានគោលបំណងរួមគ្នាក្នុងការអនុវត្តបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សតាមរយៈ "មហាលោតផ្លោះ មហាអស្ចារ្យ" ដែលរៀបចំឡើងដើម្បីកសាងប្រទេសពីសំណាក់ខ្មាំង និងកែប្រែប្រជាជនទាំងស្រុងឱ្យក្លាយជាសង្គមខ្មែរដែលមិនមានសាសនា ដោយរួបរួមគ្នាដែលមានតែវណ្ណៈកម្មករ និងកសិករ។[188] ដូច្នេះគោលនយោយបាយទាំងឡាយដែលបានដាក់ចេញ គឺមានគោលដៅដើម្បីសម្រេចឱ្យបាននូវគោលបំណងរួមរបស់បក្ស ដែលបង្កឱ្យកើតមានឧក្រិដ្ឋកម្មទូទាំងប្រទេសកម្ពុជា។ នួន ជា និង ខៀវ សំផន បានចូលរួមចំណែកក្នុងការរៀបចំ និងដាក់ចេញនូវគោលនយោបាយនានា ជាមួយនឹងមេដឹកនាំដទៃទៀតមានដូចជា ប៉ុល ពត អៀង សារី អៀង ធីរិទ្ធ ដើម្បីសម្រេចគោលបំណងរួមរបស់បក្ស។

#### ៣.៣.២.១ ការទទួលខុសត្រូវរបស់នួន ជា

ផ្អែកតាមតួនាទីរបស់ នួន ជា បានបង្ហាញយ៉ាងច្បាស់ថាគាត់ត្រូវបានចាត់ទុកថាជាបុគ្គលដ៏មានឥទ្ធិពលមួយនៅក្នុងជួរបក្សដោយចូលរួមក្នុងការប្រជុំ រៀបចំ និងដាក់ចេញគោលនយោបាយនានា ជាមួយនឹងថ្នាក់ដឹកនាំនៃបក្សកុម្មុយនីស្តកម្ពុជា។ នួន ជា បានទទួលស្គាល់ថាបានដឹងអំពីគោលនយោបាយនានា និងឧក្រិដ្ឋកម្មដែលកើតចំពោះប្រជាជនខ្មែរ ក៏ដូចជាជនជាតិវៀតណាម ជនជាតិចាម និងអតីតរដ្ឋការនៃរបបសាធារណរដ្ឋ

[186] សាលក្រមសំណុំរឿង ០០២/០២ នួន ជា និង ខៀវ សំផន, E465, កថាខណ្ឌទី ៣៣៤៧។

[187] ប្រភពដូចខាងលើ, កថាខណ្ឌទី ៣៣៤៣ ដល់ ៣៣៤៨។

[188] ប្រភពដូចខាងលើ, កថាខណ្ឌទី ៤០៦៨។

ខ្មែរ នានាដែលប្រព្រឹត្តបក្សកុម្មុយនីស្តកម្ពុជា។[189] បន្ថែមពីនេះ គាត់ក៏ជាអ្នកទទួលរបាយការណ៍ពីគណៈគ្រប់គ្រងបណ្ដាភូមិភាគ និងព័ត៌មានទាក់ទងនឹងការអនុវត្តគោលនយោបាយនានាផងដែរ។[190]

តាមរយៈសកម្មភាព និងតួនាទី នួន ជា បានចូលរួមចំណែកក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ដោយការចូលរួមដោយផ្ទាល់ ឬ ដោយប្រយោល តាមរយៈការប្រើប្រាស់ចារីឱ្យប្រព្រឹត្តអំពើល្មើសក្នុងគោលដៅសម្រេចគោលបំណងរួមរបស់បក្សជាដើម។ សកម្មភាពនៃការលើកទឹកចិត្ត និងគាំទ្រផ្នែកស្មារតីទៅលើកម្មាភិបាលនានា បានស្ដែងឡើងតាមរយៈការផ្ដល់ការណែនាំ ការបើកវគ្គបណ្ដុះបណ្ដាល និងការផ្សព្វផ្សាយនូវមាគ៌ាបក្ស ដែលជាកត្តាជំរុញដល់ចារីឱ្យប្រព្រឹត្តនូវឧក្រិដ្ឋកម្មផ្សេងៗ ពោលគឺ នួន ជា បានបំពេញភារកិច្ចយ៉ាងសកម្មដើម្បីអនុវត្តគោលនយោបាយរបស់បក្ស។

#### ៣.៣.២.២ ការទទួលខុសត្រូវរបស់ ខៀវ សំផន

ខៀវ សំផន បានទទួលស្គាល់អំពីការដឹងជាទូទៅអំពីគោលនយោបាយបក្ស និងឧក្រិដ្ឋកម្មនានាដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។[191] តាមរយៈតួនាទី និងការចូលរួមប្រជុំជាមួយគណៈកម្មាធិការអចិន្ត្រៃយ៍ ក៏ដូចជាការចូលរួមសម្រេចអំពីកិច្ចការចាំបាច់ជាច្រើន អាចបញ្ជាក់បានថាគាត់បានដឹងអំពីលទ្ធភាពដែលបណ្ដាលឱ្យកើតមានឧក្រិដ្ឋកម្មនានា។ ខៀវ សំផន ក៏ជាបុគ្គលដែលជាប់ពាក់ព័ន្ធនឹងគោលបំណងរួមរបស់បក្សកុម្មុយនីស្ត ដោយមានការគាំទ្រ ជំរុញ លើកទឹកចិត្ត និងណែនាំដល់កម្មាភិបាល អំពីការអនុវត្តគោលនយោបាយនានាក្នុងគោលដៅសម្រេចគោលបំណងរួម ពោលគឺ ខៀវ សំផន បានប្រព្រឹត្តតាមរយៈសហឧក្រិដ្ឋកម្មរួម។

### ៣.៣.៣ ទោសទណ្ឌរបស់សហជនជាប់ចោទ

#### ៣.៣.៣.១ សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង

នៅក្នុងសំណុំរឿង ០០២/០២ អ.ជ.ស.ដ បានរកឃើញថា នួន ជា និង ខៀវ សំផន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌជាលក្ខណៈបុគ្គលលើបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ។ អង្គជំនុំជម្រះបានបញ្ជាក់ថា ផ្អែកលើអំពើល្មើសដូចគ្នានៃការធ្វើមនុស្សឃាត និងការសម្លាប់រង្គាលដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅមន្ទីរស២១ មន្ទីរសន្តិសុខក្រាំងចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រាល និងចំពោះការប្រព្រឹត្តិលើជនជាតិវៀតណាម និងជនជាតិចាម ត្រូវផ្ដន្ទាទោសត្រួតគ្នាទៅលើបទសម្លាប់រង្គាលតែប៉ុណ្ណោះ។ ដោយហេតុថា អំពើទាំងពីរសុទ្ធ

---

[189] ប្រភពដូចខាងលើ, កថាខណ្ឌទី ៤០៧៨។

[190] ប្រភពដូចខាងលើ, កថាខណ្ឌទី ៤០៨១។

[191] សាលក្រម ០០២/០២ នួន ជា និង ខៀវ សំផន, E465, កថាខណ្ឌទី ៤២០៥។

សឹងតម្រូវឱ្យមានការស្លាប់ដែលកើតចេញពីអំពើសកម្ម ឬ អកម្ម ប៉ុន្តែការសម្លាប់រង្គាលតម្រូវឱ្យមានការសម្លាប់ទ្រង់ទ្រាយធំ។ ហេតុនេះ ការសម្លាប់រង្គាលជាបទល្មើសជាក់លាក់ដែលស្រូបបញ្ចូលការធ្វើមនុស្សឃាត។ មួយវិញទៀត ការផ្តន្ទាទោសចំពោះការធ្វើបាបដោយអមនុស្សធម៌ និងការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬ ឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព នៅមន្ទីរស២១ ដែលជាការបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ត្រូវផ្តន្ទាសត្រួតគ្នាលើការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬ ឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាពតែប៉ុណ្ណោះ។ ដោយហេតុថា ចេតនាដែលបង្កឱ្យមានរបួសធ្ងន់ធ្ងរទាំងនោះ នឹងបង្កើតឱ្យមានអំពើអមនុស្សធម៌កើតឡើង ហើយចេតនាបង្កនេះ មានកម្រិតធ្ងន់ធ្ងរជាក់លាក់ជាង។ ហេតុនេះ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬ ឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ស្រូបបញ្ចូលការធ្វើបាបដោយអមនុស្សធម៌។

ជាចុងក្រោយ តាមរយៈអំពើសកម្ម និងអកម្មរបស់សហជនជាប់ចោទដែលបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជា ចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ អ.ជ.ស.ដ សម្រេចផ្តន្ទាទោស ជនជាប់ចោទ នួន ជា និង ខៀវ សំផន ដាក់ពន្ធនាគារអស់មួយជីវិតលើ៖[192]

- ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈ ការសម្លាប់រង្គាល ការធ្វើមនុស្សឃាត ការនិរទេស ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា និងការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ និងអំពើអនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោយមទម្រង់ជាការប្រព្រឹត្តិដែលត្រូវបានកំណត់ថាជាការបាច់ខ្លួនដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប្រព្រឹត្ត ដែលត្រូវបានកំណត់ថាជាការជម្លៀសដោយបង្ខំ អំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប្រព្រឹត្តដែលត្រូវបានកំណត់ថា ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ
- ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ តាមរយៈការធ្វើមនុស្សឃាតដោយចេតនា ការធ្វើទារុណកម្ម ការធ្វើបាបដោយអមនុស្សធម៌ ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោដោយយុត្តិធម៌និងទៀងទាត់ និងការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់។

[192] សាលក្រមសំណុំរឿង ០០២/០២ នួន ជា និង ខៀវ សំផន, E465 , ផ្នែកសម្រេចសេចក្តី។

ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ខៀវ សំផន ផ្តន្ទាទោសទាក់ទងនឹងការសម្លាប់សមាជិកនៃក្រុមជនជាតិវៀតណាម។ រីឯ នួន ជា ត្រូវផ្តន្ទាទោសទាក់ទងនឹងការសម្លាប់សមាជិកនៃក្រុមជនជាតិវៀតណាម និង ជនជាតិចាម។

**៣.៣.៣.២ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល**

អ.ជ.ត.ក បានតម្កល់ និងបដិសេធផ្នែកខ្លះនៃសាលក្រមរបស់ អ.ជ.ស.ដ ដោយការរកឃើញកំហុសនៅក្នុងការកំណត់កំណត់ពិរុទ្ធភាពរបស់ជនជាប់ចោទ។ ទាក់ទងនឹង ការធ្វើទុក្ខបុកម្នេញផ្អែកនយោបាយលើប្រជាជនថ្មីនៅការដ្ឋាន ការធ្វើទំនប់១មករា អ.ជ.ស.ដ មានកំហុសក្នុងការយល់ឃើញថា ទង្វើនេះបានបំពានសិទ្ធិជាមូលដ្ឋានតាមរយៈការប្រព្រឹត្តិលើប្រជាជនថ្មីដែលត្រូវទទួលបានការប្រព្រឹត្តិស្មើភាពគ្នា។[193] រីឯ អំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅមន្ទីរសន្តិសុខភ្នំក្រោល ដែលបានផ្អែកលើអំពើមនុស្សឃាតពីរករណីដាច់ដោយឡែកពីគ្នា ដែលជាបំណែកមួយតូចតាចនៃការសម្លាប់ជារួម នោះអំពើមនុស្សឃាតនៅក្នុងករណីនេះពុំមានអានុភាពគ្រប់គ្រាន់លើទោសនោះឡើយ។[194] ហេតុនេះ អ.ជ.ត.ក បដិសេធការដាក់ពិរុទ្ធភាពលើ ខៀវ សំផន ទាក់ទងនឹងការធ្វើទុក្ខបុកម្នេញផ្អែកនយោបាយលើប្រជាជនថ្មីនៅការដ្ឋាន ការធ្វើទំនប់១មករា និងអំពើមនុស្សឃាតក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅមន្ទីរសន្តិសុខភ្នំក្រោល។ បន្ថែមពីនេះទៅទៀត អ.ជ.ត.ក រកឃើញថា អ.ជ.ស.ដ មានកំហុសដែលដកអំពើមនុស្សឃាតចេញពីគោលបំណងរួម និងដាក់ឱ្យទទួលខុសត្រូវចំពោះការជួយទំនុកបម្រុង។ ដោយអំពើមនុស្សឃាតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានប្រព្រឹត្តឡើងដោយចេតនាប្រយោល ដែលវារួមបញ្ចូលទៅក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម។ ហេតុនេះ អ.ជ.ត.ក សម្រេចកែប្រែទម្រង់នៃការទទួលខុសត្រូវពីការទំនុកបម្រុងទៅជាការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមវិញ។[195]

ជាចុងក្រោយអ.ជ.ត.ក សម្រេចដាក់ទោស ខៀវ សំផន ឱ្យជាប់ពន្ធនាគារអស់មួយជីវិត ទៅលើ៖

ក. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ:

- បទមនុស្សឃាតដោយចេតនាប្រយោល តាមរយៈសហឧក្រិដ្ឋកម្មរួមទាក់ទងនឹងអង្គហេតុនៃការស្លាប់ដែលបានកើតឡើងនៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់ ១មករា ការដ្ឋានសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខស២១ និង មន្ទីរសន្តិសុខក្រាំងតាចាន់។

[193] សាលដីកាសំណុំរឿង ០០២/០២ នួនជា និង ខៀវសំផន, F76, កថាខណ្ឌទី ៩៥៩ ដល់ ៩៦៦។

[194] ប្រភពដូចខាងលើ, កថាខណ្ឌទី១៧០។

[195] ប្រភពដូចខាងលើ, កថាខណ្ឌទី១៩៦៨ និង ១៩៧៦។

- បទសម្លាប់រង្គាល ទាក់ទងនឹងអង្គហេតុនៃការសម្លាប់ជនជាតិចាមដែលបានកើតឡើងនៅភូមិទ្រា និងវត្តអូរត្រកួន និងការសម្លាប់ជនជាតិវៀតណាមក្នុងខេត្តស្វាយរៀង ក្នុងដែនទឹកកម្ពុជាប្រជាធិបតេយ្យក្នុងខេត្តកំពង់ឆ្នាំង នៅវត្តខ្សាច់ និងខេត្តក្រចេះ ព្រមទាំងមន្ទីរសន្តិសុខអូរកន្សែង។
- បទការដាក់ឱ្យទៅជាទាសករ ទាក់ទងនឹងអង្គហេតុនៃការធ្វើការដោយបង្ខំរបស់អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខភ្នំក្រាល។
- បទការនិរទេសជនជាតិវៀតណាម ទាក់ទងនឹងអង្គហេតុនៃការនិរទេសប្រជាជនវៀតណាមចេញពីស្រុកត្រាំងកក់ និងពីខេត្តព្រៃវែង។
- បទការធ្វើទារុណកម្ម ទាក់ទងនឹងអង្គហេតុនៃការធ្វើបាបផ្លូវចិត្ត និងផ្លូវកាយលើជនជាតិចាមនៅភូមិទ្រា។
- បទធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ទាក់ទងនឹងអង្គហេតុនៃការប្រព្រឹត្តិលើជនជាតិចាម និងការចាត់ទុកជា សត្រូវពិត ឬ តាមការសន្មតរបស់បក្សកុម្មុយនីស្តកម្ពុជា រួមទាំងអតីតទាហាន និងអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ និងប្រជាជនថ្មី នៅសហករណ៍ត្រាំកក់ ការដ្ឋានធ្វើការទំនប់ត្រពាំងថ្ម ការដ្ឋានធ្វើការទំនប់១មករា (មិនជាប់ពាក់ព័ន្ធទៅនឹងប្រជាជនថ្មី) ការសាងសង់ព្រលានយន្តហោះខេត្តកំពង់ឆ្នាំង មន្ទីរសន្តិសុខស២១ មន្ទីរសន្តិសុខក្រាំងតាចាន់ មន្ទីរសន្តិសុខអូរកន្សែង និងមន្ទីរសន្តិសុខភ្នំក្រាល។
- បទធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ទាក់ទងនឹងអង្គហេតុនៃការរើសអើងជនជាតិចាម។
- បទធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនា ទាក់ទងនឹងអង្គហេតុនៃការរើសអើងចំពោះពុទ្ធសាសនិក និងព្រះសង្ឃនៃពុទ្ធសាសនា។
- បទធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ទាក់ទងនឹងអង្គហេតុនៃការរើសអើងជនជាតិវៀតណាម នៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខ ស២១ មន្ទីរសន្តិសុខអូរកន្សែង និងខេត្តព្រៃវែង និងស្វាយរៀង។
- បទអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានចាត់ទុកថាជាការបាត់ខ្លួនដោយបង្ខំ ទាក់ទងនឹងអង្គហេតុនៃការធ្វើឱ្យបាត់ខ្លួននៅសហករណ៍ត្រាំកក់ មន្ទីរសន្តិសុខក្រាំងតាចាន់ និងមន្ទីរសន្តិសុខភ្នំក្រាល។
- បទអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើដែលត្រូវបានចាត់ទុកថាជាការផ្លាស់ទីដោយបង្ខំ ទាក់ទងនឹងអង្គហេតុនៃការផ្លាស់ទីដោយបង្ខំជនជាតិចាមក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២។

- បទអំពើអមនុស្សធម៌ដទៃទៀតតាមរយៈអំពើនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ និងបទអំពើអមនុស្សធម៌ដទៃទៀតក្នុងទម្រង់នៃអំពើហិង្សាផ្លូវភេទ ដែលត្រូវបានចាត់ទុកថាជាការរួមភេទដោយបង្ខំក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពាក់ព័ន្ធនឹងជនរងគ្រោះជាស្ត្រី និងទទួលយកផ្នែកខ្លះនៃបណ្ដឹងសាទុក្ខរបស់ព្រះរាជអាជ្ញា ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំពាក់ព័ន្ធនឹងជនរងគ្រោះជាបុរស។ អំពើទាំងនេះ ទាក់ទងនឹងអង្គហេតុនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ការរួមភេទដោយបង្ខំ ក្នុងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៃគោលនយោបាយបទបញ្ជារៀបអាពាហ៍ពិពាហ៍ទូទាំងប្រទេស។

ខ. ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ: ទាក់ទងនឹងអង្គហេតុនៃការសម្លាប់ដោយចេតនា ការធ្វើទារុណកម្ម អំពើអមនុស្សធម៌ ការបង្កឱ្យមានការឈឺចាប់ ឬ ព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬ សុខភាព ការដកហូតឈ្លើយសឹក ឬ ជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះត្រឹមត្រូវ និងទៀងទាត់ និងការឃុំឃាំងខុសច្បាប់លើជនស៊ីវិល។

គ. ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍: ទាក់ទងនឹងអង្គហេតុនៃការសម្លាប់ជនជាតិវៀតណាម។

## ៣.៤ ការសម្រេចអំពីផ្នែកសំណងរដ្ឋប្បវេណី

វិធានការនៃការផ្តល់នូវសំណងការខូចខាតដែលរួមមាន សំណងផ្លូវចិត្ត និងសមូហភាព គឺមានចែងក្នុងវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក វិសោធនកម្មលើកទី១០ ត្រង់វិធាន ២៣ ស្ទួនបួន ដែលចែងថា៖

> តាមគោលបំណងនៃវិធានទាំងនេះ សំណងផ្លូវចិត្ត និងសមូហភាព គឺជាវិធានទាំងឡាយដែល: ក) ទទួលស្គាល់នូវការខូចខាតដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលរងដោយសារការប្រព្រឹត្តិនូវបទឧក្រិដ្ឋរបស់ជនជាប់ចោទដែលត្រូវបានផ្តន្ទាទោស និង ខ) ផ្តល់ផលប្រយោជន៍ដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើឡើងការខូចខាតនេះ។

ជាគោលការណ៍ច្បាប់ ជនដែលរងគ្រោះដោយសារអំពើបំពាន អាចស្នើសុំទៅតុលាការដើម្បីទាមទារសំណងការខូចខាតពីជនបង្កបាន។ ប៉ុន្តែ នៅក្នុងរឿងក្តីក្រោមសមត្ថកិច្ចរបស់ អ.វ.ត.ក គឺដើមបណ្តឹងរដ្ឋប្បវេណីពុំអាចទទួលបាននូវការផ្តល់សំណងក្រោមទម្រង់ជាទឹកប្រាក់ដោយផ្ទាល់នោះទេ ដោយសារតែជនរងគ្រោះមានចំនួនដ៏ច្រើនលើសលប់។[196] ផ្ទុយវិញ អ.វ.ត.ក នឹងពិចារណាទៅលើសំណងផ្លូវចិត្ត និងជាសមូហភាព ដែលមានលក្ខណៈសមស្របតាមការទាមទាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយដែលអាចអនុវត្តទៅបាន។[197]

[196] វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក, វិសោធនកម្មលើកទី ១០, វិធាន ២៣ស្ទួន ៤។

[197] ប្រភពដូចខាងលើ, វិធាន ២៣ស្ទួន ៤ កថាខណ្ឌទី៣ ចំណុច ខ។

### ៣.៤.១ សំណុំរឿងលេខ ០០១

ដើមបណ្តឹងរដ្ឋប្បវេណីបានធ្វើស្នើនូវគម្រោងចំនួន ០៨ ដើម្បីឱ្យ អ.ជ.ស.ដ ពិចារណាក្នុងការសម្រេចអំពីសំណង ដែលរួមមាន៖[198]

- ការបញ្ចូលឈ្មោះរបស់ជនរងគ្រោះនៅក្នុងសាលក្រម
- ការចងក្រង និងការបោះពុម្ពផ្សាយពាក្យសម្តីសុំអភ័យទោសរបស់ជនជាប់ចោទ
- ការបោះពុម្ព និងការផ្សព្វផ្សាយសាលក្រម
- សំណងជាប្រាក់ជាលក្ខណៈបុគ្គលសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ឬ ការបង្កើតនូវមូលនិធិមួយ
- សុំវិធានការមួយចំនួនពីរាជរដ្ឋាភិបាល
- កសាងវត្ត និងបូជនីយដ្ឋានផ្សេងៗទៀត
- សុំឱ្យអភិរក្សបណ្ណសារមន្ទីរស២១ គំនូររបស់ វ៉ាន់ ណាត និងបរិវេណមន្ទីរស២១ និងស២៤
- សុំផ្តល់នូវការថែទាំសុខភាពដោយឥតគិតថ្លៃ និងវិធានការអប់រំ

សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីលើគម្រោងចំនួន ០៨ខាងលើ ត្រូវបាន អ.ជ.ស.ដ សម្រេចទទួលយកផ្នែកខ្លះ ដោយសារតែភាគច្រើននៃគម្រោងដែលបានស្នើឡើងគឺពុំមានលក្ខណៈជាក់លាក់ និងអលទ្ធភាពក្នុងការអនុវត្ត ពោលគឺពុំបានបំពេញឱ្យគ្រប់តាមលក្ខខណ្ឌនៃការទាមទារសំណងដែលចែងក្នុងវិធានផ្ទៃក្នុង។ ជាចុងក្រោយ អ.ជ.ស.ដ បានសម្រេចឱ្យចងក្រង និងដាក់នៅលើគេហទំព័រផ្លូវការរបស់ អ.វ.ត.ក នូវសេចក្តីថ្លែងអភ័យទោសទាំងអស់ និងការទទួលស្គាល់នូវការទទួលខុសត្រូវរបស់ជនជាប់ចោទ នៅក្នុងរយៈពេល ១៤ថ្ងៃ ហើយដែលមានការយល់ស្របពី អ.ជ.ត.ក ក្រោយពីបានច្រាលចោលបណ្តឹងសាទុក្ខរបស់ដើមបណ្តឹងរដ្ឋប្បវេណី។[199]

### ៣.៤.២ សំណុំរឿងលេខ ០០២/០១

នៅក្នុងសំណុំរឿងលេខ ០០២/០១ គម្រោងចំនួន ១១ ក្នុងចំណោម ១៣ ត្រូវបាន អ.ជ.ស.ដ សម្រេចទទួលស្គាល់ជាសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី ដោយហេតុថាគម្រោងទាំងនោះមានលក្ខណៈជាក់លាក់ និងអាចអនុវត្តបាន ស្របតាមវិធាន ២៣ ស្ទួន៤ នៃវិធានផ្ទៃក្នុង ដែលមានដូចជា៖[200]

ក- ការបង្កើតទិវាជាតិនៃការចងចាំ ដែលមានការគាំទ្រពីសំណាក់រាជរដ្ឋាភិបាល និងយល់ព្រមកំណត់យកថ្ងៃទី២០ ខែឧសភា ដើម្បីប្រារព្ធទិវានេះ។

---

198 សាលក្រម ០០១, កាំង ហ្គេចអ៊ាវ, E188, កថាខណ្ឌទី៦៦៧ ដល់ ៦៧៥។

199 ពាក្យសុំអភ័យទោសរបស់ កាំង ហ្គេចអ៊ាវ នៅក្នុងអំឡុងពេលសវនាការ។ https://www.eccc.gov.kh/km/node/17958

200 សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី១១២៦ ដល់ ១១៦៤។

ខ- ការសាងសង់ស្តូបនៅរាជធានីភ្នំពេញសម្រាប់រំឭកដល់ជនរងគ្រោះ ដោយសារការជម្លៀសដោយបង្ខំ បច្ចុប្បន្នស្តូបនេះត្រូវបានសាងសងរួចរាល់ ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណសួនរង្វង់មូលស្ពាតចាស់ ទល់មុខវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ក្រោមជំនួយពីសមាជិកនៃសភាប្រទេសបារាំង។

គ- វិធីព្យាបាលតាមរបៀបការចងក្រងជាសក្ខីកម្ម គឺសំដៅលើការកត់ត្រារឿងហេតុជាលាយលក្ខណ៍អក្សរអំពីបទពិសោធន៍ដ៏តក់ស្លុតដោយមានជំនួយពីអ្នកជំនាញផ្លូវចិត្ត។

ឃ- ការបង្កើតក្រុមជួយខ្លួនឯង ដែលអនុញ្ញាតឱ្យជនគ្រោះនៃការជម្លៀសដោយបង្ខំ អាចរៀបរាប់អំពីការឈឺចាប់របស់ពួកគេ ដែលនឹងជំរុញដល់ការធ្វើឱ្យកាត់បន្ថយជំងឺបាក់ស្បាត ក្រោមជំនួយ និងការរៀបចំរបស់អង្គការចិត្តសង្គមវប្បធម៌ (TOP)។

ង- ការតាំងពិពណ៌អចិន្ត្រៃយ៍ជាសាធារណៈ នូវវត្ថុតាង ឯកសារ កំណត់ហេតុសំឡេង និងរូបភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រវត្តិសាស្ត្រជាដើម សម្រាប់ចែករំលែកដល់សាធារណជន ក្រោមកិច្ចសហការពីរដ្ឋាភិបាលអាល្លឺម៉ង់។

ច- ការតាំងពិពណ៌ចល័ត និងគម្រោងអប់រំ ដើម្បីស្វែងយល់អំពីប្រវត្តិសាស្ត្រ និងយុត្តិធម៌អន្តរកាលតាមរយៈការផ្សព្វផ្សាយដល់ប្រជាជនឱ្យបានដឹងអំពីឧក្រិដ្ឋកម្មនាសម័យខ្មែរក្រហម ក្រោមជំនួយរបស់រដ្ឋាភិបាលអាល្លឺម៉ង និងសហរដ្ឋអាមេរិក រួមជាមួយនឹងការសហការពីសំណាក់អង្គការក្រៅរដ្ឋាភិបាលមួយចំនួនផងដែរ។

ឆ- ការបញ្ចូលជំពូកស្តីពីការជម្លៀសប្រជាជនដោយបង្ខំ និងទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ ទៅក្នុងកម្មវិធីសិក្សារបស់សាលារៀននៅកម្ពុជា ដែលមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) បានបោះពុម្ពសៀវភៅសម្រាប់គ្រូបណ្តុះបណ្តាលក្រោមកិច្ចសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា។

ជ- ការសាងសង់មជ្ឈមណ្ឌលសិក្សាសន្តិភាព ដែលមានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីរបបខ្មែរក្រហម និងកិច្ចការរបស់ អ.វ.ត.ក។

ឈ- ការបោះពុម្ពកូនសៀវភៅអំពីអង្គហេតុដែលត្រូវបានសម្រេចក្នុងសំណុំរឿងលេខ ០០២/០១ និងការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

ញ- ការបោះពុម្ព និងផ្សព្វផ្សាយសាលក្រមសំណុំរឿង ០០២/០១ ដែលនឹងធ្វើឡើងជាពីរប្រភេទ គឺសាលក្រមដែលមានសំអាងហេតុពេញលេញ និងសាលក្រមសង្ខេប។

ដ- ការផ្សាយឈ្មោះ ដើមបណ្តឹងរដ្ឋប្បវេណីទៅក្នុងគេហទំព័ររបស់ អ.វ.ត.ក ដើម្បីជាការរក្សាទុកនូវការចូលរួមរបស់ពួកគេ។

### ៣.៤.៣ សំណុំរឿងលេខ ០០២/០២

នៅក្នុងសំណុំរឿងលេខ ០០២/០២ គម្រោងចំនួន ១៣ ក្នុងចំណោម ១៤ ត្រូវបាន អ.ជ.ស.ដ សម្រេចទទួលស្គាល់ជាសំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី ដោយហេតុថាគម្រោងទាំងនោះមានលក្ខណៈជាក់លាក់ និងអាចអនុវត្តបាន ស្របតាមវិធាន ២៣ ស្ទួន៤ នៃវិធានផ្ទៃក្នុង ដែលមានដូចជាៈ[201]

ក- កម្មវិធីសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហម គឺជាការចងក្រងនូវព័ត៌មានត្រឹមត្រូវ និងនិយាមខ្មែរក្រហម ដោយដាក់បញ្ចូលសម្ភារៈសោតទស្សន៍ និងរឿងរ៉ាវរបស់ដើមបណ្តឹងរដ្ឋប្បវេណី។

ខ- ការអប់រំប្រវត្តិសាស្ត្រខ្មែរក្រហមតាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់លោកគ្រូ អ្នកគ្រូ និងសាស្ត្រាចារ្យមហាវិទ្យាល័យ ដើម្បីជាប្រយោជន៍ដល់យុវជនកម្ពុជាឱ្យបានយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងបទពិសោធន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងជួយទប់ស្កាត់ការកើតឡើងវិញនូវឧក្រិដ្ឋកម្មនាពេលអនាគត។

គ- គម្រោងអន្តរព័ត៌មានប្រកបដោយភាពច្នៃប្រតិដ្ឋដើម្បីលើកកម្ពស់ការយល់ដឹងអំពីប្រវត្តិសាស្ត្រ និងភាពក្លាហានរបស់ពលរដ្ឋខ្មែរ ដែលនឹងមានការសម្តែងល្ខោន ការបញ្ចាំងខ្សែភាពយន្ត និងការតាំងរូបថត។

ឃ- ការផ្សព្វផ្សាយសហគមន៍ដែលពាក់ព័ន្ធនឹងជនជាតិចាម និងខ្មែរក្រហម ដោយអប់រំសាធារណជនអំពីបទពិសោធន៍របស់ប្រជាជនចាមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

ង- គម្រោងផ្កាស្លាក្រោមអង្គការ ដែលជាការបង្កើតផលិតកម្មរបាំបុរាណ និងការតាំងពិព័រណ៍ ពាក់ព័ន្ធនឹងបទបញ្ហានៃការរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ។

ច- គម្រោងសំឡេងពីជនជាតិភាគតិច ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជនអំពីការប្រព្រឹត្តទៅលើជនជាតិភាគតិចវៀតណាម និងចាម ដែលបានរស់នៅក្នុងរបបខ្មែរក្រហម។

ឆ- ការបោះពុម្ពសៀវភៅ ដែលជារឿងរ៉ាវមិនធ្លាប់បានដឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួមក្នុងសំណុំរឿងលេខ ០០២/០២ ដើម្បីផ្តល់ឱកាសដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការផ្សព្វផ្សាយជាសាធារណៈអំពីបទពិសោធន៍នៃការឈឺចាប់ដែលត្រូវគេទទួលស្គាល់។

ជ- ការប្រកួតប្រជែងតាក់តែងបទចម្រៀងក្នុងឆ្នាំ ២០១៦ របស់យុវជនទាក់ទងនឹងការចងចាំនៅកម្ពុជា។

ឈ- ផ្ទាំងគំនូរដើម្បីចងចាំអំពីក្រាំងតាចាន់ ដើម្បីរំលឹកពីការចងចាំ និងទទួលស្គាល់នូវការឈឺចាប់របស់ដើមបណ្តឹងរដ្ឋប្បវេណី។

[201] សាលក្រម ០០២/០១ នួនជា និង ខៀវសំផន, E313, កថាខណ្ឌទី៤៤៥៤ ដល់ ៤៤៦៥។

ញ- ការចូលមើលកំណត់ត្រារបស់តុលាការស្តីពីការជំនុំជម្រះមេដឹកនាំខ្មែរក្រហម និងសម្ភាររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ពាក់ព័ន្ធនឹង អ.វ.ត.ក។

ដ- ការព្យាបាល និងការផ្សះផ្សារសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដើម្បីព្យាបាលផ្លូវចិត្តជូនដើមបណ្តឹងរដ្ឋប្បវេណី និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ឋ- ការអប់រំផ្នែកច្បាប់ និងសិទ្ធិពលរដ្ឋដល់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិច ដើម្បីឱ្យដើមបណ្តឹងរដ្ឋប្បវេណីអាចយល់បានកាន់តែច្បាស់អំពីឋានៈផ្លូវច្បាប់របស់ពួកគេ ដោយយោងតាមច្បាប់កម្ពុជា។

ឌ- ការលើកកម្ពស់សុខភាព និងសុខុមាលភាពផ្លូវចិត្ត និងកាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងការកាត់ផ្តាច់ពីសង្គមនៃដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងបុគ្គលចាស់ជរា ដែលងាយរងគ្រោះនៅក្នុងប្រទេសកម្ពុជា ដើម្បីជួយដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានវ័យចំណាស់ តាមរយៈការសម្រួលឱ្យទទួលបានសេវាថែទាំសុខភាព និងបង្កើននូវការធានាលើប្រាក់ចំណូលរបស់ពួកគាត់។

ការទទួលស្គាល់លើគម្រោងខាងលើនេះ គឺពិតជាមានសារៈសំខាន់ណាស់សម្រាប់ជនរងគ្រោះ និងប្រជាជនខ្មែរជាទូទៅ ក៏ព្រោះតែគម្រោងនេះនឹងជួយស្តារនូវសេចក្តីថ្លៃថ្នូរដល់ជនរងគ្រោះ និងព្យាបាលរបួសផ្លូវចិត្តរបស់ពួកគាត់ ហើយគម្រោងទាំងនេះក៏ជាវិធានការដ៏ល្អដែលនឹងជំរុញការចែករំលែកនូវចំណេះដឹងដល់សារធារណៈជន ជាពិសេសយុវជនជំនាន់ក្រោយឱ្យបានយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជា ការចាកចេញពីរបបខ្មែរក្រហម និងដំណើរការស្វែងរកយុត្តិធម៌ជូនជាតិមាតុភូមិផងដែរ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

គោលបំណងចម្បងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលកើតចេញពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមកិច្ចសហប្រតិបត្តិការពីសំណាក់អង្គការសហប្រជាជាតិ គឺដើម្បីស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនខ្មែរ និងជាពិសេសដល់ជនដែលរងគ្រោះដោយសាររបបកម្ពុជាប្រជាធិបតេយ្យ។

វត្តមាននៃសមាសភាពជាតិ និងអន្តរជាតិ គឺបង្ហាញឱ្យឃើញពីការគិតគូរទៅលើគុណភាពនៃដំណើរការវិនិច្ឆ័យសេចក្តី ដើម្បីធានាឱ្យបាននូវយុត្តិធម៌ស្របតាមស្តង់ដារអន្តរជាតិ។ ដំណើរការស្វែងរកយុត្តិធម៌ដោយតុលាការនេះ បានបិទបញ្ចប់បេសកកម្មនៃការជំនុំជម្រះក្តីជាស្ថាពរនៅចុងឆ្នាំ២០២២ ដោយបានសម្រេចសេចក្តីទៅលើសំណុំរឿងចំនួន ០២ គឺ ០០១ និង០០២ (០០២/០១ និង០០២/០២)។ ជាលទ្ធផលមេដឹកនាំជាន់ខ្ពស់ ០២រូប គឺ នួន ជា និង ខៀវ សំផន រួមជាមួយនឹងអ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ០១រូបគឺ កាំង ហ្កេចអ៊ាវ ហៅ ឌុច ត្រូវបានសម្រេចឱ្យជាប់ពន្ធនាគារអស់មួយជីវិត។ ថ្វីត្បិតតែទណ្ឌកម្មដែលប្រកាសចំពោះជនជាប់ចោទមិនអាចស្តារស្ថានការណ៍ឱ្យប្រសើរឡើង ឬ លុបលាងនូវសោកនាដកម្មដែលប្រជាជនខ្មែរបានឆ្លងកាត់ក៏ពិតមែន ប៉ុន្តែវត្តមាននៃ អ.វ.ត.ក នឹងក្លាយជាវិធានការដ៏មានប្រសិទ្ធភាពក្នុងការរួមចំណែកដើម្បីទប់ស្កាត់ឧក្រិដ្ឋកម្មនានាដែលបង្កឱ្យកើតមានវិនាសកម្មដល់មនុស្សជាតិ។ ក្រៅតែពីទណ្ឌកម្មដែលប្រកាសដោយតុលាការ ជនជាប់ចោទនឹងទទួលរងនូវទណ្ឌកម្មជាលក្ខណៈប្រវត្តិសាស្ត្រ ដោយកេរ្តិ៍ឈ្មោះ និងសកម្មភាពដ៏សែនអាក្រក់របស់ពួកគេនឹងត្រូវតិះដៀលពីសំណាក់យុវជនខ្មែរគ្រប់ជំនាន់។ បន្ថែមពីនេះ សាលាក្តីខ្មែរក្រហមនឹងក្លាយជាសារដាស់តឿនដល់ថ្នាក់ដឹកនាំនានា ឱ្យមានការប្រុងប្រយ័ត្នខ្ពស់ចំពោះសកម្មភាពទាំងឡាយណាដែលជះផលអវិជ្ជមានដល់អាយុជីវិតប្រទេសជាតិ។

ជារួមមក បើទោះបីជាការកាត់ទោសលើជនជាប់ចោទហាក់បីដូចជាមិនទាន់ធ្ងន់ធ្ងរបើធៀបទៅនឹងអំពើដែលពួកគេបានប្រព្រឹត្តយ៉ាងណាក្តី ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គឺពិតជាបានស្វែងរកនូវយុត្តិធម៌ជូនប្រជាជនខ្មែរ ជាពិសេសជនរងគ្រោះ ដោយពុំអាចប្រកែកបាន។ អ្វីដែលសំខាន់ជាងនេះ គឺការបង្ហាញឱ្យឃើញអំពីសាមគ្គីភាពរបស់បណ្តាប្រទេសលើសកលលោក ក្នុងការចូលរួមបញ្ចប់នូវវប្បធម៌និទណ្ឌភាពដើម្បីបង្កើនភាពសុខដុមរមនាសម្រាប់ប្រជាជាតិទាំងមូល។

# អនុសាសន៍

# អនុសាសន៍

ប្រធានបទនេះ ពិតជាបានផ្តល់នូវបទពិសោធន៍ក្នុងការស្រាវជ្រាវ និងចំណេះដឹងបន្ថែមពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រកម្ពុជា ការបកស្រាយច្បាប់ ជាពិសេសគឺទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលជាអង្គតុលាការពិសេសសម្រាប់ដោះស្រាយលើបញ្ហាដែលបានកន្លងផុតអស់រយៈជាច្រើនឆ្នាំ។ ទន្ទឹមនឹងនេះ យើងខ្ញុំក៏បានជួបនូវឧបសគ្គមួយចំនួនដូចជា បរិមាណនៃឯកសារដ៏ច្រើនសន្ធឹកសន្ធាប់ គួបផ្សំនឹងភាពស្មុគស្មាញដែលពាក់ព័ន្ធនឹងបច្ចេកទេសរបស់ចៅក្រមនៃអង្គជំនុំជម្រះលើការបកស្រាយច្បាប់ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ក៏យើងខ្ញុំបានព្យាយាមអស់ពីសមត្ថភាពតាមដែលអាចធ្វើបាន ដើម្បីសម្រេចឱ្យបាននូវកិច្ចការស្រាវជ្រាវមួយនេះឱ្យខានតែបាន។

ជាការពិត អ.វ.ត.ក បានបញ្ចប់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញដែលជាបេសកកម្មចម្បងរួចរាល់ហើយ ប៉ុន្តែរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ បានសម្រេចបង្កើតកិច្ចព្រមព្រៀងបន្ថែមស្តីពីការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះ ដើម្បីអនុញ្ញាតឱ្យ អ.វ.ត.ក អនុវត្តបន្តលើកិច្ចការដែលនៅសេសសល់ មានជាអាទិ៍ គ្រប់គ្រងបណ្ណសារនៃសំណុំរឿងពាក់ព័ន្ធនឹងការកាត់សេចក្តីរបស់ អ.វ.ត.ក ដោយរក្សាទុកក្នុងកម្រិតស្តង់ដារអន្តរជាតិ ត្រួតពិនិត្យមើលការអនុវត្តចំពោះការផ្តល់សំណងដល់ដើមបណ្តឹងរដ្ឋប្បវេណី និងការផ្សព្វផ្សាយ ក៏ដូចជាការអប់រំស្តីពីសមិទ្ធផលរបស់ អ.វ.ត.ក ជាដើម។ល។ ជុំវិញការសិក្សាស្រាវជ្រាវទៅលើសំណុំរឿងខ្មែរក្រហម យើងខ្ញុំយល់ថាការផ្តល់សំណងរដ្ឋប្បវេណីគប្បីមានការចូលរួមបន្ថែមពីរដ្ឋាភិបាលកម្ពុជា ដើម្បីឱ្យសកម្មភាពនៃការអនុវត្តសំណងដល់ដើមបណ្តឹងកាន់តែមានភាពឱឡារិក។ តួយ៉ាង រដ្ឋាភិបាលគួរតែកំណត់តំបន់មួយដែលរងការបផ្លិចបំផ្លាញធំបំផុតដោយរបបខ្មែរក្រហម មកសាងសង់ហេដ្ឋារចនាសម្ព័ន្ធបន្ថែម ដើម្បីឱ្យក្លាយទៅជាទីកន្លែងផ្ទុកឯកសារនានា ដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍នៃការសម្លាប់ប្រជាជននៅសម័យកម្ពុជាប្រជាធិបតេយ្យ បណ្ណសារទាក់ទងនឹងសំណុំរឿងខ្មែរក្រហម ដោយរក្សាទុកទម្រង់ដើមនៃទីតាំងនោះ។

មុននឹងបញ្ចប់ យើងខ្ញុំសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការស្វែងរកនូវយុត្តិធម៌ដល់ប្រជាជនកម្ពុជា ក៏ដូចជាសូមសម្តែងនូវការគោរពអរគុណយ៉ាងជ្រៅជ្រះចំពោះមន្ត្រី អ.វ.ត.ក ជាតិ និងអន្តរជាតិ ចំពោះការបំពេញមុខងារយ៉ាងយកចិត្តទុកដាក់ ដើម្បីដោះស្រាយបញ្ហាជូនប្រជាជនកម្ពុជា។ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា រាជរដ្ឋាភិបាលនឹងជំរុញឱ្យមានការអប់រំ និងផ្សព្វផ្សាយ អំពីសមិទ្ធផលរបស់ អ.វ.ត.ក ដើម្បីជាចំណេះដឹងដល់មនុស្សជំនាន់ក្រោយឱ្យបានយល់ដឹងអំពីប្រវត្តិសាស្ត្រកម្ពុជា និងការវិនិច្ឆ័យសេចក្តីផងដែរ។

# គន្លិខ្មេស

# គន្ថនិទ្ទេស

## លិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញឆ្នាំ ១៩៧៦ នៃរបបកម្ពុជាប្រជាធិបតេយ្យ។
- រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា។
- សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស អនុម័តនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨។
- កតិសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ អនុម័តនៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦។
- អនុសញ្ញាទីក្រុងហ្សឺណែវ I, II, III, IV ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងពិធីសារបន្ថែមទី I II III ។
- ច្បាប់ស្តីអំពីទំនៀមទម្លាប់មនុស្សធម៌អន្តរជាតិ។
- អនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ អនុម័តនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៤៨។
- ច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៤។
- កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣។
- កិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យលើកិច្ចព្រមព្រៀងស្តីពីការរៀបចំក្នុងពេលអន្តកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣។
- ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១។
- ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។
- ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៦/៧២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦។
- វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

## សេចក្តីសម្រេចរបស់ អ.វ.ត.ក

- សាលក្រមនៃសំណុំរឿងលេខ ០០១, ជនជាប់ចោទ កាំង ហ្គេចអ៊ាវ ហៅឌុច។
- សាលដីកានៃសំណុំរឿងលេខ ០០១, ជនជាប់ចោទ កាំង ហ្គេចអ៊ាវ ហៅឌុច។
- សាលក្រមនៃសំណុំរឿងលេខ ០០២/០១, ជនជាប់ចោទ នួន ជា និង ខៀវ សំផន។
- សាលដីកានៃសំណុំរឿងលេខ ០០២/០១, ជនជាប់ចោទ នួន ជា និង ខៀវ សំផន។
- សាលក្រមនៃសំណុំរឿងលេខ ០០២/០២, ជនជាប់ចោទ នួន ជា និង ខៀវ សំផន។
- សាលដីកានៃសំណុំរឿងលេខ ០០២/០២, ជនជាប់ចោទ ខៀវ សំផន។

## សៀវភៅបោះពុម្ព


- TOM FAWTHROP AND HELEN JARVIS, GETTING AWAY WITH GENOCIDE?: Elusive Justice and the Khmer Rouge Tribunal, London: Pluto Press, 1st ed. 2004.
- វ៉ាន់ឌី កាអុន, ប្រវត្តិសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជាភាគទី ២, បោះពុម្ពផ្សាយលើកទី២។
- ឌី ខាំបូលី, ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩), មជ្ឈមណ្ឌលឯកសារជាតិ, បោះពុម្ពនៅកម្ពុជា, បោះពុម្ពផ្សាយលើកទី២, ២០១១។
- ពុយ គា, រដ្ឋាភិបាលកម្ពុជាពីឆ្នាំ ១៩៤៥ ដល់ ឆ្នាំ ២០១០, រោងពុម្ពពន្លឺខ្មែរ, បោះពុម្ពផ្សាយលើកទី២, ២០១០។


## ឯកសារផ្សេងៗ


- សារលិខិតរបស់សហនាយករដ្ឋមន្ត្រីទី១ និងទី២នៃព្រះរាជាណាចក្រកម្ពុជាប្រជាធិបតេយ្យផ្ញើជូនអគ្គលេខាអង្គការសហប្រជាជាតិ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧។
- របាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៧។
- របាយការណ៍ស្តីពីដំណោះស្រាយរបស់មហាសន្និបាតអង្គការសហប្រជាជាតិ អនុម័តលើស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាលេខ ៥៣/១៣៥ ចុះថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៨។
- របាយការណ៍របស់ក្រុមអ្នកជំនាញអង្គការសហប្រជាជាតិ ដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិលេខ ៥៣/៨៥០ ឆ្នាំ១៩៩៩។
- លិខិតរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិផ្ញើជូនមហាសន្និបាតអង្គការសហប្រជាជាតិ និងអគ្គលេខាធិការនៃក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩។
- របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីអំពីសាលាក្តីខ្មែរក្រហម ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣។

- របាយការណ៍របស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីអំពីសាលាក្តីខ្មែរក្រហម ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣។
- លិខិតរបស់ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ផ្ញើជូនលោក John Gunther Dean ឯកអគ្គរាជទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា

**គេហទំព័រ**

- https://www.eccc.gov.kh/km (ទស្សនាចុងក្រោយ ២៦/សីហា/២០២៣)
- https://khmerrougehistory.org/timeline/ (ទស្សនាចុងក្រោយ ២៦/សីហា/២០២៣)
- https://www.ldc-eccc.gov.kh/index.php?pt&p=1 (ទស្សនាចុងក្រោយ ២៦/សីហា/ ២០២៣)

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១

១.១ ច្បាប់ស្ដីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ១៩៩៤។

១.២ ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៦/៧២ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦។

## ឧបសម្ព័ន្ធទី ២

២.១ សារលិខិតរបស់សហនាយករដ្ឋមន្ត្រីទី១ និងទី២នៃព្រះរាជាណាចក្រកម្ពុជាប្រជាធិបតេយ្យផ្ញើជូនអគ្គលេខាអង្គការសហប្រជាជាតិ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧។

២.២ លិខិតរបស់ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ សិរីមតៈ ចុះថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ ផ្ញើជូនលោក John Gunther Dean ឯកអគ្គរាជទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា។

# ឧបសម្ព័ន្ធទី ១

១.១

# ច្បាប់
## ស្តីពី
# ការដាក់ក្រុម
# កម្ពុជាប្រជាធិបតេយ្យ
# ឱ្យនៅក្រៅច្បាប់

ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ១៩៩៤

# ច្បាប់

## ស្តីពី

## ការដាក់ក្រុម

## « កម្ពុជាប្រជាធិបតេយ្យ »

## ឱ្យនៅក្រៅច្បាប់

### រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា

● ដោយយល់ឃើញថា កិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសនាថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ ស្តីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះនៅកម្ពុជាដែលក្រុម « កម្ពុជាប្រជាធិបតេយ្យ » បានចុះហត្ថលេខាជាមួយហត្ថលេខីខ្មែរបីទៀត តម្រូវឱ្យក្រុម « កម្ពុជាប្រជាធិបតេយ្យ » ក៏ដូចជាហត្ថលេខីបីទៀតអនុវត្តបទបញ្ញត្តិទាំងប៉ុន្មានសម្រាប់នាំមកនូវសន្តិភាពនិងការផ្សះផ្សាជាតិ ។

● ដោយជាក់ស្តែង ក្រុម « កម្ពុជាប្រជាធិបតេយ្យ » មិនព្រមអនុវត្តបទបញ្ញត្តិសំខាន់ៗនៃកិច្ចព្រមព្រៀងខាងលើ ហើយជាពិសេសរំលោភលើមាត្រាដែលទាមទារ :

- ✦ ឱ្យគោរពបទឈប់បាញ់
- ✦ ឱ្យអនុញ្ញាតឱ្យមន្ត្រីនិងបុគ្គលិករបស់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ ( អ.ស.ប ) ចូលទៅក្នុងតំបន់ដែលខ្លួនកាន់កាប់
- ✦ ឱ្យអនុវត្តការប្រមូលផ្តុំកម្លាំងប្រដាប់អាវុធរបស់ខ្លួន ដកអាវុធនិងរំសាយកម្លាំងទ័ព
- ✦ ឱ្យគោរពសិទ្ធិមនុស្សនៅកម្ពុជា

● ដោយលើសពីការមិនគោរពបទបញ្ញត្តិសំខាន់ ៗ ទាំងឡាយខាងលើដែលខ្លួនជាហត្ថលេខី ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ឈ្លានពានដោយប្រដាប់អាវុធទៅលើមន្ត្រីនិងបុគ្គលិករបស់អាជ្ញាធរបណ្តោះអាសន្ននៃ អ.ស.ប ទៅលើមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានិងទៅលើអាយុជីវិតរបស់ប្រជារាស្ត្រកម្ពុជាដោយមិនរើសមុខ ។

- ដោយក្រុម « កម្ពុជាប្រជាធិបតេយ្យ » មិនព្រមចុះឈ្មោះគណៈបក្សរបស់ខ្លួនក្នុងបញ្ជីគណៈបក្សនយោបាយសម្រាប់ចូលរួមក្នុងការបោះឆ្នោតតាមបញ្ញត្តិនៃច្បាប់បោះឆ្នោតរបស់ អ.ស.ប សម្រាប់កម្ពុជា ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៩២ និងព្រមមិនចូលរួមក្នុងកិច្ចអ្វីៗទាំងអស់ ដែលច្បាប់បានបញ្ញត្តិ ដើម្បីឱ្យក្រុមខ្លួនទៅជាគណៈបក្សនយោបាយត្រឹមត្រូវពេញលក្ខណៈច្បាប់ ។

- ដោយតាំងពីពេលបោះឆ្នោតនាឆ្នាំ ១៩៩៣ រៀងរហូតមក ក្រុម «កម្ពុជាប្រជាធិបតេយ្យ» បានប្រព្រឹត្តជាបន្តបន្ទាប់នូវ ឧក្រិដ្ឋកម្ម ភេរវកម្មនិងអំពើប្រល័យពូជសាសន៍ ដែលជាចរិតពិតរបស់ក្រុមខ្លួន តាំងពីក្រុមខ្លួនដណ្តើមយកអំណាចកាន់កាប់នៅខែ មេសា ឆ្នាំ ១៩៧៥ ជម្លៀសប្រជារាស្ត្រ ចាប់ខ្លួន សម្លាប់រង្គាល ហើយក្រោយមក លួចប្លន់ ដាក់មីនពាសវាល ពាសព្រៃ គ្រប់ទិសទី បំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈនិងទ្រព្យសម្បត្តិឯកជន ដឹកនាំកាប់សម្លាប់ប្រជារាស្ត្រ វាយទន្ទ្រានយកទឹកដីជាតិកាន់កាប់ដោយខុសច្បាប់និងលក់សម្បត្តិទ្រព្យធម្មជាតិដោយរំលោភទៅលើអធិបតេយ្យនៃព្រះរាជាណាចក្រកម្ពុជា ។

- ដោយក្រុម « កម្ពុជាប្រជាធិបតេយ្យ » បានរំលោភលើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ជាពិសេសលើបទបញ្ញត្តិនៃ :

មាត្រា ៣ ដែលចែងថា « ព្រះរាជាណាចក្រកម្ពុជា ជារដ្ឋដែលមិនអាចបំបែកបាន »

មាត្រា ៤៩ ដែលចែងថា « ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ » « ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ »

មាត្រា ៥០ ដែលចែងថា « ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពគោលការណ៍អធិប_តេយ្យជាតិនិងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស »

«ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ត្រូវគោរពទ្រព្យសម្បត្តិសាធារណៈនិងកម្មសិទ្ធស្របច្បាប់របស់ឯកជន »

មាត្រា ៥២ ដែលចែងជារួមថា « រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញារក្សាឯករាជ្យអធិបតេយ្យ បូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយបង្រួបបង្រួមជាតិ ដើម្បីការពារឯកភាពជាតិ ការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់និងសន្តិសុខសាធារណៈ » ។

• ដោយក្រុម « កម្ពុជាប្រជាធិបតេយ្យ »មិនព្រមទទួលយកសេចក្ដីអំពាវនាវជាបន្តបន្ទាប់ឱ្យមកចូលរួមក្នុងដំណើរការផ្សះផ្សាជាតិ ប្រកាសឡើងដោយអាជ្ញាធរអ៊ុនតាក់ ដោយថ្នាក់ដឹកនាំភាគីឯទៀត ហើយក្រោយមកនេះ ដោយព្រះករុណាជាអម្ចាស់ជីវិតលើត្បូងនិងដោយរាជរដ្ឋាភិបាលដែលកើតចេញពីការបោះឆ្នោតដោះស្រាយបញ្ហាកម្ពុជា ។

• ដោយយល់ឃើញថា មេដឹកនាំនៃក្រុម «កម្ពុជាប្រជាធិបតេយ្យ » មិនអាចយកកិច្ចព្រមព្រៀងនាទីក្រុងប៉ារីសស្ដីពីដំណោះស្រាយនយោបាយរួមមួយនៃជម្លោះនៅកម្ពុជាធ្វើជាខែលខាងច្បាប់សម្រាប់លាក់បំបាំងយករួចខ្លួនពីការទទួលខុសត្រូវរបស់ពួកខ្លួន ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្ម ភេរវកម្មនិងអំពើប្រល័យពូជសាសន៍ចាប់តាំងពីពេលរបប ប៉ុល ពត ដណ្ដើមកាន់អំណាចនៅឆ្នាំ ១៩៧៥_១៩៧៨ ។ បទឧក្រិដ្ឋប្រល័យពូជសាសន៍គ្មានអាជ្ញាយុកាលឡើយ ។

## ហេតុនេះ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាអនុម័តច្បាប់ដែលមានបញ្ញត្តិដូចតទៅនេះ ៖

**មាត្រា** ១. _ ដាក់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » និងកម្លាំងយោធារបស់ខ្លួនឱ្យនៅក្រៅច្បាប់ ។

**មាត្រា** ២. _ ចាប់ពីថ្ងៃដែលច្បាប់នេះចូលជាធរមាន ជនទាំងឡាយណាដែលជាសមាជិកអង្គការនយោ_បាយនិងជាកម្លាំងយោធារបស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ត្រូវចាត់ទុកជាជនល្មើសនឹងរដ្ឋធម្មនុញ្ញនិងជាជនល្មើសនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

សមាជិកអង្គការនយោបាយឬកម្លាំងយោធារបស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » គឺត្រូវកំណត់បានតែជនទាំងឡាយណាដែលឱ្យបញ្ជា សមគំនិតឬចូលប្រឡូកដោយផ្ទាល់ក្នុងជម្លោះដោយអាវុធ ក្នុងទិសដៅបំរើនយោបាយរបស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ។

ជនខាងលើនេះ មិនត្រូវកំណត់បានដល់ជនទាំងឡាយដែលជាក្រុមគ្រួសារឬជាជនដែលរស់នៅក្រោមការគៀបសង្កត់របស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ឡើយ ។

**មាត្រា** ៣. _ សមាជិកអង្គការនយោបាយនិងកម្លាំងយោធារបស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ឬជនណាដែលបានប្រព្រឹត្តបទឧក្រិដ្ឋធ្វើមនុស្សឃាតដោយចេតនា ចាប់បង្ខំនារីសេពសន្ថវៈ ប្លន់ទ្រព្យសម្បត្តិប្រជា_រាស្ត្រ បំផ្លិចបំផ្លាញទ្រព្យសម្បត្តិសាធារណៈនិងឯកជន ។ ល ។ ត្រូវផ្ដន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរ_មាន ។

**មាត្រា ៤.**_ សមាជិកអង្គការនយោបាយនិងកម្លាំងយោធារបស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ឬជនណាដែលបានប្រព្រឹត្តអំពើ :

- ធ្វើសកម្មភាពអបគមន៍
- បំផ្លាញរាជរដ្ឋាភិបាល
- បំផ្លាញអង្គការនៃអំណាចសាធារណៈ
- ញុះញង់ឬបង្ខំពលរដ្ឋឱ្យកាន់អាវុធប្រឆាំងនឹងអាជ្ញាធរសាធារណៈ ត្រូវចាត់ទុកជាជនឧក្រិដ្ឋប្រឆាំងនឹងសន្តិសុខក្នុងប្រទេស ហើយត្រូវផ្តន្ទាទោសដាក់គុកពី ២០ ឆ្នាំទៅ ៣០ ឆ្នាំ ឬអស់មួយជីវិត ។

**មាត្រា ៥.**_ ច្បាប់នេះអនុគ្រោះទុកពេល ៦ ខែ ក្រោយពីចូលជាធរមាន ឱ្យជនជាសមាជិកអង្គការនយោបាយឬជាកម្លាំងយោធានៃក្រុម « កម្ពុជាប្រជាធិបតេយ្យ » វិលត្រលប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនយកទោសពៃរ៍ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត ។

**មាត្រា ៦.**_ ចំពោះមេដឹកនាំនៃក្រុម « កម្ពុជាប្រជាធិបតេយ្យ » មិនអាចមានការអនុគ្រោះ ដូចមានចែងក្នុងច្បាប់នេះឡើយ ។

**មាត្រា ៧.**_ ព្រះមហាក្សត្រទ្រង់អាចបន្ធូរបន្ថយទោសឬលើកលែងទោសតាមព្រះរាជសិទ្ធិដែលមានចែងក្នុងមាត្រា ២៧ នៃរដ្ឋធម្មនុញ្ញ ។

**មាត្រា ៨.**_ ក្រោយពីច្បាប់នេះចូលជាធរមានភ្លាម ទ្រព្យសម្បត្តិទាំងឡាយដែលស្ថិតនៅក្រោមការគ្រប់_គ្រងរបស់ក្រុម « កម្ពុជាប្រជាធិបតេយ្យ » ឬរបស់ជនល្មើសផ្សេងទៀតហើយដែលបានមកពីការបំបែកកាន់កាប់ទឹកដីមួយផ្នែកនៃព្រះរាជាណាចក្រកម្ពុជាដោយរំលោភច្បាប់ និងយកធនធានធម្មជាតិរបស់ប្រជាជាតិទៅធ្វើអាជីវកម្ម ទ្រព្យសម្បត្តិទាំងឡាយនោះ នឹងត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ ទោះបីស្ថិតនៅក្នុងព្រះរាជាណា_ចក្រកម្ពុជាឬស្ថិតនៅក្រៅប្រទេស ។

**មាត្រា ៩.**_ ជនណាមួយដែលយកច្បាប់នេះទៅរំលោភសិទ្ធិប្រជាពលរដ្ឋដោយធ្វើការគំរាមកំហែង ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន ការធ្វើទារុណកម្មឬរំលោភលើលំនៅស្ថានមិនត្រឹមត្រូវត្រូវផ្តន្ទាទោស ដាក់គុកពី ពីរឆ្នាំទៅ ប្រាំឆ្នាំ ។

អ្នកផ្តល់ពត៌មានមិនពិត អ្នកធ្វើសាក្សីភូតកុហក អ្នកក្លែងបង្កើតភស្តុតាងដើម្បីបំរើផលប្រយោជន៍នៃការយកច្បាប់នេះទៅរំលោភសិទ្ធិប្រជាពលរដ្ឋត្រូវផ្តន្ទាទោសដាក់គុកពី ពីរឆ្នាំទៅ ប្រាំឆ្នាំ ។

ប្រជាពលរដ្ឋរងគ្រោះដោយអយុត្តិធម៌ មានសិទ្ធិប្តឹងតវ៉ាទារសំណង ដើម្បីជួសជុលការខូចខាតដែលបង្កើតឡើងពីការរំលោភសិទ្ធិខាងលើ ។

មាត្រា ១០.- ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ច្បាប់នេះត្រូវបានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
អនុម័តនៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ១៩៩៤ នាសម័យប្រជុំ
រដ្ឋសភាលើកទី ២ នីតិកាលទី ១

ភ្នំពេញ . ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ១៩៩៤
**ប្រធានរដ្ឋសភាស្តីទី**

ឡូយ ស៊ីមឈាង

១.២

## ព្រះរាជក្រឹត្យ

នស/រកត/០៩៩៦/៧២

### យើង

### ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន រាជហរិវង្ស
### ឧភតោសុជាតិ វិសុទ្ធិពង្ស អគ្គមហាបុរសរតន៍ និករោត្តម
### ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ ព្រះចៅក្រុង
### កម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានទ្រង់យល់សេចក្តីប្រកាសចុះថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ១៩៩៦ និង សេចក្តីថ្លែង–ការណ៍ របស់លោក អៀង សារី ប្រធានចលនាបង្រួបបង្រួមជាតិប្រជាធិបតេយ្យ ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ១៩៩៦
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃរាជរដ្ឋាភិបាលកម្ពុជា

### ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានលើកលែងទោសអោយ លោក អៀង សារី អតីតឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុកកិច្ចការបរទេសក្នុងរដ្ឋាភិបាលនៃប្រទេសកម្ពុជាប្រជាធិបតេយ្យដែលត្រូវបានផ្តន្ទាទោសប្រហារជីវិតបង់ និង រឹបអូស ទ្រព្យសម្បត្តិទាំងអស់ តាមអំណាចសាលក្រមរបស់តុលាការប្រជាជនបដិវត្តក្រុងភ្នំពេញ ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ១៩៧៩ និង ចំពោះទោសដែលបានកំណត់ដោយច្បាប់ស្តីពី ការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យអោយនៅក្រៅច្បាប់

ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ៩៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៤ ។

មាត្រា ២: ព្រះរាជក្រឹត្យនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

មាត្រា ៣: ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និង ក្រសួងយុត្តិធម៌ ត្រូវអនុវត្តព្រះរាជក្រឹត្យនេះ អោយបានសំរេចជាស្ថាពរ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ១៩៩៦

**នរោត្តម សីហនុ**

បានក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២**

**នរោត្តម រណឫទ្ធិ ហ៊ុន សែន**

# ឧបសម្ព័ន្ធទី ២

២.១

UNITED NATIONS

A S

General Assembly
Security Council

Distr.
GENERAL

A/51/930
S/1997/488
24 June 1997

ORIGINAL: ENGLISH

GENERAL ASSEMBLY
Fifty-first session
Agenda item 110
HUMAN RIGHTS QUESTIONS

SECURITY COUNCIL
Fifty-second year

Identical letters dated 23 June 1997 from the Secretary-General addressed to the President of the General Assembly and to the President of the Security Council

I attach a letter dated 21 June 1997 which I have received from the two Prime Ministers of the Royal Government of Cambodia in which they "ask for the assistance of the United Nations and the international community in bringing to justice those persons responsible for the genocide and crimes against humanity during the rule of the Khmer Rouge from 1975 to 1979" (see annex).

The facts which gave rise to the request remain unclear. The Office of my Representative in Cambodia is presently seeking to clarify the situation, while the Secretariat is examining the legal and institutional issues involved. The letter is brought to your attention for any action which may be deemed appropriate.

(Signed) Kofi A. ANNAN

ANNEX

Letter dated 21 June 1997 from the First and Second Prime Ministers of Cambodia addressed to the Secretary-General

On behalf of the Government and people of Cambodia, we write to you to ask for the assistance of the United Nations and the international community in bringing to justice those persons responsible for the genocide and crimes against humanity during the rule of the Khmer Rouge from 1975 to 1979.

In its resolution 1997/49 of April 1997 on Cambodia, the Commission on Human Rights requested:

> "the Secretary-General, through his Special Representative, in collaboration with the Centre for Human Rights, to examine any request by Cambodia for assistance in responding to past serious violations of Cambodian and international law as a means of bringing about national reconciliation, strengthening democracy and addressing the issue of individual accountability."

Cambodia does not have the resources or expertise to conduct this very important procedure. Thus, we believe it is necessary to ask for the assistance of the United Nations. We are aware of similar efforts to respond to the genocide and crimes against humanity in Rwanda and the former Yugoslavia, and ask that similar assistance be given to Cambodia.

We believe that crimes of this magnitude are of concern to all persons in the world, as they greatly diminish respect for the most basic human right, the right to life. We hope that the United Nations and the international community can assist the Cambodian people in establishing the truth about this period and bringing those responsible to justice. Only in this way can this tragedy be brought to a full and final conclusion.

(Signed) Prince NORODOM Ranariddh
First Prime Minister

(Signed) HUN Sen
Second Prime Minister

-----

## ២.២



Phnom Penh April 16, 1975

Dear Excellency and Friend,

I thank you very sincerely for your letter and your offer to transport me towards freedom. I cannot, alas, leave in such a cowardly fashion. As for you, and in particular for your great country, I never believed for a moment that you would have this sentiment of abandoning a people, which has chosen liberty. You have refused us your protection, and we can do nothing about it. You leave, and my wish is that you and your country will find happiness under this sky. But, mark it well, that if I shall die here on the spot and in my country that I love, it is too bad, because we are all born and must die one day. I have committed this mistake of believing in you, the Americans."

Regards,

Sirik Matak

Gucci ©